# សង្កេតការណ៍ ១២

## ដំណើរកាត់ទោសមេដឹកនាំខ្មែរក្រហម

ខែមិថុនា ឆ្នាំ២០១២



# រចនាសម្ព័ន្ធរដ្ឋបាល និងប្រព័ន្ធទំនាក់ទំនង និងតួនាទី របស់ជនជាប់ចោទក្នុងរបបកម្ពុជាប្រជាធិបតេយ្យ

## មាតិកា


សវនាការសួរដេញដោលសាក្សី
ស្វូត្រ ទៀង ១
សវនាការសួរដេញដោលសាក្សី
សាឡុត បាន ៨
សវនាការសួរដេញដោលសាក្សី
ពាន យៀន ២៩



ក្រុមសង្កេតការណ៍ ៖
ឆាយ ឈុនលី, ឌី សុជាតា,
លឹម ជ័យច័ន្ទ និង ចាន ប្រាថ្នា


កុយ ធួន (រូបកណ្តាល) និង កែ ពក (រូបឆ្វេង)


មជ្ឈមណ្ឌលឯកសារកម្ពុជា ◆ ស្វែងរកការពិតដើម្បីការចងចាំនិងយុត្តិធម៌ ◆ www.dccam.org



ប៉ុល ពត ជាមួយគណៈប្រតិភូបរទេសក្នុងរបបកម្ពុជាប្រជាធិបតេយ្យ

# សវនាការលើសំណុំរឿង០០២ : រចនាសម្ព័ន្ធរដ្ឋបាល និងប្រព័ន្ធទំនាក់ទំនង និងតួនាទីរបស់ជនជាប់ចោទក្នុងរបបកម្ពុជាប្រជាធិបតេយ្យ

## ថ្ងៃទី១៨-៣០ ខែមេសា ដល់ថ្ងៃទី២-១៧ ខែឧសភា ឆ្នាំ២០១២

*ឌី សុជាតា, ចាន ប្រាថ្នា និង លឹម ជ័យទ័ត្ត*

## សេចក្ដីផ្ដើម

នៅអំឡុងថ្ងៃទី១៨-៣០ខែមេសា ដល់ថ្ងៃទី២-១៧ ខែឧសភា ឆ្នាំ២០១២ អង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានបើកសវនាការលើសំណុំរឿង ០០២ ស្ដីពីរចនាសម្ព័ន្ធរដ្ឋបាល និងប្រព័ន្ធទំនាក់ទំនងការងារនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ នៅក្នុងសវនាការកន្លងមកនេះ អង្គជំនុំជម្រះសាលាដំបូងបានកោះហៅសាក្សីចំនួនបីរូបទៀត ដើម្បីធ្វើការសួរដេញដោលអំពីបញ្ហានានាទាក់ទងនឹងរចនាសម្ព័ន្ធរដ្ឋបាល និងប្រព័ន្ធទំនាក់ទំនងការងារនៃរបបខ្មែរក្រហម ។ សាក្សីទាំងបីរូបនេះមានដូចជា សាក្សី សូត្រ ទឿង សាក្សី សាឡុត បាន និងសាក្សី ពាន យៀន ។ សាក្សី សូត្រ ទឿង ត្រូវបានកោះហៅឲ្យមកផ្ដល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងក្នុងរយៈពេលបីថ្ងៃគឺពីថ្ងៃទី១៨ដល់២០ ខែមេសា ឆ្នាំ២០១២ ។ បន្ទាប់ពីអង្គជំនុំជម្រះសាលាដំបូងបានបញ្ចប់ការស្ដាប់សក្ខីកម្មរបស់សាក្សី សូត្រ ទឿង ដែលជាអតីតអង្គរក្សការពារផ្ទាល់របស់ជនជាប់ចោទ នួន ជា នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ នៅថ្ងៃទី២៣ដល់៣០ ខែមេសា ឆ្នាំ២០១២ អង្គជំនុំជម្រះបានបន្តបើកសវនាការស្ដាប់សក្ខីកម្មរបស់សាក្សីមួយរូបទៀតឈ្មោះ សាឡុត បាន ហៅ ហុង ។ សាក្សី សាឡុត បាន គឺជាអតីតអគ្គលេខាធិការក្រសួងការបរទេស និងជាក្មួយប្រុសបង្កើតរបស់ ប៉ុល ពត ។ បន្ទាប់ពីការបញ្ចប់ការសួរដេញដោលសាក្សី សាឡុត បាន អង្គជំនុំជម្រះបានបន្តការជំនុំជម្រះទៅលើជនជាប់ចោទទាំងបីរូបដដែល មានដូចជា នួន ជា ខៀវ សំផន និងអៀង សារី ដោយបន្តកោះហៅសាក្សីមួយរូបបន្ថែមទៀត ។ សាក្សីដែលត្រូវបានកោះអញ្ជើញមកសួរនាំចាប់ពីថ្ងៃទី២ ខែឧសភា ឆ្នាំ២០១២ នេះមានឈ្មោះថា ពាន យៀន ជាអតីតអង្គរក្សការពារកម្មាភិបាលជាន់ខ្ពស់ខ្មែរក្រហមម្នាក់គឺ លោក កុយ ធួន ដែលជាអតីតប្រធានក្រសួងពាណិជ្ជកម្មនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ នៅក្នុងសវនាការសួរដេញដោលចំពោះសាក្សីទាំងបីរូបនេះ មានការពិភាក្សាអំពីបញ្ហាផ្លូវច្បាប់មួយចំនួនដែលគួរឲ្យចាប់អារម្មណ៍ផងដែរ ដូចជាការអនុវត្តសិទ្ធិនៅស្ងៀមមិនឆ្លើយតបសំណួរដោយជនជាប់ចោទ ក៏ដូចជាសិទ្ធិរបស់សាក្សីក្នុងការមិនផ្ដល់ចម្លើយទាំងឡាយណាដែលនាំឲ្យមានការដាក់ពិរុទ្ធភាពមកលើខ្លួនឯងជាដើម ។

## I. សវនាការសួរដេញដោលសាក្សី សូត្រ ទឿង



សូត្រ ទឿង

ឆ្លងផុតការពិភាក្សាអំពីការអនុវត្តសិទ្ធិនៅស្ងៀមមិនឆ្លើយតបសំណួររបស់ជនជាប់ចោទ នួន ជា អង្គជំនុំជម្រះសាលាដំបូងបានបន្តសវនាការរបស់ខ្លួនដោយសួរដេញដោលសាក្សីមួយរូបទៀតទាក់ទងនឹងរចនាសម្ព័ន្ធរដ្ឋបាល និងទំនាក់ទំនងការងារនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ សាក្សីដែលអង្គជំនុំជម្រះកោះហៅមក

ក្នុងសវនាការនាពេលនេះមានលេខសម្គាល់ TCW-617 ដែលមានឈ្មោះថា សូត្រ ទឿង ។ លោក សូត្រ ទឿង បច្ចុប្បន្នជាកសិករម្នាក់ ដែលមានអាយុ៦២ឆ្នាំ និងមានកូនចំនួនប្រាំបួននាក់ ។ មុននឹងឈានដល់ការសួរអំពីពត៌មានលម្អិត លោកប្រធានអង្គជំនុំជម្រះបានណែនាំពីសិទ្ធិមួយចំនួនដល់សាក្សី ។ លោកប្រធានបានណែនាំថា សាក្សីមានសិទ្ធិក្នុងការបដិសេធមិនឆ្លើយតបសំណួរទាំងឡាយដែលដាក់ពិរុទ្ធភាពលើខ្លួនឯង ។ ប៉ុន្តែទាក់ទងនឹងចំណុចនេះសាក្សីបានឆ្លើយតបវិញថាខ្លួនមិនយល់ពីបញ្ហានេះទេ ។ លោកប្រធានបានព្យាយាមពន្យល់ពីសិទ្ធិនេះជាថ្មីដល់សាក្សី ។ បន្ទាប់មកលោកមេធាវីអន្តរជាតិការពារក្តីជនជាប់ចោទ នួន ជា គឺលោក អេនទ្រូ អ៊ីនូហ្វី បានលើកឡើងដោយផ្អែកទៅលើវិធាន២៨ នៃវិធានផ្ទៃក្នុងថាអង្គជំនុំជម្រះត្រូវតែធ្វើអន្តរាគមន៍សួរបញ្ជាក់ឲ្យបានច្បាស់លាស់ ចំពោះភាពដែលអាចមានការចោទប្រកាន់ណាមួយមកលើសាក្សី ។ អង្គជំនុំជម្រះត្រូវធានាដែរថា ភស្តុតាងដែលអាចផ្តល់មកនឹងត្រូវបានរក្សាជាការសម្ងាត់មិនឲ្យសាធារណៈជនដឹងបាន ឬក៏នឹងត្រូវយកមកប្រើប្រាស់ដោយផ្ទាល់ និងដោយប្រយោលដើម្បីធ្វើការចោទប្រកាន់នោះទេ ។ ដូច្នេះជំហររបស់លោកមេធាវីគឺសូមឲ្យអង្គជំនុំជម្រះបញ្ជាក់ឲ្យបានច្បាស់លាស់ ឬបញ្ជាក់ដល់សាក្សីនៅក្នុងសវនាការជាម្ងាត់ ។ លោកតំណាងសហព្រះរាជអាជ្ញាអន្តរជាតិបានធ្វើការគាំទ្រចំពោះសវនាការជាសម្ងាត់ ។ លោកមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីជាតិលោក ពេជ អង្គ បានលើកឡើងថា អ្វីដែលមេធាវីការពារក្តីជនជាប់ចោទ នួន ជា បានលើកឡើងអាចមានការប៉ះពាល់ដល់អារម្មណ៍របស់សាក្សីក្នុងការឆ្លើយការពិត ។ លោកមេធាវីបានបន្តទៀតថា ទាក់ទងនឹងប្រភេទបុគ្គលដែលត្រូវចោទប្រកាន់ដោយតុលាការនេះដែលផ្តោតទៅលើតែបុគ្គលពីរប្រភេទគឺអ្នកដឹកនាំជាន់ខ្ពស់ និងអ្នកទទួលខុសត្រូវខ្ពស់បំផុតប៉ុណ្ណោះ ។

ដោយសារតែសំណើរបស់លោកមេធាវីមានលក្ខណៈមិនច្បាស់លាស់លោកប្រធានបានអនុញ្ញាតឲ្យតំណាងសហព្រះរាជអាជ្ញាជាតិ លោក សេង ប៊ុនឃាង ធ្វើការចាប់ផ្តើមតាំងសំណួរ ប៉ុន្តែត្រូវបានលោកមេធាវី អេនទ្រូ អ៊ីនូហ្វី ក្រោកឈរដើម្បីធ្វើការស្នើសុំជាថ្មីដោយសុំឲ្យអង្គជំនុំជម្រះបើកសវនាការជាអសាធារណៈ ។ សំណើនេះត្រូវបានលោកប្រធានអង្គជំនុំជម្រះបដិសេធ ហើយលោកប្រធានក៏បានរំឭកដល់គ្រប់ភាគីទាំងអស់នៅពេលដែលមានបំណងស្នើសុំឲ្យបើកសវនាការជា អសាធារណៈនាពេលអនាគតគឺត្រូវដាក់សំណើជាលាយលក្ខអក្សរឲ្យបានច្បាស់លាស់ និងធ្វើឲ្យបានមុនពេលអង្គជំនុំជម្រះអញ្ជើញសាក្សីមកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការ ។ លោកប្រធានបានផ្តល់វេទិកាដល់លោកសហព្រះរាជអាជ្ញាធ្វើការតាំងសំណួរដល់សាក្សី ។

## ១) ការសួរដេញដោលសាក្សី សូត្រ ទឿង ដោយសហព្រះរាជអាជ្ញា

លោកតំណាងសហព្រះរាជអាជ្ញាជាតិ សេង ប៊ុនឃាង បានចាប់ផ្តើមធ្វើការតាំងសំណួរដំបូងទាក់ទងនឹងប្រវត្តិរូបខ្លះរបស់សាក្សី ។ ឆ្លើយតបតាមសំណួររបស់លោកសហព្រះរាជអាជ្ញា លោក សូត្រ ទឿង ជម្រាបថា ខ្លួនបានចូលបដិវត្តនៅឆ្នាំ១៩៦៨ តាមរយៈឈ្មោះ អ៊ឹង ហើយនៅពេលនោះលោកស្ថិតនៅក្នុងក្រុមកុមារចលនាតស៊ូ ។ លោកសាក្សីចូលក្នុងសម្ព័ន្ធយុវកក អំឡុងឆ្នាំប្រហែល១៩៧២ តាមរយៈឈ្មោះ គូ ។ លោកមិនធ្លាប់បានចូលរួមវគ្គសិក្សាអំពីមាគ៌ាបក្ស ឬគោលនយោបាយ បក្សនោះទេ ប៉ុន្តែលោកធ្លាប់មានកូនសៀវភៅដែលអប់រំសីលធម៌១២ប្រការ ។

លោកតំណាងសហព្រះរាជអាជ្ញាបានសួរដេញដោលពីមន្ទីរប-២០ ប៉ុន្តែភ្លាមនោះ លោកសាក្សីមិនស្គាល់ និងមិនដឹងថាមន្ទីរនោះមានទីតាំងនៅកន្លែងណាទេ ។ លោកគ្រាន់តែដឹងថាជាកន្លែងសម្រាប់ដាំបន្លែ និងចិញ្ចឹមសត្វជ្រូក មាន់ ជាដើម ។ ឆ្លើយតបនឹងសំណួរបន្ទាប់ លោក សូត្រ ទឿង បានជម្រាបជូនអង្គជំនុំជម្រះថា លោកធ្វើការនៅមន្ទីរប-២០ ជាអ្នកដឹកជញ្ជូនតាមកាណូតនូវបន្លែ អង្ករ និង ដឹកជញ្ជូនគ្រាប់ចុះឡើងជាដើម ។ ប្រហែលកន្លះឆ្នាំបន្ទាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ លោកបានចាកចេញពីកន្លែងកុមារ ទៅកន្លែង ខាំ មី ដែលជាអ្នកគ្រប់គ្រងកងការពារ ឬកងទ័ពនៅមន្ទីរ យ-១០ ។

### ◆ ការជម្លៀសនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥

លោកតំណាងសហព្រះរាជអាជ្ញា បានរំឭកឡើងវិញដោយការសួរនាំទាក់ទងនឹងការជម្លៀសនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ។ សាក្សី សូត្រ ទឿង បានបដិសេធសំណួរមួយចំនួនដោយប្រើពាក្យថាមិនមានការចងចាំចំពោះព្រឹត្តការណ៍ទាំងនោះ

ព្រមទាំងឆ្លើយតបនឹងសំណួរមួយចំនួនថា សភាពទីក្រុងភ្នំពេញនៅពេលជម្លៀសគឺមានសភាពស្ងប់ស្ងាត់ និងមានមនុស្សដើរតាមផ្លូវមួយៗ ប៉ុន្តែមានតែកងទ័ពនៅពាសពេញទីក្រុង ។ ក្រោយពេលលោកមកដល់ទីក្រុងភ្នំពេញលោកបានទៅនៅមន្ទីរ យ-១០ ។ ពេលនោះឈ្មោះ ហនុមាន និងឈ្មោះ ហាគូ បាននាំលោកឲ្យមកធ្វើការជាអ្នកយាមនៅមន្ទីរនោះ ។

**កំណត់សម្គាល់៖** ក្រោយពេលបើកសវនាការអសាធារណៈស្តីពីការប្រើប្រាស់សិទ្ធិនៅស្ងៀមមិនឆ្លើយតបរបស់ជនជាប់ចោទរួចមក លោកប្រធានបានផ្តល់វេទិការសួរដេញដោលចំពោះសាក្សីជូនទៅតំណាងសហព្រះរាជអាជ្ញា ជាតិ សេង ប៊ុនឃាង សារជាថ្មី ។ លោក សេង ប៊ុនឃាង បានបន្តសំណួរដោយលើកយកសក្ខីកម្មដែលសាក្សីផ្តល់ជូនសហចៅក្រមស៊ើបអង្កេតពាក់ព័ន្ធនឹងការអមដំណើរ ជនជាប់ចោទ នួន ជា ទៅធ្វើទស្សនកិច្ចនៅប្រទេសចិន តួនាទីជាអង្គរក្សការពារ នួន ជា និងតួនាទីជា និរសាបញ្ជូនសំបុត្រ ។

## ◆ ការអមដំណើរជនជាប់ចោទ នួន ជា

សាក្សីធ្លាប់បានអមដំណើរជនជាប់ចោទ នួន ជា ទៅប្រទេសចិន និងកូរ៉េខាងជើង ក្នុងរយៈពេលពីរសប្តាហ៍ ដែលមួយប្រទេសមួយសប្តាហ៍ តាមរយៈយន្តហោះរបស់ប្រទេសចិន ។ ដោយសារសាក្សីមិនចងចាំនូវព្រឹត្តិការណ៍នៃការអមដំណើរជនជាប់ចោទ នួន ជា ទៅប្រទេសទាំងពីរខាងលើ លោកតំណាងសហព្រះរាជអាជ្ញា ឌុល លីសាក់ បានដាក់បង្ហាញឯកសារដើម្បីរំឭកដល់ការចងចាំព្រឹត្តិការណ៍ ។ ប៉ុន្តែការដាក់បង្ហាញឯកសារនេះត្រូវបានលោកមេធាវីអន្តរជាតិការពារក្តីជនជាប់ចោទ អៀង សារី គឺលោក កាណាវ៉ាស បានធ្វើការជំទាស់ដោយលើកឡើងថា មិនគួរមានការបង្ហាញបែបនេះទេ ដោយសារសហព្រះរាជអាជ្ញាបានសួរទៅសាក្សីរួចហើយ ទើបបានដាក់បង្ហាញឯកសារនៅតាមក្រោយបន្ទាប់ពីសាក្សីឆ្លើយថាមិនចាំ ។ លោកប្រធានអង្គជំនុំជម្រះបានបដិសេធការជំទាស់របស់លោកមេធាវី កាណាវ៉ាស និងអនុញ្ញាតឲ្យសហព្រះរាជអាជ្ញាដាក់បង្ហាញឯកសារទៅសាក្សី ។ សាក្សីបានឆ្លើយថាខ្លួនមិនបានដឹងថា នួន ជា ធ្វើការងារអ្វីខ្លះនៅប៉េកាំងនោះទេ ព្រោះខ្លួនមិនបានចូលទៅខាងក្នុងជាមួយឡើយ គឺនៅខាងក្រៅដើម្បីយាម ។ សាក្សីបានបន្តទៀតថា លោក នួន ជា និយាយពីបញ្ហាសេដ្ឋកិច្ច តែលោកមិនដឹងថាជាអ្វីទេ ។ នួន ជា បានជួបជាមួយមេដឹកនាំចិនដែរ ប៉ុន្តែគាត់មិនស្គាល់ ។

សាក្សីបានជម្រាបថា ចំពោះដំណើរទស្សនកិច្ចនៅកូរ៉េខាងជើង ដំបូង នួន ជា ទៅកន្លែង គីម អ៊ីលស៊ុង ហើយក្រោយមកបន្តដំណើរទៅតំបន់ជនបទនៃប្រទេសនេះ ដែលមានសាក្សីជាអ្នកអមដំណើរទៅជាមួយដែរ ។ ចំពោះសំណួរទាក់ទងនឹងការរៀបចំម្ហូបនៅប្រទេសកូរ៉េថាតើខុសគ្នាយ៉ាងណាជាមួយម្ហូបអាហារនៅរបប


ការហូបចុកផ្ទះបាយរួម

កម្ពុជាប្រជាធិបតេយ្យនោះ លោក កាណាវ៉ាស ការពារក្តីឲ្យជនជាប់ចោទ អៀង សារី និងលោកមេធាវី គង់ សំអុន ការពារក្តីជនជាប់ចោទ ខៀវ សំផន បានជំទាស់ដោយផ្តល់ហេតុថា ជាសំណួរដែលមិនជាប់ពាក់ព័ន្ធ ហើយវាមិនដូចគ្នាទេ ព្រោះពេលនោះជាពេលដែលប្រទេសកូរ៉េខាងជើងរៀបចំទទួលអ្នកដឹកនាំគណៈប្រតិភូ មិនមែនជាម្ហូបដែលប្រជាជនកូរ៉េហូបចុកប្រចាំថ្ងៃនោះឡើយ ប៉ុន្តែបើជាម្ហូបប្រចាំថ្ងៃមែន ក៏សាក្សីមិនមានជំនាញក្នុងការប្រៀបធៀបដែរ ។ លោកប្រធានបានសម្រេចដោយផ្ទាល់មាត់ថា ការជំទាស់របស់មេធាវីមានប្រសិទ្ធិភាព និងបានបង្គាប់ទៅសាក្សីមិនចាំបាច់ឆ្លើយនូវសំណួរនេះទេ ។

## ◆ តួនាទីជាអង្គរក្សការពារជនជាប់ចោទ នួន ជា

លោក សូត្រ ទឿង បម្រើការជាអង្គរក្សការពារជនជាប់ចោទ នួន ជា នៅអំឡុងពេលប្រហែលជាពាក់កណ្តាលឆ្នាំ១៩៧៥ រហូតដល់ពេលលោកទៅប៉េកាំង ប្រហែលឆ្នាំ១៩៧៧ ដែលមានភារកិច្ច

ការពារទាំងយប់ទាំងថ្ងៃដើម្បីសុវត្ថិភាព នួន ជា ។ ក្រុមមនុស្សយកមកពីមន្ទីរយ-១០ សម្រាប់ទៅការពារ នួន ជា គឺមានការចល័តគ្នា និងមានកាន់អាវុធដល់ទៅពីរប្រភេទទៀតផង ដូចជា អាកា និង សេកាសេ ក្នុងការការពារថ្នាក់ដឹកនាំ ។ លោកមានភារកិច្ចការពារជុំវិញការធ្វើដំណើររបស់ នួន ជា ដូចជាការចុះតាមខេត្តដើម្បីអប់រំ បើកអង្គប្រជុំ ការជួបជាមួយប្រធានភូមិភាគ និងប្រធានតំបន់ ការចុះទៅពិនិត្យទំនប់ប្រឡាយជាដើមដែលការចុះនេះគឺក្នុងរយៈពេល ២-៣ខែម្តង ។ តាមចម្លើយរបស់សាក្សី អ្នកអមដំណើរជនជាប់ចោទ នួន ជា នៅពេលដែលគាត់ធ្វើដំណើរទៅខេត្តម្តងៗ មានគ្នាប្រហែល១០ ឬនៅពេលខ្លះលើសពី១០នាក់ ។ ពេលធ្វើដំណើរ នួន ជា ជិះក្នុងឡានជាមួយអ្នកបើកឡានម្នាក់ និងនិរសាផ្ទាល់របស់គាត់ម្នាក់ប៉ុណ្ណោះ ចំណែកសាក្សីជិះនៅក្នុងឡានកងការពារមួយផ្សេង ។ មន្ទីរយ-១០ មានទីតាំងនៅជាប់នឹងមន្ទីរក-១ នៅស្ថានទូតអាមេរិក និងមានសមាជិកធ្វើការប្រហែល៣០នាក់ ។ លោកសាក្សីបានជម្រាបជូនអង្គជំនុំជម្រះថា ក្នុងរយៈពេលប្រហែលបីខែ ដែលលោកស្ថិតនៅមន្ទីរយ-១០ លោកធ្លាប់បានឃើញមេដឹកនាំធំៗ ដូចជា ប៉ុល ពត នួន ជា សុន សេន ខៀវ សំផន និងអៀង សារី ចេញចូលមន្ទីរក-១ និងក-៣ ទៀតផង ។ លោកសាក្សីបានឲ្យដឹងថា ថ្នាក់ដឹកនាំដែលស្នាក់នៅមន្ទីរ ក-១ មានផ្លាស់គ្នាចុះឡើងពីរនាក់ គឺ នួន ជា និង ប៉ុល ពត ។

លោកសាក្សីបានបញ្ជាក់ជូនអង្គជំនុំជម្រះតាមរយៈសំណួរពីសហព្រះរាជអាជ្ញាទាក់ទងនឹងមន្ទីរ ក-៧ ដែលមានទីតាំងនៅជាប់មាត់ទន្លេ និងផ្ទះពីរជាន់ ។ ទីនេះជាកន្លែងសម្រាប់ទទួលមនុស្សពីជនបទ រួចហើយធ្វើការបែងចែកមនុស្សទៅតាមអង្គភាពក្នុងរយៈមួយទៅពីរថ្ងៃ ឬអ្នកខ្លះអាចស្នាក់នៅរហូតដល់មួយខែទើបត្រូវបានគេបែងចែកក៏មានដែរ ។ លោកមិនធ្លាប់ស្នាក់នៅក្នុងមន្ទីរ ក-៧ ទេគ្រាន់តែធ្លាប់ដើរកាត់ប៉ុណ្ណោះ ។

យោងតាមការផ្តល់សក្ខីកម្ម ភាគច្រើនសាក្សី សូត្រ ឡើង មិនសូវបានដឹងពីអត្ថន័យនៃកិច្ច ប្រជុំនានាដែលជនជាប់ចោទ នួន ជា បានចូលរួមនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យប៉ុន្មានទេ ដោយសារលោកតែងតែយាមកាមនៅខាងក្រៅបន្ទប់ ឬសាលប្រជុំ ។ លោកក៏មិនចាំ ថាតើមានអ្នកដឹកនាំ ចូលរួមក្នុងកិច្ចប្រជុំដែរទេ ឬក៏ នួន ជា ធ្លាប់បានលើកឡើងពីបញ្ហាជនក្បត់ដែរឬយ៉ាងណាឡើយ ដោយសារលោកនៅការពារពីខាងក្រៅ ។ ឆ្លើយតបនឹងការរំពុក


នួន ជា ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ

ឡើងរបស់តំណាងសហព្រះរាជអាជ្ញា សាក្សីចាំបានថាជាការពិតមែន គឺខ្លួនធ្លាប់ការពារ នួន ជា ទៅបើកវគ្គរៀនសូត្រនៅបុរីកីឡា ក្នុងរយៈពេលបី-បួន ខែម្តង ដែលមានមនុស្សចូលរួមប្រហែលពី ១០ទៅ៣០នាក់ ប៉ុន្តែលោកក៏នៅតែមិនសូវមានភាពច្បាស់លាស់ប៉ុន្មានដែរ ដោយសារលោកមិនបានចូលដល់ខាងក្នុងជាមួយ នួន ជា ។ គួរបញ្ជាក់ដែរថា សាក្សីធ្លាប់បានចូលរួមរក្សាសន្តិសុខនៅក្នុងកម្មវិធីធំៗ ដូចជា ខួបបក្ស ១៧ មេសា ឬមហាសន្និបាតបក្ស និងបានឃើញដូចជា ប៉ុល ពត អៀង សារី ខៀវ សំផន ជាដើម ដែលមានវត្តមាននៅក្នុងអង្គមេទ្ទិញទាំងនោះ ។

### ◆ តួនាទីជានីរសាបញ្ជូនសំបុត្រដល់ជនជាប់ចោទ នួន ជា

លោក សូត្រ ទៀង ធ្លាប់បានបម្រើការជាអ្នករត់សំបុត្រពីជនជាប់ចោទ នួន ជា ទៅ ឌុច នៅមន្ទីរសន្តិសុខស-២១និងពី ឌុច ទៅ នួន ជា ក្នុងរយៈពេលប្រហែលបីឆ្នាំ ។ នៅក្នុងការរត់សំបុត្រនោះគឺ នួន ជា បានយកមកប្រគល់ឲ្យខ្លួនផ្ទាល់ ហើយខ្លួនយកសំបុត្រនោះទៅប្រគល់ជូន ឌុច នៅកន្លែងធ្វើការ ប៉ុន្តែត្រឹមតែមាត់ទ្វារបងនៃមន្ទីរ ស-២១ ប៉ុណ្ណោះព្រោះ ឌុច នៅខាងក្នុង ហើយពេលនោះលោកមិនចាំថាជាកន្លែងណានោះទេ ។ ឯកសារនោះត្រូវបានដាក់ក្នុងស្រោមសំបុត្រ ដែលមានចារអំពីឈ្មោះអ្នកជូន និងអ្នកទទួល គឺ ឌុច និង នួន ជា ។ លោកមិនហ៊ានបើកមើលឯកសារក្នុងស្រោមសំបុត្រទេ គ្រាន់តែដឹងថាវាមានកម្រាស់ធម្មតាប្រហែលសៀវភៅ និងមានពណ៌លឿង ។ ពេលសាក្សីនាំយកសំបុត្រទៅជូន ឌុច គឺធ្វើតាមរយៈ ប៉ង់ ហើយប្រើពេលធ្វើដំណើរប្រហែល៥នាទីប៉ុណោះតាមរយៈម៉ូតូ ។ ចំណែក នួន ជា វិញគឺសាក្សីប្រគល់ឯកសារជូនជនជាប់ចោទ នួន ជា ដោយផ្ទាល់ដៃនៅពេលខ្លះ ។ លោកធ្វើការងារនេះប្រហែលមួយខែគឺធ្វើបានបួនប្រាំដង ប៉ុណ្ណោះ ។

### ◆ ទស្សនាវដ្តីយុវជនយុវនារីបដិវត្ត

លោក សូត្រ ទៀង បានទទួលទស្សនាវដ្តីយុវជនយុវនារីបដិវត្តនៅឆ្នាំ១៩៧៨ ហើយលោកទទួលបានរហូតដល់ឆ្នាំ១៩៧៦ ។ លោកសាក្សីបានជម្រាបជូនអង្គជំនុំជម្រះថា ថ្វីដ្បិតតែខ្លួនមិនមានលទ្ធភាពអានអក្សរ ប៉ុន្តែនៅពេលប្រជុំនាសម័យនោះ ប្រធានអង្គប្រជុំដែលជួនកាលគឺ ខាំ មុី ជួនកាល ប៉ង់ បានអាននូវអត្ថន័យនៃទស្សនាវដ្តីនេះឲ្យស្តាប់ ។ ប៉ង់ ដែលជាអ្នកគ្រប់គ្រងរួមនៅមន្ទីរ ក-១ បានបង្រៀនអំពីខ្លឹមសារទស្សនាវដ្តីនៅមន្ទីរ ក-៧ និង យ-១០ ។

### ២) ការសួរដេញដោលដោយសាក្សី សូត្រ ទៀង ដោយក្រុមមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី

លោកស្រីមេធាវី ទី ស្រ៊ីណា បានចាប់ផ្តើមដោយត្រឡប់ទៅក្រោយបន្តិចអំពីអ្នកដែលតែងតាំង ជាកងការពាររបស់ នួន ជា នោះគឺ ប៉ង់ ដែលជាអ្នកណែនាំអំពីគោលការណ៍នៃការកាពារដល់លោក សូត្រ ទៀង ។ មួយរយៈពេលក្រោយមក គឺនៅអំឡុងឆ្នាំប្រហែល១៩៧៧ ទើបអង្គការបញ្ជូនលោកទៅការពារ នួន ជា ដោយសារលោកជាមនុស្សមិនសូវចេះដឹង ហើយមានភាពស្មោះត្រង់ ។ ក្នុងពេលបម្រើការងារជាអ្នកការពារសន្តិសុខជូន នួន ជា លោកសាក្សីមិនមែនជាអ្នកការពារផ្ទាល់ទេ គឺគ្រាន់តែទៅទីនេះទីនោះតាមបញ្ជារបស់ នួន ជា ប៉ុណ្ណោះ ។ លោកបំពេញកាងារនេះតាំងពីឆ្នាំ១៩៧៥-៧៨ ។ លោកធ្លាប់អមដំណើរ នួន ជា ទៅតំបន់នីមួយៗដូចជា ភូមិភាគបូព៌ា បាត់ដំបង កំពង់ឆ្នាំង និង កំពង់ស្ពឺ ។ លោកបានឃើញមានស្ថានភាពប្រជាជន គឺមានសភាពស្គមដោយការអត់បាយ បើតាមការស្មានរបស់លោកនៅពេលនោះ ។ លោកឃើញ នួន ជា ពិនិត្យការងាររបស់ប្រជាជន ហើយពេលខ្លះ នួន ជា អប់រំប្រជាជននៅតាមសហករណ៍ ។ ប្រជាជននៅបាត់ដំបងនៅអំឡុងឆ្នាំ១៩៧៧នោះ គឺធ្វើស្រែ ធ្វើទំនប់ជាដើម ។ ជនជាប់ចោទ នួន ជា បានទៅជួបប្រធានសហករណ៍មួយចំនួន និងបានឈៀងទៅសួរសុខទុក្ខសាច់ញាតិផងដែរ ។ លោកបានអមដំណើរ នួន ជា ទៅតំបន់បូព៌ានិងបានឃើញប្រជាជននៅទីនោះ គឺមានសភាពធម្មតាដែលគ្រាន់បើជាងប្រជាជននៅបាត់ដំបង ។ លោកបានអមដំណើ នួន ជា ទៅទំនប់ ១ មករា និងបានឃើញប្រជាជនយ៉ាងច្រើនរែកដី ដើម្បីសាងសង់ទំនប់នេះ ។ ពេល នួន ជា ចុះទៅម្តងៗ លោកឃើញប្រជាជនធ្វើការតាមធម្មតាមិនមានឈប់សម្រាកទេ ។ លោកថែមទាំងឃើញមានការសាងសង់ទំនប់ឡើងវិញ នៅពេលដែលធ្វើមិនបានល្អដូចតម្រូវការ ។ គួរកត់សម្គាល់ដែរថា លោកស្រីមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានអង្គជំនុំជម្រះរំឭកជាច្រើនដង ចំពោះការរក្សាគម្លាតពេលបន្តិច ដើម្បីឲ្យអ្នកបកប្រែអាចមានពេលបញ្ចប់ឃ្លាបកប្រែ

របស់ខ្លួន ។ សាក្សីបានបន្តទៀតថា នៅពេល នួន ជា ឃើញការលើកទំនប់មិនបានល្អ គាត់បានហៅប្រធានសហករណ៍មកអប់រំ ជូនកាលគាត់ហៅអប់រំនៅកន្លែងនោះតែម្តង ។ បន្ទាប់ពីការចុះទៅពិនិត្យទំនប់ ១ មករា ជនជាប់ចោទ នួន ជា បានបន្តទៅពិនិត្យនៅគ្រប់កន្លែងផ្សេងទៀត ឯសាក្សីមិនសូវបានទៅការពារជាប់ជាមួយទេ ។ ការសួរទាក់ទងនឹងការធ្វើដំណើរទៅប្រទេសចិន និងកូរ៉េខាងជើង សាក្សីមិនបានឃើញមានការចុះកិច្ចព្រមព្រៀងជាមួយចិន និងកូរ៉េខាងជើងទេ ព្រោះលោកនៅយាម ខាងក្រៅ ។

បន្ទាប់ពីលោកស្រីមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ទីស្រ៊ីណា បានបញ្ចប់សំណួររបស់ខ្លួន លោកស្រីមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី អេលីហ្សាប៊ែត ស៊ីម៉ុណូហូត បានទទួលការអនុញ្ញាតពេលវេលាបន្ថែម១៥នាទីតាមការស្នើសុំ ។ តាមរយៈសំណួរពីលោកស្រីមេធាវីបានឲ្យដឹងថា នៅមុនឆ្នាំ១៩៧៥ សាក្សីចូលបដិវត្តនៅខេត្តរតនគិរី លោកមិនបានឃើញមេដឹកនាំទេ ។ សាក្សីមិនស្គាល់ លោក ខ្ញុំពីត ទេ ប៉ុន្តែស្គាល់លោក ខាំមុំ ។ នៅឆ្នាំ១៩៦៨ លោកមិនរស់នៅក្នុងកងចល័តទេ គ្រាន់តែផ្លាស់ទីចុះឡើងប៉ុណ្ណោះ ។ លោក សូត្រ ទឿង បានដឹកគ្រាប់រំសេវតាមឡានកាំម្ញូងដែលជាឡានរបស់ប្រទេសចិនទៅកំពង់ឆ្នាំង និងកំពង់ចាមដើម្បីវាយជាមួយយួននៅអំឡុងឆ្នាំ១៩៧៤ ។ ពេលនោះ លោកនៅខាងផ្នែកដឹកជញ្ជូន មិនមែនផ្នែកយោធាទេ ប៉ុន្តែលោកធ្វើការជំនួសគេ ជាអ្នកដឹកគ្រាប់រំសេវបានមួយរយៈពេលប៉ុណ្ណោះ ។ លោកស្រីមេធាវីអន្តរជាតិបានបន្តសាកសួរអំពីមន្ទីរប-៥ ប៉ុន្តែសាក្សីមិនស្គាល់ ។ ចំពោះសំណួរទាក់ទងនឹងក្រមសីលធម៌ទាំង១២ប្រការ លោកសាក្សីដែលតែងតែផ្តល់នូវចម្លើយតបខ្លីៗកន្លងមក បានជម្រាបជូនអង្គជំនុំជម្រះថា ខ្លួនធ្លាប់ទទួលបានឯកសារនេះ ។ សាក្សីបានបន្តទៀតថា វាមានសារសំខាន់ណាស់ និងជាឯកសារល្អមួយដែលអាចអប់រំដើម្បីបំបាត់អំពើពុករលួយ ហើយចំពោះអ្នកមិនចេះអក្សរគឺប្រធានអង្គប្រជុំបានអានឲ្យស្តាប់ ។ សម្រាប់អ្នកមិនគោរពតាមប្រការទាំងនោះ គឺត្រូវបានអង្គការនាំយកទៅអប់រំ ។ នៅក្នុងសវនាការនារសៀលនោះ សាក្សី សូត្រ ទឿង បានទទួលស្គាល់អ្វីដែលលោកបានជម្រាបជូនចៅក្រមស៊ើបអង្កេតកាលពីពេលកន្លងមកថា បើយើងមិនគោរពតាមក្រមសីលធម៌របស់បក្សទេយើងនឹងត្រូវស្លាប់ ហើយលោកមិនអាចពន្យល់បានទេត្រង់ចំណុចនេះ ។ នៅចន្លោះឆ្នាំ១៩៧៥-៧៩ មានការតឹងរ៉ឹងចំពោះសេរីភាពណាស់ តាមការយល់របស់លោកគឺវាស្ថិតនៅលើអង្គការចាត់តាំង ។ ក្នុងសម័យនោះលោកសាក្សីមានភាពភ័យខ្លាចចំពោះការធ្វើខុសផ្សេងៗ ព្រោះការកសាងកំហុសអាចត្រូវបានគេនាំយកទៅសម្លាប់ចោល ។ បន្ទាប់ពីការបញ្ចប់សំណួរដោយលោកស្រីមេធាវីអន្តរជាតិនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី លោកប្រធានអង្គជំនុំជម្រះបានសួរយោបល់ចៅក្រមផ្សេងទៀតចំពោះការតាំងសំណួរទៅកាន់សាក្សី ។ ប៉ុន្តែដោយសារលោក លោកស្រីចៅក្រមទាំងអស់មិនមានសំណួរ ដូច្នេះលោកប្រធានបានប្រគល់វេទិកាសួរសំណួរជូនទៅក្រុមមេធាវីការពារក្តីជនជាប់ចោទ នួន ជា មុនគេ ។

**៣) ការសួរដេញដោលសាក្សី សូត្រ ទឿង ដោយមេធាវីការពារក្តី**

**ក) ការសួរដេញដោលដោយមេធាវីការពារក្តីជនជាប់ចោទ នួន ជា**


អេនទ្រូ អ៊ីនូហ្ស៊ី

លោកមេធាវី អេនទ្រូ អ៊ីនូហ្ស៊ី បានជម្រាបជូនអង្គជំនុំជម្រះថាខ្លួននឹងប្រើប្រាស់ពេលវេលាដើម្បីសួរចាប់ពីពេលនេះរហូតដល់មុនពេលសម្រាកនាថ្ងៃនេះ ពោលគឺប្រហែលមួយម៉ោងប៉ុណ្ណោះ ។ ចាប់ផ្តើមសំណួរដំបូង លោកមេធាវីបានបង្ហាញឯកសារជូនទៅសាក្សីទាក់ទងនឹងចម្លើយដែលសាក្សីបានផ្តល់ជូនចៅក្រមស៊ើបអង្កេត ។ លោកមេធាវីបានស្នើឲ្យសាក្សីអានឯកសារនេះ តែសាក្សីបានបង្ហាញនូវភាពរារែកមិនចង់អាន ។ លោក អេនទ្រូ អ៊ីនូហ្ស៊ី

បានលើកឡើងថា បើសិនសាក្សីមានភាពនឿយហត់ លោកអាច ស្នើសុំតុលាការបន្តសវនាការនេះទៅថ្ងៃស្អែកវិញ ។ ភ្លាមៗ លោកសហព្រះរាជអាជ្ញាបានលើកឡើងថា ប្រសិនបើសាក្សីមិនអាចអានបាន គួរតែលោកមេធាវីអានឲ្យសាក្សីនេះស្តាប់វិញ ដោយសារគាត់មិនអាចអានភាសាខ្មែរបានច្បាស់ លោកមេធាវីអាចប្រើប្រាស់វិធីសាស្ត្រនេះដូចភាគីមុនៗដែលធ្លាប់បានធ្វើរួចមកហើយ ។

លោកមេធាវីបានប្តូរវិធីសាស្ត្រក្នុងការសួរសាក្សី ហើយលោកបានចាប់ផ្តើមដោយការសួរនាំពីភាពចងចាំរបស់សាក្សីកាលពីពេលដែលសាក្សីធ្វើសក្ខីកម្មនៅចំពោះមុខសហចៅក្រមស៊ើបអង្កេតកាលពីថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧កន្លងទៅ ។ លោកមេធាវីបានសួរពីភាពប្រាកដប្រជាចំពោះការផ្តិតម្រាមដៃនៅគ្រប់ទំព័រនៃសក្ខីកម្ម និងការធ្វើសម្បថរបស់សាក្សីនៅពេលនោះ ។ គួរកត់សម្គាល់ថា លោកមេធាវីបានសួរសាក្សីប៉ុន្មានសំណួរប៉ុណ្ណោះទាក់ទងនឹងសក្ខីកម្មរបស់សាក្សីនៅចំពោះមុខសហចៅក្រមស៊ើបអង្កេត ។


ស៊ុន អរុណ

លោកមេធាវី ស៊ុន អរុណ បានបន្តសំណួររបស់ខ្លួនពាក់ព័ន្ធនឹងរយៈពេលដែលសាក្សីបម្រើការងារ និងអត្តចរិកកូនក្តីរបស់លោក ។ សាក្សី សូត្រ ទឿង បានឆ្លើយថា ជនជាប់ចោទ នួន ជា នៅពេលកំពុងដឹកនាំគឺជាមនុស្សល្អត្រឹមត្រូវមែន ប៉ុន្តែក្រៅពីនេះសាក្សីមិនដឹងថាយ៉ាងម៉េចនោះឡើយ ។ លោកមេធាវីបានសួរបញ្ជាក់អំពីការធ្វើសម្បថរបស់សាក្សីជាមួយសហចៅក្រមស៊ើបអង្កេត ថាតើការស្បថនោះធ្វើដោយបង្ខំ ឬដោយរបៀបណា ហើយថាតើសាក្សីមិនយល់ពីអ្វីដែលសហចៅក្រមស៊ើបអង្កេតបានអានតាមក្រដាសដែលសរសេរស្រាប់នោះឬទេ ។ លោកសាក្សីបានជម្រាបថា គឺមិនមែនជាការបង្ខំទេ តែលោកពិតជាមិនសូវយល់ពីអ្វីដែលគេអាននោះមែន ។ លោកមេធាវីបានសួរបញ្ជាក់ពីការនាំយកសំបុត្រទៅមករវាងជនជាប់ចោទ នួន ជា និង ឌុច ។ សំណួរនេះត្រូវបានលោកតំណាងសហព្រះរាជអាជ្ញាបដិសេធថាជាសំណួរច្រំដែល និងជាសំណួរនាំមុខ ។ លោកមេធាវីបានបញ្ចប់សំណួររបស់ខ្លួនត្រឹមនេះ ។

## ខ) ការសួរដេញដោលដោយក្រុមមេធាវីការពារក្តីជនជាប់ចោទ អៀង សារី


អាង ឧត្តម

លោកមេធាវី អាង ឧត្តម បានធ្វើការសួរដេញដោលសាក្សីទាក់ទងនឹងការងារសន្តិសុខ អ្នកការពារ និងនិរសាជនជាប់ចោទ នួន ជា ដោយការសួរនាំពីសភាពខ្លះៗនៅមន្ទីរ យ-១០ មន្ទីរក-១ និងមន្ទីរក-៣ ។ លោកមេធាវីបានសួរអំពីទំនាក់ទំនងរវាងសាក្សីជាមួយនឹងកូនក្តីរបស់ខ្លួន គឺជនជាប់ចោទ អៀង សារី ប៉ុន្តែសាក្សីបានបញ្ជាក់ថាខ្លួនមិនធ្លាប់មានទំនាក់ទំនងជាមួយ អៀង សារី ទេ ។ លោកមេធាវីក៏បានបញ្ចប់សំណួររបស់ខ្លួនក្នុងរយៈប្រហែល ១៥ នាទីប៉ុណ្ណោះ ។

គួរកត់សម្គាល់ថា ក្រុមមេធាវីការពារក្តីជនជាប់ចោទ ខៀវ សំផន មិនធ្វើការតាំងសំណួរទៅកាន់លោកសាក្សី សូត្រ ទឿង ទេ

ដោយលោកមេធាវី គង់ សំអុន បានជម្រាបហេតុផលជូនអង្គជំនុំជម្រះថា តាមការសង្កេតរបស់ខ្លួនសាក្សីមិនមានការផ្តល់សក្ខីកម្មទាក់ទងនឹងកូនក្តីរបស់លោកឡើយ ។

## II. សវនាការសួរដេញដោលសាក្សី សាឡុត បាន



សាឡុត បាន

លោក សាឡុត បាន គឺជាសាក្សីទីបីបន្ទាប់ពីសាក្សី កាំង ហ្គេកអ៊ាវ ហៅ ឌុច និង សូត្រ ទឿង ដែលអង្គជំនុំជម្រះបានស្តាប់សក្ខីកម្មទាក់ទងនឹងអង្គហេតុស្តីពីប្រព័ន្ធគ្រប់គ្រងរដ្ឋបាល ប្រព័ន្ធទំនាក់ទំនងការងារ និងតួនាទីរបស់ជនជាប់ចោទម្នាក់ៗ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យកន្លងមក ។ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ លោក សាឡុត បាន មានតួនាទីជាអគ្គលេខាធិការនៃក្រសួងការបរទេស ដែលមានជនជាប់ចោទ អៀង សារី ជាឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការបរទេស ។ ជាងនេះទៅទៀត លោកសាក្សីត្រូវជាក្មួយប្រុសបង្កើតរបស់ ប៉ុល ពត ដែលជាមេដឹកនាំកំពូលម្នាក់របស់បក្សកុម្មុយនីស្តកម្ពុជា ហើយបានកាន់កាប់អំណាចក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។

ដោយសារលោក សាឡុត បាន ធ្លាប់កាន់តួនាទីជាអគ្គលេខាធិការក្រសួងការបរទេស ដូច្នេះភាគីទាំងអស់បានចោទសួរសំណួរភាគច្រើនដោយផ្តោតសំខាន់លើអង្គហេតុដែលកើតមាននៅក្នុងក្រសួងការបរទេសពាក់ព័ន្ធនឹងការសម្លាប់បញ្ញាវន្តខ្មែរក៏ដូចជាបញ្ញាជនផ្សេងៗដែលត្រូវបានបញ្ជូនមកពីក្រៅប្រទេស ។ បន្ថែមលើនេះ សំណួរបានសួរផ្តោតលើអង្គហេតុដែលកើតមាននៅមន្ទីរសន្តិសុខបឹងត្របែក និងប្រាំងចំរេះ ដែលត្រូវបានដាក់ឲ្យស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងការបរទេសបន្ទាប់ពី ប៉ង់ បានបាត់ខ្លួនទៀតផង ។ មន្ទីរទាំងពីរនេះត្រូវបានគេស្គាល់ថាជាកន្លែងរក្សាទុកបញ្ញាជនសម្រាប់ធ្វើការ លត់ដំ និងសម្លាប់ ។ នៅពេលដំណើរការនីតិវិធីសួរដេញដោល លោកប្រធានអង្គជំនុំជម្រះគឺលោកចៅក្រម និល ណុន បានអនុញ្ញាតឲ្យភាគីទាំងអស់សួរតាមលំដាប់ ដែលចាប់ផ្តើមដំបូងដោយតំណាងសហព្រះរាជអាជ្ញា បន្ទាប់មកមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ហើយបន្ទាប់មកទៀតចៅក្រមនៃអង្គជំនុំជម្រះ និងចុងក្រោយបង្អស់គឺមេធាវីការពារក្តីឲ្យជនជាប់ចោទទាំងបីក្រុម ។

ក្នុងការសួរដេញដោលសាក្សី សាឡុត បានតំណាងសហព្រះរាជអាជ្ញាជាតិនិងអន្តរជាតិបានចំណាយពេលរហូតដល់ទៅពីរថ្ងៃកន្លះដើម្បីសួរអំពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការបទេស ដែលក្នុងនោះផ្តោតសំខាន់លើតួនាទីរបស់ជនជាប់ចោទ អៀង សារី និងបុគ្គលមួយចំនួនទៀតដូចជា ប៉ង់, ជាម និងតួនាទីរបស់សាក្សីផ្ទាល់ដែលមានភាពពាក់ព័ន្ធនឹងការសម្លាប់បញ្ញាជនទាំងនោះ ។ ចំពោះអង្គជំនុំជម្រះវិញ បានប្រើពេលជិតកន្លះថ្ងៃក្នុងការសួរដេញដោលសាក្សី សាឡុត បាន ពោលគឺលោកគ្រាន់តែសួរដើម្បីបញ្ជាក់ឲ្យបានច្បាស់នូវអ្វីដែលតំណាងសហព្រះរាជអាជ្ញាក៏ដូចជាមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានសួរប៉ុណ្ណោះ ។ ចំណែកមេធាវីការពារក្តីឲ្យជនជាប់ចោទទាំងបីក្រុមវិញ គឺមេធាវីការពារក្តីជនជាប់ចោទ អៀង សារី បានប្រើពេលច្រើនជាងគេគឺរហូតដល់មួយថ្ងៃពេញ ដែលក្រុមផ្សេងសួរតែកន្លះថ្ងៃប៉ុណ្ណោះ ។ ការសួរពេញមួយថ្ងៃរបស់ក្រុមមេធាវីការពារក្តីជនជាប់ចោទ អៀង សារី គឺបានចោទសួរផ្តោតសំខាន់ពីទំនាក់ទំនង និងភាពជិតស្និតរវាងសាក្សី សាឡុត បាន ជាមួយ ប៉ុល ពត និងរវាង ប៉ង់ ជាមួយ ប៉ុល ពត ដើម្បីឆ្លុះបញ្ចាំងថាតើខ្សែសង្វាក់នៃការបញ្ជូនបញ្ញាជនទៅមន្ទីរសន្តិសុខ ហើយត្រូវបានសម្លាប់នោះ គឺស្ថិតនៅក្រោមការទទួលខុសត្រូវរបស់ជនជាប់ចោទ អៀង សារី ដែរឬទេ?

### ១) ការសួរដេញដោលសាក្សី សាឡុត បាន ដោយតំណាងសហព្រះរាជអាជ្ញា

បន្ទាប់ពីអង្គជំនុំជម្រះបានប្រគល់វេទិកាក្នុងការសួរដេញ

ដោលសាក្សី សាឡុត បាន សហព្រះរាជអាជ្ញារងជាតិ គឺលោក ចាន់ គារាស្មី បានចាប់ផ្តើមសំណួរដោយផ្តោតសំខាន់អំពីប្រវត្តិសាវតារ


ចាន់ គារាស្មី

របស់សាក្សី ។ នៅក្នុងការសួរអំពីប្រវត្តិសាវតារនេះ លោកបាន សួរពាក់ព័ន្ធនឹងស្ថានភាពគ្រួសារ ការសិក្សាអប់រំ និងការចូលរួម ចលនាបដិវត្តចាប់ពីឆ្នាំ១៩៦៧ រហូតដល់បក្សកុម្មុយនីស្តកម្ពុជា ចូលកាន់កាប់ទីក្រុងភ្នំពេញក្នុងឆ្នាំ១៧៩៥ ។ ឯតំណាងសហព្រះរាជ អាជ្ញាអន្តរជាតិ គឺលោក វីនសិន ដឺវ៉ាល់ បានសួរផ្តោតជាសំខាន់អំពី អង្គហេតុទាក់ទងនឹងមន្ទីរ១០០ របស់បក្សកុម្មុយនីស្តកម្ពុជា តួនាទី របស់ជនជាប់ចោទ ខៀវ សំផន នៅមន្ទីរ៨៧០ ក្នុងនោះរាប់ បញ្ចូលទាំងមន្ទីរផ្សេងៗដែលស្ថិតក្រោមការគ្រប់គ្រងរបស់មន្ទីរ នេះ អំពីតួនាទីរបស់សាក្សី និងរចនាសម្ព័ន្ធគ្រប់គ្រងនៅក្នុងក្រសួង ការបរទេស ។ ក្រៅពីនេះ លោកបានផ្តោតលើអង្គហេតុសំខាន់ៗ មួយចំនួនទៀតដូចជាទំនាក់ទំនងរវាង ប៉ុង ជាមួយក្រសួងការ បរទេសក្នុងការបញ្ជូនបញ្ជាជនផ្សេងៗ ទៅមន្ទីរសន្តិសុខបឹងត្របែក ការបោសសម្អាតខ្មាំងបន្ទាប់ពីមានការចាប់ខ្លួន កុយ ធួន និងសិទ្ធិ ក្នុងការធ្វើសេចក្តីសម្រេចផ្សេងៗ ។

## ◆ ប្រវត្តិសាវតាររបស់សាក្សី សាឡុត បាន

លោក សាឡុត បាន ហៅ សូ ហុង មានអាយុ ៦៧ឆ្នាំ ជាអតីតយោធាម្នាក់នៅក្រសួងការពារជាតិ ថ្នាក់ឧត្តមសេនីយ៍ត្រី បច្ចុប្បន្នរស់នៅស្រុកម៉ាឡៃ ខេត្តបាត់ដំបង ។ ឪពុករបស់សាក្សី ឈ្មោះ សាឡុត សេង និងម្តាយឈ្មោះ ពុម ហឹប ។ លោកមាន ប្រពន្ធឈ្មោះ ជូ ឆេង ដែលមានកូនចំនួន៥ នាក់ និងមានបងប្អូនចំនួន ៩នាក់ ក្នុងនោះមានស្រីពីរនាក់ ។ ប្អូនប្រុសរបស់លោក សាឡុត បាន ឈ្មោះ សេង លីថេង ធ្លាប់ធ្វើទាហានរបស់កងទ័ពវៀតណាម ។ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ សេង លីថេង មានតួនាទីជាជាង ថតរូបនៅមន្ទីរក១ ហើយក៏ជាបុគ្គលម្នាក់ដែលមានការទាក់ទង ជាមួយ ប៉ុល ពត, អៀង សារី និង ខៀវ សំផន ដែរ ។ ចំណែកឪពុក ឈ្មោះ សាឡុត សេង គឺជាបងប្រុសបង្កើត របស់ សាឡុត ស ហៅ ប៉ុល ពត ។

នៅអាយុបាន៧ឆ្នាំ សាក្សីបានចាកចេញពីឪពុកម្តាយ រហូតដល់អាយុ១៥ឆ្នាំ ទើបទៅរស់នៅជាមួយ ប៉ុល ពត ហើយ បានបន្តការសិក្សារហូតដល់ថ្នាក់ទី៣នៅសង្គមចាស់ ។ បន្ទាប់ពី ប្រឡងធ្លាក់ថ្នាក់បាក់ឌុប សាក្សីបានសម្រេចចិត្តចូលរួមចលនា បដិវត្តដើម្បីប្រឆាំងនឹងពួកចក្រពត្តិអាមេរិក ដែលក្នុងពេលនោះ លោកបានប្រកបការងារជាអ្នកធាក់ស៊ីក្លូធ្វើជាកម្មករសំណង់ និង ជាគ្រូពេទ្យតិចតួច ។ ក្នុងឆ្នាំ១៩៦៦ លោកបានគេចខ្លួនពីទីក្រុង ភ្នំពេញទៅរស់នៅក្នុងខេត្តក្រចេះ ដោយសារលោកត្រូវបានចោទ ប្រកាន់ថាជាជនក្បត់ជាតិពីខាងកងទ័ព លន់ នល់ ។ គួររំឭកដែរថា លោកសាក្សីធ្លាប់ត្រូវបានកងទ័ពរបស់ លន់ នល់ ចាប់ដាក់គុកងងឹត ចំនួន១០ថ្ងៃ តែត្រូវបានព្រះបាទ នរោត្តម សីហនុ ដោះលែង ឲ្យរួចខ្លួនវិញ ។ ថ្វីដ្បិតតែលោកមានឪពុកធំឈ្មោះ សាឡុត ស្វង ធ្វើការនៅក្នុងព្រះរាជវាំងពិតមែន ប៉ុន្តែលោកបានបញ្ជាក់ថា ការដោះលែងនេះមិនមែនដោយសារតែឪពុកធំរបស់ខ្លួននោះ ឡើយ គឺដោយសារពេលនោះមានការលើកលែងអ្នកទោសជា ទូទៅដោយព្រះមហាក្សត្រ ។ បន្ទាប់ពីបានទទួលការដោះលែងភ្លាម សាក្សីបានប្តូរពីឈ្មោះ សាឡុត បាន មកជាឈ្មោះ បៀន និង ផាត ដើម្បីរស់នៅក្នុងរបបសង្គមរាស្ត្រនិយម ។ ចាប់ពីឆ្នាំ១៩៦៧ សាក្សីបានចូលរួមក្នុងចលនាតស៊ូធ្វើបដិវត្តជាមួយមេដឹកនាំខ្មែរ ក្រហមមួយចំនួននៅក្នុងព្រៃ ហើយបានជួប ប៉ុល ពត, សុន សេន, អៀង សារី, អៀង ធីរិទ្ធ និង សឿន វ៉ាស៊ី ហៅ ឌឿន ។ ក្នុងអំឡុង ពេលនោះលោក សាឡុត បាន មានតួនាទីជាអ្នកដាំបាយ ជានិរសារ ជាគ្រូពេទ្យ និងជាកងការពារផ្ទាល់របស់ ប៉ុល ពត ហើយបានបន្ត តួនាទីនេះរហូតមកដល់ឆ្នាំ១៩៧៥ ។ លោកបានបញ្ជាក់ថា គ្រួសារ

របស់ ប៉ុល ពត និង គ្រួសាររបស់ អៀង សារី គឺរស់នៅជាមួយគ្នា ក្នុងព្រៃម៉ាគី ហើយលោកស្រឡាញ់និងគោរព អៀង សារី ដូចជា ប៉ុល ពត ដែរ ។

លោក សាឡុត បាន បានបញ្ជាក់បន្ថែមថា ពេលបក្សកុម្មុយនិស្តកម្ពុជាត្រៀមវាយដណ្តើមយកទីក្រុងភ្នំពេញ ខ្លួនជាអ្នកទទួលបន្ទុកការពារ ប៉ុល ពត ដែលពេលនោះ ប៉ុល ពត បានទៅបោះទីតាំងមួយនៅឃុំពាម ដែលជាកន្លែងស្តុកទុកសម្ភារយោធាដូចជា រំសេវ និងគ្រាប់កាំភ្លើង មានចំនួនជាច្រើនគោនសម្រាប់វាយយកទីក្រុងភ្នំពេញ ។ បន្ទាប់ពីទីក្រុងភ្នំពេញត្រូវបានកាន់កាប់ដោយខ្មែរក្រហម លោកត្រូវបាន ប៉ង់ ចាត់តាំងឲ្យទៅបោសសម្អាតនៅក្រសួងការពារជាតិ និងក្រសួងការបរទេស ។ បន្ទាប់មក អៀង សារី បានចាត់តាំងលោកឲ្យបំពេញការងារជាអគ្គលេខាធិការក្រសួងការបរទេស ទទួលបន្ទុកផ្នែកអប់រំសតិអារម្មណ៍ដល់បុគ្គលិកកម្មាភិបាល និងផ្នែកការងារកសិកម្មនៅក្នុងក្រសួងនេះ ។

◆ **អំពីមន្ទីរ១០០**

បន្ទាប់ពីសហព្រះរាជអាជ្ញារងជាតិបានបញ្ចប់នូវសំណួររបស់ខ្លួន លោកតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ វីនសិនដឺវ៉ាល់ បានចាប់ផ្តើមសំណួររបស់ខ្លួនដោយផ្តោតលើមន្ទីរ១០០ ។ ក្នុងការឆ្លើយតបនឹងសំណួររបស់តំណាងសហព្រះរាជអាជ្ញា សាក្សី សាឡុត បាន បញ្ជាក់ថាមន្ទីរ១០០ មានទីតាំងនៅខេត្តរតនគិរី ហើយត្រូវបានប្តូរទីតាំងមកស្ទឹងជីនិត ស្ថិតក្នុងខេត្តកំពង់ធំវិញ ។ ក្រោយមកមន្ទីរនេះត្រូវបានប្តូរទីតាំងមកខេត្តកំពង់ចាមវិញ បន្ទាប់ពី លន់ នល់ ធ្វើរដ្ឋប្រហារទម្លាក់សម្តេច សីហនុ ពីអំណាចនៅខែមីនា ឆ្នាំ១៩៧០ ។ មន្ទីរ១០០ បានបើកដំណើរការជារៀងរាល់ថ្ងៃ និងពេញ២៤ម៉ោងក្នុងមួយថ្ងៃ ហើយមេដឹកនាំខ្មែរក្រហមធ្វើការជួបប្រជុំជាប្រចាំពាក់ព័ន្ធនឹងកិច្ចការនយោបាយ និងបញ្ហាផ្សេងៗរបស់បក្ស ។ លោក សាឡុត បាន បានបន្ថែមថា ខ្លួនធ្លាប់ឃើញវត្តមានរបស់ជនជាប់ចោទ នួន ជា ជួបប្រជុំនៅមន្ទីរ១០០ ដើម្បីពិភាក្សាពីការធ្វើបដិវត្តប្រឆាំងនឹងពួកចក្រពត្តិ ចំណែក ខៀវ សំផន ក៏ធ្លាប់មានវត្តមាននៅមន្ទីរ១០០ ដែរបន្ទាប់ពីមន្ទីរនេះត្រូវបានប្តូរមកស្ទឹងជីនិត ។ មន្ទីរនេះមានការផ្លាស់ប្តូរទីតាំងជាញឹកញាប់ដោយអនុលោមតាមទ្រឹស្តីមួយថា "ស្រោល ស្ងាត់ ចល័ត រស់រវើក" ។

◆ **តួនាទីរបស់ ខៀវ សំផន**

បន្ទាប់ពីបញ្ចប់សំណួរពាក់ព័ន្ធនឹងមន្ទីរ១០០ ដែលមានការផ្លាស់ប្តូរទីតាំងជាច្រើនកន្លែងមុនឆ្នាំ១៩៧៥ លោកតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ វីនសិន បានបន្តសួរដេញដោលសាក្សីអំពី


វីនសិន ដឺវ៉ាល់

តួនាទីរបស់ជនជាប់ចោទ ខៀវ សំផន ទាំងមុននិងក្នុងអំឡុងពេលរបបកម្ពុជាប្រជាធិបតេយ្យ ។ ក្នុងការសួរដេញដោលនេះលោក វីនសិន បានផ្តោតសំខាន់អំពីទំនាក់ទំនងរវាង ខៀវ សំផន និងមន្ទីរ៨៧០ ដែលគេស្គាល់ថាជាមន្ទីរនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជានៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ស្របពេលជាមួយគ្នានេះដែរ លោក វីនសិន តែងតែបង្ហាញឯកសារកំណត់ហេតុដែល សាឡុត បាន ធ្លាប់បានផ្តល់សក្ខីកម្មជូនចៅក្រមស៊ើបអង្កេតដើម្បីសួរបញ្ជាក់ ។

ពាក់ព័ន្ធនឹងតួនាទីរបស់ជនជាប់ចោទ ខៀវ សំផន លោក សាឡុត បាន បញ្ជាក់ថា ទាំងនៅមុននិងក្នុងអំឡុងពេលរបបកម្ពុជាប្រជាធិបតេយ្យ ខ្លួនមិនដឹងថា ខៀវ សំផន មានតួនាទី ឬទទួលបន្ទុកធ្វើកិច្ចការអ្វីឡើយ ។ ប៉ុន្តែលោកដឹងថា មុនពេលវាយបែកទីក្រុងភ្នំពេញ ជនជាប់ចោទ ខៀវ សំផន ធ្វើការនៅមន្ទីរណាសិរ្សដែលនៅទីនោះមានទាំងព្រះរាជបុត្ររបស់ព្រះមហាក្សត្រ និងឥស្សរជនមួយចំនួនធ្វើការជាមួយគ្នានៅមន្ទីរនេះ ។ ក្នុងអំឡុងពេលនោះ ខៀវ សំផន បានធ្វើដំណើរទៅមន្ទីរ១០០ ជាញឹកញាប់ ដែលការធ្វើដំណើរម្តងៗត្រូវចំណាយពេល២ថ្ងៃទើបទៅដល់ ។ សាក្សីបាន

បញ្ជាក់បន្ថែមថា នៅពេលដែលខ្លួនធ្វើជាកងការពារឲ្យ ប៉ុល ពត នៅឃុំពាម ខៀវ សំផន ក៏មានវត្តមាននៅទីនោះដែរ ដោយទទួលបន្ទុកជាអ្នកធ្វើបញ្ជីសារពើភ័ណ្ឌអំពីសម្ភារ ហើយ នួន ជា ក៏ធ្លាប់ទៅទីនោះម្តងម្កាលដែរ ។ បន្ទាប់ពីបក្សកុម្មុយនីស្តកម្ពុជា ចូលកាន់កាប់ទីក្រុងភ្នំពេញ ខៀវ សំផន និង ប៉ាង់ ធ្វើការនៅមន្ទីរ៨៧០ ដែលកាលនោះ ខៀវ សំផន ទទួលបន្ទុកកិច្ចការខាងក្នុង ចំណែក ប៉ាង់ ទទួលបន្ទុកធ្វើការនៅខាងក្រៅមន្ទីរ ។ តែទោះបីជាយ៉ាងនេះក្តី ខ្លួនមិនដឹងថា អ្នកទាំងពីរនេះទទួលបន្ទុកធ្វើកិច្ចការអ្វីខ្លះឡើយ ។ សាក្សីបានបញ្ជាក់ទៀតថា យូរៗម្តង ខៀវ សំផន ទៅក្រសួងការបរទេសស្វែងរកព័ត៌មានដើម្បីធ្វើសុន្ទរកថា ។

### ◆ អំពីមន្ទីរក-១

នៅថ្ងៃបន្ទាប់លោកតំណាងសហព្រះរាជអាជ្ញា វីនសិន បានបន្តសួរដេញដោលសាក្សីអំពីអង្គហេតុទាក់ទងនឹងមន្ទីរក-១ ដែលត្រូវបានគេស្គាល់ថាជាមន្ទីរមួយស្ថិតក្នុងរចនាសម្ព័ន្ធរបស់មន្ទីរ៨៧០ ។ មកដល់ចំណុចនេះដំបូងឡើយ សាក្សីមិនបានបង្ហាញនូវអាកប្បកិរិយាសហការជាមួយតុលាការក្នុងការផ្តល់សក្ខីកម្មឡើយ ហើយថែមទាំងបានបង្ហាញនូវការព្រួយបារម្ភថា អ្វីដែលខ្លួនបានផ្តល់ ឬនឹងត្រូវផ្តល់សក្ខីកម្មជូនអង្គជំនុំជម្រះអាចនាំឲ្យមានការដាក់ពិរុទ្ធភាពលើខ្លួនឯងទៀតផង ។ ជាក់ស្តែង នៅពេលចាប់ផ្តើមដំបូង លោក វីនសិន សួរថា តើលោក សាឡុត បាន បានទៅមន្ទីរក-១ប៉ុន្មានដង? សាក្សីបានលើកឡើងថា ខ្លួនមិនអាចឆ្លើយបានទេ ព្រោះកិច្ចការងារទាំងនេះគឺជាការសម្ងាត់ ហើយការសម្ងាត់នេះនឹងរក្សាទុករហូតអស់ជីវិត ។ ភ្លាមនោះ ប្រធានអង្គជំនុំជម្រះបញ្ជាក់ថា សាក្សីមានកាតព្វកិច្ចឆ្លើយនឹងសំណួររបស់ភាគី ប្រសិនបើការឆ្លើយសំណួរទាំងនោះនឹងមិនអាចនាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនឯង ។ លោក សាឡុត បាន បានឆ្លើយតបវិញថា សំណួរដែលខ្លួនបានឆ្លើយអស់រយៈពេលមួយថ្ងៃកន្លងមក គឺសុទ្ធតែធ្វើឲ្យវិណ្ឌកខ្លួនឯង ដូចនេះខ្លួននឹងមិនឆ្លើយទៀតឡើយ ។ ដោយសាក្សីលើកឡើងពីការព្រួយបារម្ភ ដូច្នេះប្រធានអង្គជំនុំជម្រះបញ្ជាក់បន្ថែមថា ៖

“តាមការស្តាប់របស់អង្គជំនុំជម្រះ តាំងពីដើមរហូតដល់ចប់ មិនមានសំណួរឯណាដែលនាំឲ្យលោកឆ្លើយដាក់ពិរុទ្ធភាពលើខ្លួនឯងឡើយ ពាក្យថាវិណ្ឌករមានន័យថា លោកមានកំហុសក្នុងរឿងហ្នឹង តាមអ្វីដែលយើងដំណើរការនីតិវិធីកន្លងមក គឺមិនមានសំណួរ និងចម្លើយណាមួយដាក់ពិរុទ្ធភាពលើខ្លួនលោកឡើយ ។ ដូច្នេះសូមលោកធ្វើការសហការជាមួយតុលាការបន្តទៀត ។ ដោយឡែករឿងក្តីនេះ លោកបានជ្រាបហើយនៅក្នុងបទបញ្ញត្តិនៃកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិក៏ដូចជាច្បាប់បង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដែលត្រូវបានបង្កើតឡើងដោយផ្អែកលើកិច្ចព្រមព្រៀង គឺកំណត់វិសាលភាពនៃការចោទប្រកាន់ចំពោះតែមនុស្សពីរក្រុមតែប៉ុណ្ណោះ គឺថ្នាក់ដឹកនាំជាន់ខ្ពស់របបកម្ពុជាប្រជាធិបតេយ្យ និងអ្នកទទួលខុសត្រូវខ្ពស់បំផុត ។ ដូច្នេះអ្នកផ្សេងៗទៀតនោះ គឺមិនមែនជាកម្មវត្ថុក្នុងការចោទប្រកាន់នោះឡើយ ។ ម្យ៉ាងទៀត នៅក្នុងកិច្ចដំណើរការនីតិវិធីនេះ អង្គជំនុំជម្រះបានរំឭកពីសិទ្ធិរបស់លោកហើយ ហើយថែមទាំងចាត់តាំងមេធាវីប្រឹក្សាឲ្យលោកថែមទៀត ដើម្បីឲ្យលោកមានឱកាសប្រឹក្សា ប្រសិនបើសំណួរណាសួរទៅលោកពាក់ព័ន្ធនឹងអំពើទាំងឡាយដែលមានវិនាសកម្មដែលអាចថាបង្កដោយលោក ឬលោកបានចូលរួមនោះ លោកអាចសុំពិភាក្សាជាមុន មុននឹងលោកសម្រេចថាឆ្លើយតប ឬមិនឆ្លើយតបសំណួរនោះ នេះជាសិទ្ធិដែលមានចែង ហើយយើងបានប្រាប់រួចហើយ ។ ដោយឡែកបញ្ហាផ្សេងទៀត លោកមានកាតព្វកិច្ច ឬភារកិច្ចត្រូវឆ្លើយនូវអ្វីដែលលោកបានដឹង បានឮ បានឃើញ គឺមិនមានអ្វីដែលនាំឲ្យវិណ្ឌករដល់លោកឡើយ...” ។

ទោះបីប្រធានអង្គជំនុំជម្រះបញ្ជាក់យ៉ាងច្បាស់ដូច្នេះក្តី ប៉ុន្តែសាក្សីនៅតែបង្ហាញនូវជំហរមិនសហការជាមួយតុលាការដដែល ដោយសាក្សីបានលើកឡើងថា ៖

“ខ្ញុំចូលមកធ្វើសវនាការក្នុងអង្គតុលាការនេះ ខ្ញុំបានស្បថស្បែចំពោះមុខលោកតាដំបងដែក ។ យប់មិញនេះលោកតាដំបងដែកបានប្រមូលបុព្វការីជនទាំងអស់មកប្រាប់ខ្ញុំថា ឯងកុំនិយាយអីផ្តេសផ្តាស ។ ឯងត្រូវគិតភាសាខ្មែរឲ្យបានច្បាស់ សិរីសួស្តី ពាក្យថា សិរីសួស្តី បើសំណួរណាមិនមានសិរីសួស្តីទេ ឯងមិនត្រូវស្តីរកទេ ។ នេះជាបណ្តាំរបស់លោកតាដំបងដែកប្រាប់ខ្ញុំ ។ លោកតាដំបងដែកប្រាប់ខ្ញុំទៀតថា តុលាការនេះមិនយុត្តិធម៌មួយរយភាគ

រយៈនោះទេ ល្អហើយតុលាការនេះមានខ្មែរ មានអន្តរជាតិ បើតុលាការអន្តរជាតិនៅប្រទេសផ្សេងៗ គេយកឯងទៅព្យួរកហើយ តែមានភ័ព្វសំណាងឯងមានតុលាការនៅក្នុងពេលនេះ ដែលគេហៅថា អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដែលគេហៅថាតុលាការដែលកាត់ទោសខ្មែរក្រហមឲ្យផុតពូជហើយ ។ លោកតាដំបងដែកប្រាប់ខ្ញុំអញ្ចឹង ខ្ញុំសួរទៅព្រះអង្គវិញថា ហេតុអ្វីលោកតាថាតុលាការនេះមិនយុត្តិធម៌? លោកតាថា ព្រោះតុលាការនេះអត់កាត់សំណុំរឿង០០០» ។

ដោយសារលោក សាឡុត បាន និយាយខ្លាំងៗ និងបានបង្ហាញឥរិយាបថបែបនេះ លោកប្រធានអង្គជំនុំជម្រះបានសម្រេចកាត់ផ្តាច់ការថ្លែងនេះ ហើយលោកប្រធានបានសួរបញ្ជាក់ថា «ឥឡូវលោកសាក្សីប្រកាន់ឥរិយាបថដូចម្តេច? ...អង្គជំនុំជម្រះមិនអនុញ្ញាតឲ្យលោកយកបញ្ហាយល់សប្តិជាបញ្ហាធំមករារាំងកិច្ចដំណើរការនីតិវិធីរបស់តុលាការឡើយ លោកបានស្បថរួចហើយ ហើយសម្បថនេះមានចែងក្នុងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា...» ។ ជាលទ្ធផលសាក្សីបានបន្ទន់ឥរិយាបថរបស់ខ្លួន ហើយបានឆ្លើយតបនឹងអង្គជំនុំជម្រះវិញថា ខ្លួននឹងសហការជាមួយតុលាការដូចដើម តែស្នើសុំថាចម្លើយដែលខ្លួនបានផ្តល់ គឺមិនត្រូវចោទប្រកាន់មកលើខ្លួនឡើយ ។ បន្ទាប់ពីបញ្ហានេះត្រូវបានដោះស្រាយរួច លោកតំណាងសហព្រះរាជអាជ្ញា វីនសិន បានបន្តសួរសំណួរមួយចំនួនទាក់ទងនឹងមន្ទីរក-១ ។

ជាការឆ្លើយតប សាក្សី បានបញ្ជាក់ថា ខ្លួនធ្លាប់ទៅមន្ទីរក-១ ជាច្រើនលើក ដោយសារប្រពន្ធរបស់ខ្លួនឈ្មោះ ជូ ឆេង ធ្វើការជាអ្នកដាំបាយនៅទីនោះ ហើយខ្លួនក៏ធ្លាប់បានយកសំបុត្រជាច្រើនរបស់ អៀង សារី ទៅឲ្យមន្ទីរនេះដែរ ។ រាល់ការចេញចូលមន្ទីរនេះ ខ្លួនមិនចាំបាច់មានសំបុត្រអនុញ្ញាតឡើយ ហើយខ្លួនមានសិទ្ធិចេញសំបុត្រអនុញ្ញាតឲ្យអ្នកនៅក្រោមបង្គាប់របស់ខ្លួនក្នុងករណីមានភារកិច្ចត្រូវចេញចូលមន្ទីរនេះ ។ លោក សាឡុត បាន បានបន្ថែមថា នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ជាទូទៅមេដឹកនាំធំៗរបស់បក្សកុម្មុយនីស្តកម្ពុជាជួបប្រជុំគ្នានៅមន្ទីរក-១ ហើយខ្លួនធ្លាប់បានឃើញ ប៉ុល ពត, នួន ជា និង អៀង សារី ប្រជុំជាមួយគ្នានៅទីនោះ ប៉ុន្តែមិនដឹងថាអ្នកទាំងនោះប្រជុំអំពីបញ្ហាអ្វីឡើយ ។

## ◆ ក្រសួងការបរទេសនៃរបបកម្ពុជាប្រជាធិបតេយ្យ

ក្នុងការសួរដេញដោលសាក្សី សាឡុត បាន អំពីអង្គហេតុទាក់ទងនឹងក្រសួងការបរទេស លោក វីនសិន បានសួរផ្តោតលើការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការបរទេស តួនាទីរបស់ អៀង សារី, សាឡុត បាន, ប៉ង់ និងបុគ្គលមួយចំនួនទៀត ដែលមានការពាក់ព័ន្ធនឹងការនាំយកបញ្ញាជនទៅសម្លាប់នៅមន្ទីរសន្តិសុខបឹងត្របែក និងប្រាំងចំរេះ ។

ពាក់ព័ន្ធនឹងការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការបរទេសលោក សាឡុត បាន បញ្ជាក់ថា ក្រសួងការបរទេស ដែលជាទូទៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យត្រូវបានគេស្គាល់ថាជាមន្ទីរ ប-១ គឺមានទីតាំងនៅចំទីស្តីការរបស់នាយករដ្ឋមន្ត្រីនាពេលបច្ចុប្បន្ននេះ ។ ក្រសួងនេះត្រូវបានដឹកនាំ និងគ្រប់គ្រងដោយ អៀង សារី ដែលជាអ្នកទទួលបន្ទុកផ្នែកកិច្ចការបរទេស ។ ក្រសួងនេះត្រូវបានបែងចែកជាពីរផ្នែកធំៗ គឺមួយផ្នែកទទួលបន្ទុកគ្រប់គ្រង និងអប់រំខាងសតិអារម្មណ៍ដល់កម្មាភិបាល និងបុគ្គលិក ដោយរួមបញ្ចូលទាំងការផ្សារដាំដុះនៅក្នុងក្រសួង ចំណែកមួយផ្នែកទៀតទទួលបន្ទុកគ្រប់គ្រង ខាងបញ្ញាជន និងកិច្ចការបរទេសដែលមាន អៀង សារី ជាអ្នកដឹកនាំ ។ ផ្នែកធំៗទាំងពីរនេះ មានផ្នែកតូចៗជាច្រើនទៀតដូចជាផ្នែកទទួលពិធីការ ផ្នែកគ្រប់គ្រងទីផ្សាររបស់រដ្ឋ ផ្នែកពាណិជ្ជកម្ម ហើយបន្ទាប់ពី ប៉ង់ និង កុយ ធួន ត្រូវបានចាប់ខ្លួន មន្ទីរសន្តិសុខបឹងត្របែក និងប្រាំងចំរេះ ក៏ត្រូវបានដាក់ឲ្យស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងការបរទេស ។ ផ្នែកគ្រប់គ្រងទីផ្សាររបស់រដ្ឋមានបុគ្គលិកប្រមាណពី១៥០ទៅ៣០០នាក់ ហើយគ្រប់គ្រងរាល់ផលិតផលកសិកម្ម សាច់សត្វ ឧស្សាហកម្ម ។ល។ ដែលបានផលិតនៅទូទាំងប្រទេស ។ ក្រៅពីនេះ ក្រសួងការបរទេសទទួលបន្ទុកគ្រប់គ្រង និងផ្តល់ព័ត៌មានផ្សេងៗដល់ស្ថានទូត និងស្ថានកុងស៊ុលរបស់ខ្លួនដែលមានទីតាំងនៅប្រទេសផ្សេងៗ ។ សាក្សីបានបញ្ជាក់ជូនអង្គជំនុំជម្រះថា ខ្លួនមិនចាំថាក្រសួងការបរទេសមានការិយាល័យទទួលបន្ទុកខាងព្រលានយន្តហោះដែរឬយ៉ាងណានោះទេ តែលោកចាំច្បាស់ថាក្រសួងនេះទទួលរក្សាទុកបុគ្គលទាំងឡាយដែលត្រូវបានបញ្ជូនមកពីក្នុងនិងក្រៅប្រទេស ដែល ប៉ង់ ចាត់ទុកថាមានប្រវត្តិរូបមិនច្បាស់លាស់ មុននឹងបញ្ជូន

ទៅមន្ទីរសន្តិសុខដើម្បីស៊ើបអង្កេត ។

ទាក់ទងនឹងតួនាទីរបស់ជនជាប់ចោទ អៀង សារី នៅក្នុងក្រសួងការបរទេសសាក្សី សាឡុត បាន បានបញ្ជាក់ថា អៀង សារី គឺជាឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការបរទេស ។ ដូច្នេះរាល់កិច្ចការទាំងអស់នៅក្នុងក្រសួងត្រូវមានការអនុញ្ញាតពី អៀង សារី ទើបអាចធ្វើបាន ។ ក្នុងនាមជាអគ្គលេខាធិការ ខ្លួនបានជួបប្រជុំ និងរាយការណ៍ជារៀងរាល់ថ្ងៃនៅពេលដែល អៀង សារី មកធ្វើការនៅក្រសួង ។ ពេលមានការប្រជុំធំៗក្នុងក្រសួងការបរទេស អៀង សារី ធ្វើជាអធិបតីនៃកិច្ចប្រជុំ ហើយប្រធានផ្នែកនីមួយៗបានរាយការណ៍អំពីស្ថានភាពដែលបានកើតឡើងក្នុងផ្នែករបស់ខ្លួន រួមទាំងបញ្ហាសន្តិសុខក្នុងក្រសួងដែរ ។ ក្រៅពីនេះ អៀង សារី ក៏ធ្លាប់ធ្វើជាធិបតីនៃកិច្ចប្រជុំធ្វើជីវទស្សន៍ (ស្វ័យទិតៀន) ដែលអ្នកចូលរួមត្រូវលើកឡើងពីគុណវិបត្តិរបស់ខ្លួនឯង ឬបុគ្គលណាម្នាក់ដែលបានប្រព្រឹត្តផ្ទុយនឹងក្រមសីលធម៌ទាំង១២ប្រការដែលបក្សបានកំណត់ ហើយជាទូទៅក៏មានការលើកឡើងពីសត្រូវខាងក្នុងនិងសត្រូវខាងក្រៅរបស់បក្សជូនអង្គប្រជុំទាំងមូលឲ្យបានដឹង ហើយចុងក្រោយ អៀង សារី ជាអ្នកធ្វើការបូកសរុបពីគុណសម្បត្តិ និងគុណវិបត្តិដែលបុគ្គលនោះមាន ។ លោក សាឡុត បាន បានបញ្ជាក់បន្ថែមទៀតថា ក្នុងករណី អៀង សារី មិននៅនោះ មិនមានកិច្ចប្រជុំធំៗនៅក្នុងក្រសួងការបរទេសឡើយ ពោលគឺមានតែកិច្ចប្រជុំតាមផ្នែកតូចៗ ហើយកិច្ចប្រជុំទាំងនោះ គឺមិនមានការសម្រេចធំដុំឡើយ ។ ប៉ុន្តែ អៀង សារី បានប្រាប់លោក សាឡុត បាន ថា ក្នុងករណី ខ្លួន (អៀង សារី) មិននៅ ហើយ ប៉ង់ ត្រូវការអ្វី គឺត្រូវអនុញ្ញាតាមសំណើរបស់ ប៉ង់ ។ ចុងក្រោយ លោកតំណាងសហព្រះរាជអាជ្ញា វីនសិន ដាក់បង្ហាញឯកសារកំណត់ហេតុដែល លោក សាឡុត បាន បានផ្តល់ចម្លើយជូនចៅក្រមស៊ើបអង្កេតថា អៀង សារី គឺជាសមាជិករបស់គណៈកម្មាធិការមជ្ឈិម និងគណៈកម្មាធិការអចិន្ត្រៃយ៍នៃបក្សកុម្មុយនីស្តកម្ពុជា ហើយចម្លើយនេះនៅតែត្រូវបានលោក សាឡុត បាន ទទួលស្គាល់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងដដែល ។

បន្ទាប់ពីលោក វីនសិន បញ្ចប់សំណួររបស់ខ្លួនពាក់ព័ន្ធនឹងតួនាទីរបស់ជនជាប់ចោទ អៀង សារី លោកបន្តសួរអំពីតួនាទីរបស់លោក សាឡុត បាន ដែលធ្លាប់អនុវត្តការងារនៅក្រសួងការបរទេស ។ ជាការឆ្លើយតប សាក្សីបានបញ្ជាក់ថា ខ្លួនត្រូវបានចាត់តាំងឲ្យកាន់តួនាទីជាអគ្គលេខាធិការក្រសួងការបរទេស បន្ទាប់ពី អៀង សារី វិលចូលមកស្រុកខ្មែរវិញ ។ មូលហេតុដែល អៀង សារី ចាត់តាំងឲ្យខ្លួនកាន់តួនាទីនេះ គឺដោយសារ អៀង សារី ស្រឡាញ់ និងជឿទុកចិត្តមកលើខ្លួន ។ ក្នុងឋានៈជាអគ្គលេខាធិការ ខ្លួនទទួលបន្ទុកគ្រប់គ្រងបុគ្គលិកក្នុងក្រសួង ជាពិសេសផ្តោតលើកម្មាភិបាល និងបុគ្គលិកដែលត្រូវបានជ្រើសរើសចេញពីវណ្ណៈកសិករ និងកម្មករ ហើយធ្វើការសម្របសម្រួលមិនឲ្យមានទំនាស់ជាមួយបុគ្គលិកដែលជាបញ្ញាជនឡើយ ។ ក្នុងការគ្រប់គ្រងនេះ ខ្លួនទទួលបន្ទុកអប់រំខាងផ្នែកសតិអារម្មណ៍ និងការងារដាំដុះនៅក្នុងក្រសួង ។ ក្រៅពីនេះ ខ្លួនទទួលបន្ទុកគ្រប់គ្រង និងបង្ហាត់បង្រៀនកូនកម្មាភិបាលជាង១០០០នាក់ថែមទៀត ដើម្បីឲ្យចេះកិច្ចការនៅក្រសួងការបរទេស ។ គួររំឭកថា លោកតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ វីនសិន បានបង្ហាញឯកសារកំណត់ហេតុដែលសាក្សី សាឡុត បាន បានផ្តល់សក្ខីកម្មជូនចៅក្រមស៊ើបអង្កេតថា ខ្លួនជាអ្នកទទួលបន្ទុកគ្រប់គ្រងលើបញ្ញាជន និងបញ្ញាវន្ត ដែលត្រូវបានបញ្ជូនមកពីប្រទេសបារាំង និងសហរដ្ឋអាមេរិក ហើយក្រៅពីនេះក៏ទទួលបន្ទុកការងារសន្តិសុខនៅក្នុងក្រសួងដែរ ។ សាឡុត បាន បញ្ជាក់បន្ថែមថា បន្ទាប់ពី កុយ ធួន ត្រូវបានចាប់ខ្លួន លោកត្រូវបានចាត់តាំងឲ្យទៅគ្រប់គ្រងមន្ទីរប្រាំងចំរេះ ដែលទទួលបន្ទុកផ្នែកដាំដុះ ហើយការងារសំខាន់នៅពេលនោះ គឺអប់រំផ្នែកសតិអារម្មណ៍ដល់កម្មាភិបាលដែលធ្វើការនៅទីនោះ ។ លោក សាឡុត បាន បំភ្លឺជូនអង្គជំនុំជម្រះថា ចម្លើយសារភាពរបស់ កុយ ធួន ដែលជាអតីតប្រធានភូមិភាគ៣០៤ ត្រូវបានមន្ទីរសន្តិសុខស-២១ ផ្ញើឲ្យក្រសួងការបរទេស ហើយត្រូវបានជនជាប់ចោទ អៀង សារី យកមកអាននៅក្នុងកិច្ចប្រជុំដែលមានការចូលរួមពីសំណាក់កម្មាភិបាលទាំងអស់របស់ក្រសួងដើម្បីផ្តល់ជា ព័ត៌មាន ។ បន្ទាប់ពីបញ្ចប់ការអានរបស់ អៀង សារី គឺមានការស្នើដល់កម្មាភិបាលដែលធ្លាប់មានភាពពាក់ព័ន្ធជាមួយ កុយ ធួន ឲ្យនិយាយរៀបរាប់នូវអំពើដែលធ្លាប់ធ្វើជាមួយ កុយ ធួន ឬបុគ្គលណាម្នាក់ដែលមានការពាក់ព័ន្ធដើម្បីអប់រំកែប្រែ ។ លោក សាឡុត បាន បានញ្ជាក់ថែមទៀតថា ខ្លួនក៏ធ្លាប់



*អៀង សារី (រូបខាងស្តាំ) ព្រមទាំងកម្មាភិបាលខ្មែរក្រហមដទៃទៀតកំពុងវាដៃលាគណៈប្រតិភូមកពីទីម័រខាងកើត ។ ទីតាំងក្នុងរូបថតនេះ គឺជាមន្ទីរប-១ ឬក្រសួងការបរទេសនៃរបបកម្ពុជាប្រជាធិបតេយ្យ ហើយសម័យក្រោយមក អគារនេះត្រូវបានប្រើប្រាស់ជាទីស្តីការគណៈរដ្ឋមន្ត្រី រហូតដល់ឆ្នាំ២០០៦ នៅពេលដែលអគារនេះត្រូវបានបំផ្លាញចោល ដើម្បីសាងសង់អគារទីស្តីការគណៈរដ្ឋមន្ត្រីថ្មី ក្រោមជំនួយរបស់រដ្ឋាភិបាលចិន ។*

កោះហៅកម្មាភិបាលដែលធ្វើការនៅប្រាំងចំរេះមកសួរនាំអំពីការជាប់ពាក់ព័ន្ធជាមួយ កុយ ធួន ក្នុងគោលបំណងអប់រំឲ្យកសាងខ្លួនឡើងវិញ ហើយបន្ទាប់មកលោកបានរាយការណ៍អំពីកិច្ចប្រជុំអប់រំនេះទៅជនជាប់ចោទ អៀង សារី ឲ្យបានដឹងទៀតផង ។

ក្នុងឋានៈជាអគ្គលេខាធិការក្រសួងការបរទេស សាក្សីធ្លាប់បានជូនអ្នកកាសែតរបស់សហរដ្ឋអាមេរិក និងជប៉ុន ទៅធ្វើទស្សនកិច្ចនៅតាមមូលដ្ឋានបាននាំគណៈប្រតិភូប្រទេសឡាវ ទៅធ្វើទស្សនកិច្ចនៅកំពង់សោម និងនាំគណៈប្រតិភូប្រទេសប៊ែលហ្ស៊ិក ទៅជួបពិភាក្សាជាមួយ ប៉ុល ពត ។ ពាក់ព័ន្ធនឹងការជូនគណៈប្រតិភូទៅធ្វើទស្សនកិច្ចនេះ លោក វីនសិន បង្ហាញរូបថតមួយចំនួនដើម្បីឲ្យសាក្សីបញ្ជាក់ពីវត្តមានរបស់មេដឹកនាំខ្មែរក្រហមដែលបានចូលរួមទទួលគណៈប្រតិភូទាំងនោះ ។ លោក សាឡុត បាន ក៏បានញ្ជាក់ផងដែរថារូបថតទាំងនោះមានវត្តមានរបស់ អៀង សារី, នួន ជា, ខៀវ សំផន, អៀង ធិរិទ្ធ, យន់ យ៉ាត និងមានអ្នកផ្សេងៗទៀតដែលខ្លួនមិនស្គាល់ ។ ពេលជូនគណៈប្រតិភូបរទេសទៅធ្វើទស្សនកិច្ចនៅតាមមូលដ្ឋាន ខ្លួនបានឃើញប្រជាជនមានការអត់ឃ្លាន ហើយបានរាយការណ៍ឲ្យ អៀង សារី បន្ទាប់មក អៀង សារី រាយការណ៍បន្តឲ្យថ្នាក់មជ្ឈិម ។ ក្រៅពីការជូនដំណើរគណៈប្រតិភូបរទេស ខ្លួនធ្លាប់បានជូនដំណើរ អៀង សារី ទៅចូលរួមកិច្ចប្រជុំនៅអង្គការសហប្រជាជាតិ ហើយពេលត្រឡប់មកវិញបានឈាងចូលប្រទេសបារាំងដើម្បីជួបបញ្ញវន្តដែលរស់នៅទីក្រុងប៉ារីស ហើយពេលនោះ អៀង សារី បានទៅជួបផ្ទាល់ជាមួយបញ្ញវន្តទាំងនោះ ។ ក្រោយមកមានបញ្ញាជន និងបញ្ញវន្តជាច្រើនរយនាក់បានវិលត្រឡប់មកស្រុកខ្មែរវិញ ។

ចំពោះតួនាទីរបស់ ប៉ាង់ វិញ សាក្សី សាឡុត បាន បានផ្តល់សក្ខីកម្មដោយភាពស្រពិចស្រពិលថា “ប៉ាង់ ប្រហែលជាសមាជិករបស់គណៈមជ្ឈិម តែមិនដឹងថាជាសមាជិករបស់គណៈអចិន្ត្រៃយ៍ដែរឬអត់ ហើយក្នុងក្របខណ្ឌការងារ ប៉ាង់ ក៏ប្រហែលជាស្ថិតនៅក្រោមឱវាទរបស់គណៈអចិន្ត្រៃយ៍” ។ តែទោះបីជាយ៉ាងណាក៏ដោយសាក្សីបានបញ្ជាក់យ៉ាងច្បាស់ថា ជានិច្ចជាកាល ប៉ាង់ តែងតែនាំកម្មាភិបាលនៅភូមិភាគ ឬតំបន់ដែលមានប្រវត្តិរូបមិនច្បាស់លាស់មកផ្ញើនៅក្រសួងការបរទេស មុននឹងបញ្ជូនទៅមន្ទីរសន្តិសុខដើម្បីស៊ើបអង្កេត ។ រាល់ពេល ប៉ាង់ យកមនុស្សមកផ្ញើ ខ្លួនតែងតែរាយការណ៍ ជូន អៀង សារី ឲ្យបានដឹង ។ ក្រោយមកមនុស្សទាំងនោះត្រូវបាន ប៉ាង់ ឬអ្នកនៅក្រោមបង្គាប់របស់ ប៉ាង់ យកទៅវិញ តែមិនដឹងថាយកទៅទីណា ឬយកទៅធ្វើអ្វីឡើយ តែអ្នកទាំងនោះមិនដែលបានវិលត្រឡប់មកវិញទេ ។ សាក្សីក៏បានទទួលស្គាល់ឯកសារកំណត់ហេតុដែលខ្លួនធ្លាប់បានផ្តល់ចម្លើយជូនចៅក្រមស៊ើបអង្កេតថា ប៉ាង់ មានទំនាក់ទំនងផ្ទាល់ជាមួយ អៀង សារី ក្នុងការនាំយកបុគ្គលមួយចំនួនចេញពីក្រសួងការបរទេសដែរ ។ ក្នុងឯកសារនោះដែរ សាក្សីធ្លាប់បានបញ្ជាក់ថា “ខ្ញុំបានដឹងថាមានបុគ្គលិករបស់ក្រសួងបានបាត់ខ្លួន តែមិនដឹងថាគេយកទៅណាអ្នកដែលមកយកគឺ ប៉ាង់ ហើយការបាត់នេះគឺ អៀង សារី ក៏បានដឹងដែរ...” ។ លោក សាឡុត បាន បានញ្ជាក់ថា បុគ្គលិករបស់ក្រសួងការបរទេសជាច្រើនត្រូវបាន ប៉ាង់ ឬអ្នកនៅក្រោមបង្គាប់របស់ ប៉ាង់ នាំយកទៅដោយប្រាប់ថាយកទៅឲ្យរៀនសូត្រ តែជាលទ្ធផលអ្នកទាំងនោះមិនដែលវិលមកវិញឡើយ ។ ពេល ប៉ាង់ មកយកមនុស្សចេញពីក្រសួងការបរទេស គឺមិនចាំបាច់មានសំបុត្រអនុញ្ញាតឡើយ តែបើអ្នកនៅក្រោមបង្គាប់មកយក គឺត្រូវមានសំបុត្រដោយមានចុះហត្ថលេខារបស់ ប៉ាង់ ។ បន្ទាប់ពីមានការនាំយកមនុស្សចេញទៅជាច្រើន អៀង សារី បានកោះប្រជុំកម្មាភិបាលនៅក្នុងក្រសួងរបស់ខ្លួនមកធ្វើការណែនាំដើម្បីកុំឲ្យមានការភ័យខ្លាច ។ សាក្សីបានបញ្ជាក់ថា ប៉ាង់ គឺជាមនុស្សម្នាក់ដែលមានអំណាច ពោលគឺអាចចេញចូលពីក្រសួងមួយទៅក្រសួងទៀតបាន ឬទៅគ្រប់ទីកន្លែងនៅទូទាំងប្រទេស ដោយមិនចាំបាច់មានលិខិតអនុញ្ញាត ប៉ុន្តែខ្លួនមិនដឹងថា ប៉ាង់ ស្ថិតនៅក្រោមការបង្គាប់បញ្ជារបស់បុគ្គលណាឡើយ ។

ពាក់ព័ន្ធនឹងបញ្ញាជន និងបញ្ញវន្តដែលត្រូវបានបញ្ជូនមកពីបរទេសលោក សាឡុត បាន បញ្ជាក់ថាពេលដែលអ្នកទាំងនោះមកដល់ព្រលានយន្តហោះពោធិ៍ចិនតុង ក្រុមយោធាដែលប្រចាំការនៅទីនោះបានចាប់បញ្ជូនមកឲ្យ ប៉ាង់ នៅទីក្រុងភ្នំពេញ ហើយ ប៉ាង់ បញ្ជូនបន្តទៅមន្ទីរឃុំឃាំងនៅបឹងត្របែក រីឯសម្ភារផ្សេងៗរបស់អ្នកទាំងនោះត្រូវបានបញ្ជូនទៅទុកក្រសួងការបរទេសទាំងអស់ ។

### ◆ *កំណត់ហេតុដោយដៃរបស់សាក្សី សាឡុត បាន នៅក្នុងរបបខ្មែរក្រហម*

បន្ទាប់ពីចោទសំណួរជាច្រើនពាក់ព័ន្ធនឹងក្រសួងការបរទេស លោក វីនសិន ដាក់បង្ហាញឯកសារមួយដែលមានកម្រាស់ជាង ២០០ទំព័រ ហើយលោកបានពិពណ៌នាថា ជាកំណត់ដៃរបស់ សាឡុត បាន កត់ត្រានូវរឿងរ៉ាវដែលបានកើតឡើងនៅក្នុងក្រសួងការបរទេស ។ បន្ទាប់ពីទទួលបានឯកសារមកមើល សាឡុត បាន បញ្ជាក់ថា ខ្លួនមិនដែលបានឃើញឯកសារនេះពីមុនឡើយ ហើយខ្លួនក៏មិនស្គាល់ឯកសារនេះដែរ ។ លោក វីនសិន អះអាងថា ឯកសារនេះត្រូវបានចៅក្រមស៊ើបអង្កេតយកមកបង្ហាញ និងសួរ សាឡុត បាន រួចហើយ ។ ដើម្បីគាំទ្រនូវអំណះអំណាងរបស់ខ្លួន លោក វីនសិន បានដកស្រង់យកចម្លើយមួយចំនួនពាក់ព័ន្ធនឹងការកំណត់ខ្មាំងអំពីសមាជជាតិ អំពីការដាំដុះចំនួនមនុស្សនៅប្រាំងចំរេះ ដែល សាឡុត បាន ធ្លាប់បានផ្តល់ចម្លើយជូនចៅក្រមស៊ើបអង្កេតដែល ចម្លើយទាំងនេះអាចបញ្ជាក់ថា ពេល សួរសាក្សី សាឡុត បាន គឺចៅក្រមស៊ើបអង្កេតបានដកស្រង់ខ្លឹមសារនៃកំណត់ហេតុនេះមកសួររួចហើយ ហើយថែមទាំងបានប្រាប់ពីអត្តសញ្ញាណរបស់ឯកសារនេះដែរ ។ ដូចនេះអាចបញ្ជាក់ថា ឯកសារនេះបានបង្ហាញនៅចំពោះមុខសាក្សីរួចហើយ ។ ប៉ុន្តែទោះបីជាយ៉ាងណាសាក្សី សាឡុត បាន នៅតែបដិសេធថា ខ្លួនមិនស្គាល់ឯកសារនេះដដែល ដោយអះអាងថា ពេលចៅក្រមស៊ើបអង្កេតមកសួរ គឺបានយកឯកសារតែ២ឬ៣សន្លឹកប៉ុណ្ណោះមកបង្ហាញលោក ។ ដោយសារសាក្សីបានប្រកាន់ជំហរបែបនេះ លោកមេធាវី សុន អរុណ បានលើកឡើងថា “សាក្សីបញ្ជាក់ថាខ្លួនមិនបានស្គាល់ឯកសារនេះដូច្នេះសហព្រះរាជអាជ្ញា ឬមេធាវីដើមបណ្តឹងរដ្ឋប្បវេណី មិនអាចបង្ខំឲ្យសាក្សីទទួលស្គាល់ឯកសារនេះឡើយ” ។ ភ្លាមនោះ ប្រធានអង្គជំនុំជម្រះបញ្ជាក់ថា “ទោះបីសាក្សីបញ្ជាក់ថាខ្លួនមិនដែលឃើញឯកសារនេះទាំងមូល តែភាគីអាចសួរសំណួរពាក់ព័ន្ធដែលអាចបង្ហាញថា ចៅក្រមស៊ើបអង្កេតបាន បង្ហាញឯកសារនេះទាំងមូល ឬមួយផ្នែកដល់សាក្សីនៅពេលសួរយកចម្លើយ” ។ ម្យ៉ាងវិញទៀត សាក្សីអាចមានការភ្លេចចំពោះឯកសារនេះ ព្រោះតាមចម្លើយដែលសាក្សីបានផ្តល់នៅដំណាក់កាលស៊ើបអង្កេតអាចបញ្ជាក់ថាឯកសារនេះត្រូវបានបង្ហាញដល់សាក្សីរួចហើយ ដូច្នេះភាគីអាចសួរសំណួរទូទៅពាក់ព័ន្ធនឹងឯកសារនេះបាន ។

បន្ទាប់ពីប្រធានអង្គជំនុំជម្រះអនុញ្ញាតដូច្នេះ លោក វីនសិន បានបន្តសួរសាក្សី សាឡុត បាន ពាក់ព័ន្ធនឹងការធ្វើមហាសន្និបាត និងការចាប់ខ្លួនបុគ្គលិកនៅក្រសួងការបរទេស ។ សាក្សីបានបញ្ជាក់ថាក្រសួងការបរទេសធ្វើមហាសន្និបាតជាប្រចាំក្រោមអធិបតីរបស់ អៀង សារី ហើយពេលធ្វើម្តងៗ មានរយៈពេលជួនកាល១សប្តាហ៍ ឬជួនកាល១ខែទើបចប់ ពោលគឺអាស្រ័យលើសភាពការណ៍ជាក់ស្តែង ។ ពាក់ព័ន្ធនឹងការចាប់បុគ្គលិកនៅក្រសួងការបរទេស សាក្សី សាឡុត បាន បានលើកឡើងថានៅខែកក្កដា ឆ្នាំ១៩៧៦ មានការចាប់ខ្លួនកម្មាភិបាលរបស់ក្រសួងក្នុងទ្រង់ទ្រាយធំ តែការចាប់នេះមិនមែនផ្តោតតែក្រសួងការបរទេសឡើយ ពោលគឺការចាប់ក្នុងទ្រង់ទ្រាយធំនេះគឺធ្វើឡើងទូទាំងប្រទេស ។

## ២) ការសួរដេញដោលដោយមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីចំពោះសាក្សី សាឡុត បាន

បន្ទាប់ពីសហព្រះរាជអាជ្ញាបានបញ្ចប់ការសួរដេញដោលលើសាក្សី សាឡុត បាន នៅរសៀលថ្ងៃទី២៥ ខែមេសា ឆ្នាំ ២០១២ អង្គជំនុំជម្រះបានប្រគល់វេទិកាជូនក្រុមមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីដើម្បីសួរដេញដោលចំពោះសាក្សី ។ មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីពីររូបគឺលោកស្រីមេធាវី ចេត វ៉ាន់លី និងលោកស្រីមេធាវី អេលីហ្សាប៊ែត ហ្សូលី រ៉ាបីសាន់ជ្រាតាណា បានសាកសួរសាក្សី សាឡុត បាន ដោយផ្តោតសំខាន់លើការចាប់ខ្លួនបញ្ញាជន ដែល វិលត្រឡប់ពីបរទេសតាមការអំពាវនាវរបស់មេដឹកនាំនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ ជាដំបូងអង្គជំនុំជម្រះបានប្រគល់វេទិកាជូនលោកស្រីមេធាវី ចេត វ៉ាន់លី ដើម្បីចោទសួរលើសាក្សី ។

### ក) ការសួរដេញដោលដោយមេធាវី ចេត វ៉ាន់លី

ចាប់ផ្តើមសំណួរដំបូង លោកស្រីមេធាវីបានសួរនាំសាក្សីអំពីមូលហេតុនៃការដកហូតលិខិតឆ្លងដែនរបស់បញ្ញាជនដែលមកពីបរទេស ។ លោកសាក្សី សាឡុត បាន បានឆ្លើយតបថា ពេលនោះមិនមែនខាងក្រសួងការបរទេសជាអ្នកដកហូតទេ គឺខាងកងទ័ពនៅព្រលានយន្តហោះជាអ្នកដកហូតលិខិតឆ្លងដែនពីបញ្ញាជនទាំង

នោះ ។ ចំណែកលោកទទួលយកឥវ៉ាន់ និងវ៉ាលី មកទុកនៅក្រសួងការបរទេសប៉ុណ្ណោះ ។ បន្ទាប់មកអ្នកទាំងនោះមិនត្រូវបានបញ្ជូនមកក្រសួងការបរទេសទេ គឺ ប៉ង់ ជាអ្នកនាំយកទៅ ដែលនៅពេលនោះលោកមិនបានដឹងថាអ្នកទាំងនោះត្រូវបញ្ជូនទៅទីណាទេ ។ ប៉ុន្តែនៅឆ្នាំ១៩៧៩ ក្រោយពេលវៀតណាមចូលមកដល់កម្ពុជា ទើបលោកដឹងថាបញ្ញាជនទាំងនោះត្រូវបានបញ្ជូនទៅមន្ទីរឃុំឃាំងបឹងត្របែក នៅទីក្រុងភ្នំពេញ ។ បញ្ញាជនទាំងនោះត្រឡប់មកពីប្រទេសបារាំង និងអាមេរិក ហើយក្នុងចំណោមអ្នកដែលត្រឡប់មកកម្ពុជាក្នុងអំឡុងឆ្នាំ១៩៧៩ មានអ្នកការទូតខ្លះដែរដែលលោកស្គាល់ច្បាស់គឺ លោក តូច ខាំឌឿន និងលោក ហោ ណាំហុង ។ ប៉ុន្តែលោក ហួត សម្បត្តិ និង នរោត្តម ភូរីស្សារ៉ា សាក្សីមិនបានស្គាល់មុខទេ គឺធ្លាប់ឮតែឈ្មោះប៉ុណ្ណោះ ។ លោកសាក្សីបានទទួលស្គាល់ថានៅក្នុងនោះក៏មានឈ្មោះលោក គាត ឈន់ ដែលក្រោយមកធ្វើការជាមួយខ្លួនអំឡុងពេលសាក្សីនៅធ្វើការក្នុងក្រសួងការបរទេសទៀតផង និងលោក អ៊ិន សុកាន ។ លោកបានអះអាងថាធ្លាប់បានឃើញជនជាប់ចោទ អៀង សារី នៅក្នុងក្របខ័ណ្ឌក្រសួងការបរទេសបានធ្វើការណែនាំ អប់រំ ពង្រឹងសតិអារម្មណ៍អំពីគោលការណ៍រណសិរ្ស ប៉ុន្តែនៅក្រៅក្របខ័ណ្ឌក្រសួងនេះ លោកមិនដែលឃើញ អៀង សារី ចុះទៅអប់រំទេ ។ នៅក្នុងការអប់រំនោះ គឺបាននិយាយអំពីការលំបាកនៃការធ្វើបដិវត្ត ដែលត្រូវការតស៊ូស៊ិតស្វាញ ហើយពេលខ្លះត្រូវលះបង់ជីវិតទៀតផង ។ អៀង សារី ធ្លាប់ទៅបរទេសជាញឹកញាប់ដើម្បីចូលរួមនៅក្នុងកិច្ចប្រជុំមិនចូលបក្សសម្ព័ន្ធ និងនៅប្រទេសចិន រឺឯប្រទេសផ្សេងៗ លោកក្តាប់មិនបានទេ ។ លោកបានបញ្ជាក់ថាក្នុងនាមជាអគ្គលេខាធិការនៅក្នុងក្រសួងការបរទេស គឺលោកមានតែនាម និងជួយសម្របសម្រួលនៅក្នុងក្រសួងប៉ុណ្ណោះ ព្រោះលោកមិនចេះភាសាបរទេសទេ ។ លោកសាក្សីបានបន្តទៀតថា ខ្លួនមិនបានសិក្សាអំពីឯកសារគោលនយោបាយរបស់បក្សទេ ហើយក៏មិនបានឃើញលក្ខន្តិកៈបក្សដែរ ប៉ុន្តែលោកបានរៀនពីទស្សនៈសភាពការណ៍បច្ចុប្បន្ន និងការវិភាគសភាពការណ៍ទៅអនាគត ដើម្បីជម្រាបជូនបងប្អូនប្រជាជន ។ លោកបានបញ្ជាក់ថា ផែនការរបស់បក្សគឺមានទៅតាមសភាពការណ៍នីមួយៗ ដោយមិនអាចរៀបរាប់ឲ្យត្រឹមត្រូវបានទេ ។ លោកបានលើកជាឧទាហរណ៍ថា បើលោកនៅធ្វើការខាងដាំបន្លែ លោកត្រូវគ្រប់គ្រងការដាំបន្លែឲ្យបានល្អ ។ លោកបន្តថា ក្រោយពីរំដោះថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ នៅក្នុងក្រសួងមិនទាន់មានជារចនាសម្ព័ន្ធត្រឹមត្រូវទេ គឺគេផ្តោតតែទៅលើការរៀបចំបោសសម្អាតក្រសួងតែប៉ុណ្ណោះ ។ ឆ្លើយតបនឹងសំណួររបស់លោកស្រីមេធាវី លោក សាឡុត បាន បានជម្រាបជូនអង្គជំនុំជម្រះថា នៅក្នុងចំណោមអ្នកដែលគេចាប់ខ្លួនពីក្រសួងការបរទេសនោះក៏មានឈ្មោះ ចៅ សេង ដែរ ។ តាមរយៈការយល់ដឹងរបស់លោក បុគ្គលឈ្មោះ ប៉ង់ ជាអ្នកនាំយកមនុស្សចេញទៅ ដោយមានចុះហត្ថលេខាទទួលខុសត្រូវទៀតផង ប៉ុន្តែលោកមិនដឹងថាទាក់ទងនឹងការបញ្ជារបស់ថ្នាក់លើឬយ៉ាងណានោះទេ ។ លោកស្រីមេធាវីបានសួរនាំទាក់ទងនឹងការប្រជុំធំៗនៅក្នុងក្រសួងការបរទេស ដែលធ្លាប់បានធ្វើប៉ុន្មានដងនោះ គឺមានអ្នកចូលរួមទាំងផ្នែកកសិករ និងបញ្ញាជន ប៉ុន្តែលោកមិនបានចូលរួមនៅក្នុងការប្រជុំធំៗដូចជាប្រជុំរៀបចំទៅអង្គការសហប្រជាជាតិនោះឡើយ ។ លោក សាឡុត បាន បានបន្តទៀតថា ការប្រជុំធំៗនោះមិនលើសពី២ដងទេក្នុងរយៈពេលមួយឆ្នាំ ប៉ុន្តែវាអាស្រ័យទៅតាមសភាពការណ៍ដែលជំរុញ និងសភាពការណ៍ទំនេរ ដែលសភាពការទំនេរគឺធ្វើសន្និបាត ។ លោកសាក្សីបដិសេធថាខ្លួនមិនបានដឹងអំពីការចាប់ខ្លួនជនបរទេស និងឈ្លើយសឹកវៀតណាមយកទៅមន្ទីរស-២១ទេ ហើយចំពោះចំណុចថាតើ អៀង សារី ដឹងឬមិនដឹងអំពីបញ្ហានេះ ក៏លោកមិនបានជ្រាបដែរ ។ ចំពោះមន្ទីរឃុំឃាំងនៅបឹងត្របែក លោកសាក្សីមិនបានជ្រាបថា ជនជាប់ចោទ អៀង សារី ទៅញឹកញាប់យ៉ាងណាឡើយ លោកគ្រាន់តែចាំថា អៀង សារី បាននាំលោកទៅមន្ទីរបឹងត្របែកនេះ នៅពេលដែលវៀតណាមហៀបនឹងចូលដល់ភ្នំពេញ ។ លោក សាឡុត បាន បានឆ្លើយបំភ្លឺនៅចំពោះមុខអង្គសវនាការថា លោកទើបតែស្គាល់មន្ទីរនេះនៅក្រោយពេលខ្មែរក្រហមធ្វើសមាហរណកម្មចូលក្នុងរដ្ឋាភិបាលកម្ពុជាតែប៉ុណ្ណោះ ប៉ុន្តែលោកមិនបានស្គាល់នៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យទេ ។ លោកបន្តថាមន្ទីរបឹងត្របែក គឺជាកន្លែងដែល ប៉ង់ បានយកបញ្ញាជនទៅដាក់នៅទីនោះ ដែលនៅក្នុងនោះមានសាស្ត្រាចារ្យដែលល្បីៗ រួមទាំងលោក ហោ ណាំហុង ជាអ្នកការទូតនៅរបបកម្ពុជាប្រជាធិប

តេយ្យ ក៏ត្រូវបានគេចាប់បញ្ជូនមកទីនោះដែរ ។ ឃើញដូច្នេះ ខ្លួនលោកផ្ទាល់យល់ថា ជាការមិនត្រឹមត្រូវទេ ដែលនាំយកអ្នកចេះដឹងមកដាក់នៅទីនេះ ។ លោកបានបញ្ជាក់ថា នៅពេលដែលជនជាប់ចោទ អៀង សារី បាននាំលោកទៅមន្ទីរបឹងត្របែកនោះ តាមការសង្កេតរបស់លោកនៅពេលនោះឃើញថា អ្នកនៅជាប់ឃុំមានការភិតភ័យ ប៉ុន្តែនៅពេលពួកគេបានឃើញលោក និង អៀង សារី ទៅដល់ទីនោះ ពួកគេមានការអបអរសាទរ ដែលហាក់ដូចជារួចផុតពីវេទនានៃការធ្វើទារុណកម្ម ។ ដោយសារឃើញពីភាពលំបាករបស់ពួកគេ អៀង សារី បានផ្តល់ចំណីអាហារទៅដល់បញ្ញាជនដែលជាអ្នកជាប់ឃុំនៅទីនោះ ។ ឆ្លើយតបនឹងសំណួររបស់មេធាវីទាក់ទងនឹងការស្គាល់បញ្ញាជននៅបឹងត្របែក លោកសាក្សី សាឡុត បាន បានអះអាងថា លោកស្គាល់បញ្ញាជនម្នាក់ឈ្មោះ ឃួន ដាវីត ដែលជាមនុស្សពូកែម្នាក់ ព្រោះនៅបរទេសលោក ដាវីត ធ្វើជាសាស្ត្រាចារ្យបង្រៀនសាស្ត្រាចារ្យ ។ លោកសាឡុត បាន បាននាំយកភាពពូកែរបស់ លោក ឃួន ដាវីត ប្រាប់ទៅឪពុកមាររបស់លោកគឺ ប៉ុល ពត ។ ពេលនោះ ប៉ុល ពត បានឲ្យលោកទៅតាមស៊ើបពីបុគ្គលនេះ ក្នុងបំណងនាំយកបុគ្គលនេះមកជួយធ្វើកិច្ចការខ្លះរបស់ខ្លួន ។ លោក សាឡុត បាន ក៏បានទៅប្រាប់ ប៉ង់ ឲ្យតាមមើលឈ្មោះ ដាវីត តាមបញ្ជារបស់ ប៉ុល ពត ព្រោះ ប៉ង់ គឺជាអ្នកគ្រប់គ្រងអ្នកទាំងនោះ ។ ប៉ុន្តែក្រោយមកបំណងរបស់ ប៉ុល ពត មិនបានសម្រេចទេ ដោយសារមានការបាត់ខ្លួនលោក ឃួន ដាវីត ដោយគ្មានដំណឹងថាទៅទីណាឡើយ ។

ចំពោះការិយាល័យ ២១ នៅតាខ្មៅ លោកសាក្សីបានរៀបរាប់ជូនអង្គជំនុំជម្រះថា ខ្លួនមិនបានជ្រាបពីការិយាល័យនេះទេ លុះក្រោយពេលវៀតណាមចូលស្រុកខ្មែរហើយ ទើបលោកបានដឹង ។ ការិយាល័យនេះមិនស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងការបរទេសទេ ។ ឆ្លើយតបនឹងសំណួររបស់លោកស្រីមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី លោកសាក្សីបានបញ្ជាក់ថា លោកបានដឹងអំពីការចាប់ខ្លួនបុគ្គលឈ្មោះ ខៀវ ធីរ៉ាត់ ដែលត្រូវជាបងថ្លៃរបស់ អៀង សារី ហើយបុគ្គលនេះបានស្លាប់នៅតាខ្មៅ ។ លោកបាននាំយកសាកសពរបស់លោកស្រី ខៀវ ធីរ៉ាត់ ដែលជាបញ្ញាជនមួយរូបមកពីប្រទេសបារាំង និងជាសាស្ត្រាចារ្យអក្សរសាស្ត្រខ្មែរមកបូជានៅវត្តព្រះពុទ្ធដោយផ្ទាល់ដៃទៀតផង ។ ការស្លាប់របស់លោកស្រី ខៀវ ធីរ៉ាត់ តាមដែលលោកសាក្សីដឹងពីឈ្មោះ ដួន ជឿន ក្រោយពេលពិនិត្យបានឲ្យដឹងថា គឺកើតឡើងដោយសារតែត្រូវគេប្រហារចិត្ត ។

លោកសាក្សី សាឡុត បាន បានបញ្ជាក់ថា លោកមិនដឹងថាមន្ទីរប្រាំងចំរេះបង្កើតឡើងនៅឆ្នាំណាទេ លោកគ្រាន់តែចាំបានថាមន្ទីរនេះជាកន្លែងរបស់ភូមិភាគ៣០៤ ដែលប្រគល់ឲ្យក្រសួងការបរទេសពីឆ្នាំ១៩៧៧រហូតមក ។ កន្លែងនេះសព្វថ្ងៃគឺស្ថិតនៅខាងលិចភ្នំពេញ ជាប់នឹងផ្លូវជាតិ ។ វាជាកន្លែងដាំដុះស្រូវ ដាំបន្លែបន្តិចបន្តួច និងចិញ្ចឹមត្រី ។ នៅឆ្នាំ១៩៧៧ លោក សាឡុត បាន ជាអ្នកគ្រប់គ្រងមន្ទីរប្រាំងចំរេះ ដែលជាមន្ទីរស្ថិតនៅក្រោមក្រសួងការបរទេស ដោយមានបុគ្គលិកតិចជាង១០០នាក់ ។ ក្រោយពីឆ្នាំ១៩៧៧ មន្ទីរប្រាំងចំរេះក្លាយជាផ្នែកមួយនៃក្រសួងការបរទេស ហើយសមាសភាពធ្វើការគឺមកពីភូមិភាគ៣០៤ ដែលនៅទីនោះស្រាប់ ។ សាក្សីបានបញ្ជាក់ថា អ្នកធ្វើការនៅប្រាំងចំរេះភាគច្រើនគឺជាប្រជាជនចាស់ និងមិនមានបញ្ញាជនទេ នៅពេលលោកកំពុងគ្រប់គ្រង ។ លោកស្រីមេធាវីបានសួរដេញដោលឲ្យសាក្សីពន្យល់ពីភាពខុសគ្នារវាងប្រជាជនចាស់ និងប្រជាជនថ្មី ។ នៅត្រង់ចំណុចនេះលោក សាឡុត បាន មិនបានឆ្លើយតបនឹងសំណួររបស់មេធាវីដោយផ្ទាល់ទេគឺលោកបានឆ្លើយតបថា លោកមិនបានបែងចែកប្រជាជនថ្មី ឬចាស់នោះទេ ។ អ្នកដែលធ្វើការនៅទីនោះ គឺថ្នាក់លើបានបញ្ជូនទៅឲ្យលោក ហើយការជ្រើសរើសបុគ្គលិកនៅពេលនោះមិនដូចជាសម័យអ៊ីនធឺណែតនាពេលបច្ចុប្បន្ននេះទេ ។ អ្នកនៅទីនេះមិនអាចដើរផ្តេសផ្តាសបានឡើយ គឺនៅតែកន្លែងខ្លួនឯងប៉ុណ្ណោះ ។ ជាគោលការណ៍ ការហូបចុក គឺខ្លួនខបត្តមខ្លួនដោយខ្លួនឯង បើខ្វះខាតអង្គការនឹងជួយផ្តល់ឲ្យខ្លះ ហើយការហូបចុកគឺធ្វើឡើងជារួម ។ នៅមន្ទីរប្រាំងចំរេះ លោកធ្លាប់បានប្រជុំសតិអារម្មណ៍ និងការបង្កបង្កើនផលជាមួយនឹងបុគ្គលិកដែលធ្វើការនៅទីនោះ ហើយលោកក៏ធ្លាប់រាយការណ៍ទៅ អៀង សារី ដែរ ។ អៀង សារី មិនសូវបានធ្វើដំណើរទៅទីនោះទេ ។

បន្ទាប់មកលោកស្រីមេធាវីបានស្នើឲ្យលោកសាក្សីធ្វើការបញ្ជាក់លើឯកសារទាក់ទងនឹងចម្លើយរបស់លោកសាក្សីដែលបាន

ធ្វើជាមួយនឹងការិយាល័យសហចៅក្រមស៊ើបអង្កេត ។ នៅពេលសួរថាតើលោកសាក្សីបានស្គាល់ឈ្មោះ ហួត សម្បត្តិ ទេ? លោកសាក្សីបានបញ្ជាក់ថា លោកគ្រាន់តែធ្លាប់ឮឈ្មោះ ប៉ុន្តែមិនស្គាល់មុខបុគ្គលនេះទេ ។ បន្ទាប់មកលោកស្រីមេធាវីបានសួរថាតើលោកសាក្សីមានដឹងពីការចាប់ខ្លួនឈ្មោះ ហួត សម្បត្តិ នៅក្នុងឆ្នាំ ១៩៧៦ ពីមន្ទីរប្រាំងចំរេះដែរឬទេ? លោកបានឆ្លើយតបថា នៅក្នុងឆ្នាំ១៩៧៦ លោកមិនបានដឹងនោះទេ ព្រោះលោកមិនទាន់ចូលគ្រប់គ្រងនៅទីនោះនៅឡើយ ។

**ខ) ការសួរដេញដោលដោយមេធាវី វ៉ាប៊ីសាន់ ជ្រាគាណា**



វ៉ាប៊ីសាន់ ជ្រាគាណា

សំណួរដំបូងរបស់លោកស្រីមេធាវីអន្តរជាតិ វ៉ាប៊ីសាន់ជ្រាគាណា បានសួរអំពីការដាក់ទណ្ឌកម្មទៅលើ ប៉ន់ ចំពោះការស្លាប់របស់លោកស្រី ខៀវ ធីរ៉ាត់ ។ សាក្សីបានឆ្លើយតបថា មិនឃើញមានការដាក់ទណ្ឌកម្មអីទៅលើ ប៉ន់ នោះទេ ។ ប៉ុន្តែក្រោយមកបានឮថា ប៉ន់ បាត់ខ្លួនដោយមិនដឹងពីមូលហេតុ ។ លោកស្រីមេធាវីអន្តរជាតិបានបន្តសំណួររបស់ខ្លួនដែលចង់សួរនោះ គឺថាតើការបាត់ខ្លួនរបស់ ប៉ន់ មានភាពពាក់ព័ន្ធនឹងការស្លាប់របស់លោកស្រី ខៀវ ធីរ៉ាត់ ដែរឬទេ? ត្រង់សំណួរនេះ មានការជំទាស់ពីមេធាវីអន្តរជាតិការពារក្តីលោក អៀង សារី ដែលថាជាសំណួរដែលនាំឲ្យមានការសន្និដ្ឋានដោយសាក្សី ។ អង្គជំនុំជម្រះបានគាំទ្រទៅលើការជំទាស់នេះ ។ លោកស្រីមេធាវី វ៉ាប៊ីសាន់ ជ្រាគាណា បានបន្តសំណួរទាក់ទងនឹងមន្ទីរបឹងត្របែក នៅពេលដែលលោកផ្តាំឲ្យ ប៉ន់ ជួយយកចិត្តទុកដាក់ចំពោះបញ្ញវន្តឈ្មោះ ឃួន ដាវីត ។ លោកស្រីមេធាវីបានលើកឡើងថា សំណួររបស់លោកស្រីនោះគឺថា តាមអ្វីដែលសាក្សីបានផ្តល់សក្ខីកម្មកន្លងមកគឺសាក្សីបានទៅបឹងត្របែកមុនពេល ប៉ន់ ត្រូវបានចាប់ខ្លួន ប៉ុន្តែសាក្សីក៏បាននិយាយដែរថា មិនមានការទាក់ទងគ្នាទេរវាងមន្ទីរបឹងត្របែក និងក្រសួងការបរទេសនៅមុនពេល ប៉ន់ ត្រូវបានចាប់ខ្លួន ។ តើសាក្សីអាចពន្យល់បានទេថាខ្លួនបានទៅមន្ទីរបឹងត្របែកនៅពេលដែលមន្ទីរនេះស្ថិតនៅក្រោមការគ្រប់គ្រងរបស់ ប៉ន់? លោកសាក្សីបានឆ្លើយបដិសេធថាលោកបាន ជួប ប៉ន់ និយាយគ្នាអំពីឈ្មោះ ឃួន ដាវីត មែន ប៉ុន្តែមិនមែនជួបនៅមន្ទីរបឹងត្របែកនោះទេ គឺនៅកន្លែងណាមួយផ្សេងដែលខ្លួនចាំមិនបាន ។ លោកស្រីមេធាវីបានសួរបញ្ជាក់បន្ថែមអំពីការអញ្ជើញទៅមន្ទីរបឹងត្របែករបស់លោក សាឡុត បាន នៅមុនពេលវៀតណាមចូលមកដល់ប្រទេសកម្ពុជា ដែលកាលនោះសាក្សីបានជម្លៀសទាហាន ថាតើសាក្សីមានអំណាចអ្វីទៅលើយោធាទាំងអស់នេះ តើជាសមាជិកសន្តិសុខ ឬក៏ជាអង្គភាពការពាររបស់ក្រសួង? ចំពោះសំណួរនេះ លោកមេធាវី កាណាវ៉ាស បានជំទាស់ថាលោកដូចជាមិនបានឮអ្វីដូចជាលោកស្រីមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីលើកឡើងនោះទេ ហើយសូមកុំឲ្យសួរនូវសំណួរនោះ ។ ភ្លាមៗលោកតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ វីនសិន ដឺវ៉ាល់ ក៏បានក្រោកឈរឡើង ហើយបង្ហាញនូវកំណត់ត្រារបស់ខ្លួនអំពីភាពជាក់លាក់ថា សាក្សីពិតជាបានទៅមន្ទីរបឹងត្របែកចំនួនបួនលើក ដែលពីរលើកទៅជាមួយ អៀង សារី និងពីរលើកទៀតទៅម្នាក់ឯង ហើយនៅក្នុងចំណោមនោះមានម្តងគឺសាក្សីបានទៅដើម្បីជម្លៀសទាហាននៅមន្ទីរបឹងត្របែក នៅមុនពេលវៀតណាមចូលមកដល់កម្ពុជា ។ លោកមេធាវី គង់ សំអុន ការពារក្តី ជនជាប់ចោទ ខៀវ សំផន បានធ្វើអន្តរាគមន៍បន្ថែម ចំពោះបញ្ហានេះដោយលើកឡើងថា សាក្សីបានលើកឡើងនោះគឺមិនមែនទៅជម្លៀសទាហានទេ គឺទៅជម្លៀសបញ្ញជននៅទីនោះ ។ អង្គជំនុំជម្រះបានចេញសេចក្តីសម្រេចផ្ទាល់មាត់ដោយគាំទ្រការជំទាស់របស់មេធាវីការពារក្តី និងបានរំឭកថា ជាការពិតសាក្សីមិនបានលើកឡើងថាខ្លួនទៅជម្លៀសទាហានទេ គឺទៅជម្លៀសបញ្ញាជននៅបឹងត្របែកប៉ុណ្ណោះ ។

លោកសាក្សីបានបញ្ជាក់ថា លោកធ្លាប់បានឃើញ ប៉ង់ នៅគ្រប់ទីកន្លែង ហើយជាញឹកញាប់នៅមន្ទីរ៨៧០ ជួនកាលឃើញគាត់នៅជួបជុំទាហាន កងទ័ព អប់រំកងទ័ព ដូចជាកម្មាភិបាលចល័តមួយរបស់ក្រសួង៨៧០ ។ លោកបានបន្តទៀតថា ប៉ង់ មានសិទ្ធិទៅណាក៏បាន និងមានសិទ្ធិចូលគ្រប់មន្ទីរទាំងអស់ ព្រោះ ប៉ង់ មានសិទ្ធិចល័តគ្រប់ទីកន្លែង ។ លោកបន្តថា ប៉ង់ មានសិទ្ធិដើរហើរដោយសេរីតែនៅក្នុងក្របខណ្ឌភ្នំពេញប៉ុណ្ណោះ ។ ឆ្លើយតបនឹងសំណួរបន្ទាប់សាក្សីបានបញ្ជាក់ថា លោកមិនដឹងថានរណាទទួលបន្ទុកជំនួស ប៉ង់ នោះទេ ព្រោះពេលនោះសភាពការណ៍មានភាពចលាចល ដូច្នេះ លោកគិតតែពីការរៀបចំអង្គភាពរបស់លោកតែប៉ុណ្ណោះ ធ្វើម៉េចឲ្យរួចពីការចូលលុកលុយរបស់ប្រទេសវៀតណាម ។ បន្ទាប់មកលោកស្រីមេធាវីបានបង្ហាញលោកសាក្សីអំពីរូបរបស់លោក ចៅ សេង ដែលស្ថិតនៅក្នុងទីក្រុងប៉ារីស នៅឆ្នាំ១៩៧១ គឺនៅពេលដែលលោក ចៅ សេង កំពុងផ្តល់បទសម្ភាសន៍ដល់អ្នកកាសែត ។ ទាក់ទងនឹងឈ្មោះ ចៅ សេង ដែលជាអតីតមន្ត្រីការទូតនៅមន្ទីរប្រាំងចំរេះ សាក្សីបានឆ្លើយថា លោកស្គាល់ឈ្មោះ ចៅ សេង តាមរយៈកាសែត ប៉ុន្តែនៅក្នុងរូបដែលបង្ហាញនេះ លោកមិនស្គាល់ទេ និងថាលោកមិនបានដឹងថាលោក ចៅ សេង ត្រូវបានចាប់បញ្ជូនទៅទីណា ហើយនរណាជាអ្នកចាប់នោះទេ ។ បន្ទាប់មកលោកស្រីមេធាវីបានពន្យល់ទៅលោកសាក្សីថា ចៅ សេង ត្រូវបានចាប់ខ្លួនបញ្ជូនទៅមន្ទីរបឹងត្របែកនិងក្រោយមកត្រូវបានបញ្ជូនទៅមន្ទីរស-២១ នៅពេលដែលគេចាប់ខ្លួននោះលោក ចៅ សេង ត្រូវបានគេប្តូរឈ្មោះទៅជា ចិន សួន ប៉ុន្តែសាក្សីនៅតែរក្សាចម្លើយដដែលថាខ្លួនមិនបានដឹងពីបញ្ហានេះទេ ។ បន្ទាប់មកលោកស្រីមេធាវីបានបង្ហាញរូបថតលោក ភីង គុន ដែលជាសាស្ត្រាចារ្យមហាបរិញ្ញាផ្នែកច្បាប់ ដែលត្រូវបានគេទទួលស្គាល់ និងស្គាល់ជាទូទៅថាជាមនុស្សឆ្នើមនៅក្នុងប្រទេសកម្ពុជា ព្រមទាំងបញ្ជាក់ថា លោកសាស្ត្រាចារ្យ ភីង គុន ធ្លាប់បានបង្រៀននៅក្នុងមហាវិទ្យាល័យបារាំងមួយចំនួន និងជាអ្នកជំនាញផ្នែកកងទ័ពសមុទ្រទៀតផង ។ លោកស្រីមេធាវីបានសួរលោកសាក្សី សាឡុត បាន អំពីការចាប់ខ្លួនលោកសាស្ត្រាចារ្យ ភីង គុន យកទៅមន្ទីរបឹងត្របែក ។ លោកសាក្សីបានឆ្លើយតបថា លោកមិនបានដឹងអំពីបញ្ហានៃការចាប់ខ្លួនលោក ភីង គុន នោះទេ ។ បន្ទាប់មកលោកស្រីមេធាវីបានសួរអំពីការបាត់ខ្លួនរបស់លោក រស់ សារិន និងប្រពន្ធរបស់គាត់ឈ្មោះ រស់ ឈួស៊ីអ៊ី ។ លោកសាក្សីនៅតែរក្សាចម្លើយតបដដែលថា ខ្លួនមិនបានដឹងពីការចាប់ខ្លួន អ្នកទាំងនោះទេ ។

**៣) ការផ្តល់សក្ខីកម្មរបស់ សាឡុត បាន ចំពោះការចោទសួររបស់អង្គជំនុំជម្រះ**

ក្នុងការសួរដេញដោលសាក្សី សាឡុត បាន លោកប្រធានអង្គជំនុំជម្រះ គឺលោកចៅក្រម និល ណុន បានសួរបញ្ជាក់អង្គហេតុទាក់ទងនឹងមន្ទីរ៨៧០ អំពីសមាជិករបស់គណៈមជ្ឈិម និងគណៈអចិន្ត្រៃយ៍ និងការនាំយកបុគ្គលិកចេញពីក្រសួងការបរទេស ។ ចំណែកលោកចៅក្រម ហ្សង់ម៉ាក ឡាវើញ បានសួរផ្តោតសំខាន់លើតួនាទីរបស់ ប៉ង់ ដែលមានទំនាក់ទំនងជាមួយក្រសួងការបរទេស ។ គួររំឭកថា អង្គហេតុទាំងនេះត្រូវបានតំណាងសហព្រះរាជអាជ្ញាសួរម្តងរួចមកហើយ ដូច្នេះការណ៍ដែលលោកចៅក្រមទាំងពីរសួរ គឺគ្រាន់តែជាការបញ្ជាក់បន្ថែមប៉ុណ្ណោះ ។ បើទោះបីជាដូច្នេះក្តីក៏លោក សាឡុត បាន នៅតែផ្តល់សក្ខីកម្មដោយមិនមានភាពច្បាស់លាស់ដដែល ។ ជាក់ស្តែងពាក់ព័ន្ធនឹងសមាជិករបស់គណៈកម្មាធិការមជ្ឈិម និងគណៈអចិន្ត្រៃយ៍នៃបក្សកុម្មុយនីស្តកម្ពុជា ឬអង្គហេតុទាក់ទងនឹងមន្ទីរ៨៧០ លោក សាឡុត បាន តែងតែឆ្លើយត្រឹមតែក្នុងភាពប្រហាក់ប្រហែលតែប៉ុណ្ណោះ ។

សាក្សី បានបញ្ជាក់ថានៅឆ្នាំ១៩៧៥-១៩៧៦ គណៈកម្មាធិការមជ្ឈិមមានសមាជិកប្រហែល២០នាក់ តែមិនដឹងថាបុគ្គលណាខ្លះជាសមាជិករបស់គណៈកម្មាធិការនេះឡើយ ។ រីឯសមាជិករបស់គណៈកម្មាធិការអចិន្ត្រៃយ៍រួមមាន ប៉ុល ពត និង នួន ជា ហើយ សុន សេន ដែលទទួលខុសត្រូវខាងយោធា ប្រហែលមិនមែនជាសមាជិករបស់គណៈអចិន្ត្រៃយ៍ទេ ។ សាឡុត បាន បញ្ជាក់បន្ថែមថា ខៀវ សំផន មានតួនាទីជាសមាជិករបស់គណៈកម្មាធិការមជ្ឈិម ហើយធ្លាប់រស់នៅនិងធ្វើការជាមួយ ប៉ុល ពត និង អៀង សារី ដូច្នេះ ខៀវ សំផន បានដឹងអំពីកិច្ចការដែល ប៉ុល ពត និង អៀង សារី បានធ្វើ ។

ពាក់ព័ន្ធនឹងមន្ទីរ៨៧០ សាឡុត បាន បញ្ជាក់ថា មន្ទីរនេះកើតមានតាំងពីមុនរបបកម្ពុជាប្រជាធិបតេយ្យ ពោលគឺមានតាំងពី

មុនសង្គ្រាមឆ្នាំ១៩៧០-១៩៧៥ ដែលជាទូទៅគេហៅថាមន្ទីររបស់អង្គការ ។ ក្រោយថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ មន្ទីរនេះមានទីតាំងនៅមន្ទីរក-១ (ជាទូទៅសាក្សីហៅមន្ទីរ៨៧០ថាជាមន្ទីរក-១) ហើយមន្ទីរនេះត្រូវបានបំបែកទៅជាមន្ទីរក-២ ។

ក្នុងរបបកម្ពុជាប្រជាធិតេយ្យ សឿ វ៉ាស៊ី ហៅ ឌឿន ជាអនុលេខារបស់ភូមិភាគ៣០៤ មកធ្វើការនៅមន្ទីក-២ ដោយទទួលបន្ទុកផ្នែកចែកចាយសម្ភារភស្តុភារ ហើយបន្ទាប់ពី ឌឿន ត្រូវបានចាប់ខ្លួន ខៀវ សំផន ក៏ទទួលបន្ទុកធ្វើការងារនេះជំនួសវិញ ។ ចំណែក ប៉ង់ ធ្វើការងារនៅមន្ទីរក-១ ដែលក្នុងឋានៈនេះ ប៉ង់ មានតួនាទីគ្រប់គ្រងក្រសួងទាំងអស់ដែលនៅក្រោមមជ្ឈិម ។ សំណួរចុងក្រោយ លោកចៅក្រមបានសួរថាតើមន្ទីរ៨៧០ គឺជាមន្ទីរដែលប្រែក្លាយមកពីមន្ទីរ១០០ដែរឬទេ? សាក្សី សាឡុត បាន បានបញ្ជាក់ដោយភាពស្រពិចស្រពិលថា "មន្ទីរ៨៧០ គឺប្រហែលជាមន្ទីរដែលប្រែក្លាយមកពីមន្ទីរ១០០ ដែលមានមុនរបបកម្ពុជាប្រជាធិបតេយ្យ" ។

***កំណត់សម្គាល់៖*** បន្ទាប់ពីលោកចៅក្រមបញ្ចប់សំណួររបស់ខ្លួន លោកមេធាវី ម៉ៃឃើល ខាណាវ៉ាស ការពារក្តីជនជាប់ចោទ អៀង សារី បានលើកឡើងថា អង្គជំនុំជម្រះបានសម្រេចរួចហើយថា ភាគីមិនអាចយកចម្លើយរបស់សាក្សីណាម្នាក់មកសួរសាក្សីម្នាក់ទៀតឡើយ តែអង្គជំនុំជម្រះអាចធ្វើបែបនេះបាន ។ ដូច្នេះខ្លួនស្នើសុំអង្គជំនុំជម្រះសម្រេចជាថ្មី គឺអនុញ្ញាតឲ្យភាគីអាចយកចម្លើយរបស់សាក្សីណាម្នាក់ទៅចោទសួរសាក្សីម្នាក់ទៀតបាន ព្រោះពេលនេះខ្លួនមានបំណងយកចម្លើយរបស់សាក្សីជាច្រើនមកចោទសួរលោក សាឡុត បាន ។ មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី គឺលោក ស្រី អេលីហ្សាប៉ែត ស៊ីម៉ូណូហ្វុត បានគាំទ្រយ៉ាងពេញទំហឹងចំពោះសំណើសុំរបស់លោក ខាណាវ៉ាស ។ ភ្លាមៗ នោះលោកចៅក្រម ហ្សង់ម៉ាក ឡាវែ៉ញ បានញ្ជាក់ជូនភាគីថា អង្គជំនុំជម្រះមិនមានបំណងកែប្រែសេចក្តីសម្រេចរបស់ខ្លួនឡើយ ។

**៤) ការសួរដេញដោលសាក្សី សាឡុត បាន ដោយមេធាវីការពារក្តីជនជាប់ចោទទាំងបីក្រុម**

តាមការអនុវត្តកន្លងមក លំដាប់លំដោយនៃការសួរដេញដោលសាក្សីដោយមេធាវីការពារក្តី គឺចាប់ផ្តើមដោយមេធាវីការពារក្តីរបស់ជនជាប់ចោទ នួន ជា បន្ទាប់មកមេធាវីរបស់ អៀង សារី និង ចុងក្រោយបង្អស់គឺមេធាវីរបស់ជនជាប់ចោទ ខៀវ សំផន ។ ដោយឡែក ក្នុងការសួរដេញដោលលោក សាឡុត បាន អង្គជំនុំជម្រះបានអនុញ្ញាតឲ្យមេធាវីរបស់ជនជាប់ចោទ អៀង សារី សួរសាក្សីមុនគេ បន្ទាប់មកមេធាវីរបស់ជនជាប់ចោទ នួន ជា និងចុងក្រោយគឺមេធាវីរបស់ ខៀវ សំផន ។ ការសម្រេចឲ្យមានការផ្លាស់ប្តូរនេះ គឺដោយសារអង្គជំនុំជម្រះយល់ឃើញថា សក្ខីកម្មដែល សាឡុត បានផ្តល់ជូនតំណាងសហព្រះរាជអាជ្ញា មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងអង្គជំនុំជម្រះ ភាគច្រើនពាក់ព័ន្ធនឹងជនជាប់ចោទ អៀង សារី ។ ចំណែកជនជាប់ចោទ នួន ជា និង ខៀវ សំផន មានការជាប់ពាក់ព័ន្ធតិចតួច ព្រោះក្នុងរបបកម្ពុជាប្រជាធិបតេយ្យលោក សាឡុត បាន កាន់តួនាទីជាអគ្គលេខាក្រសួងការបរទេស ដែលមានជនជាប់ចោទ អៀង សារី ជាអ្នកគ្រប់គ្រងក្នុងឋានៈជាឧបនាយករដ្ឋមន្ត្រី និងរដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការបរទេស ។

**ក) ការផ្តល់សក្ខីកម្មចំពោះការចោទសួររបស់មេធាវីការពារក្តី អៀង សារី**


ម៉ៃឃើល ខាណាវ៉ាស់

ក្នុងការសួរដេញដោល សាឡុត បាន លោកមេធាវីអន្តរជាតិ ម៉ៃឃើល ខាណាវ៉ាស់ សួរផ្តោតលើចំណុចសំខាន់ៗមួយចំនួនដូចជាទំនាក់ទំនងរវាងសាក្សីជាមួយ ប៉ុល ពត នៅមុនរបបកម្ពុជាប្រជាធិបតេយ្យ ការចាត់តាំងសាក្សីឲ្យធ្វើជាអគ្គលេខាធិការក្រសួងការបរទេស និងការបាត់ខ្លួនកម្មាភិបាលខ្មែរក្រហមសំខាន់ៗមួយចំនួន ។

### ◆ អំពីទំនាក់ទំនងរវាង សាឡុត បាន ឬ ប៉ាង់ ជាមួយ ប៉ុល ពត

ក្នុងការសួរដេញដោលពីទំនាក់ទំនងរវាង សាឡុត បាន ជាមួយ ប៉ុល ពត លោកមេធាវី ខាណារ៉ាស បានសួរផ្ដោតពីភាពជិតស្និទ្ធក្នុងក្របខណ្ឌគ្រួសារ និងក្នុងក្របខណ្ឌការងារ ដែលសាក្សីមានចំពោះ ប៉ុល ពត ។ ជាការឆ្លើយតបលោក សាឡុត បាន បានបញ្ជាក់ថា ក្នុងក្របខណ្ឌគ្រួសារ គឺខ្លួនគោរពនិងស្រឡាញ់ ប៉ុល ពត ទុកដូចជាទីសក្ការៈរហូតមកដល់សព្វថ្ងៃនេះ ព្រោះជានិច្ចជាកាល ប៉ុល ពត តែងតែធ្វើការណែនាំអប់រំឲ្យកសាងខ្លួន ។ ចំពោះក្របខណ្ឌការងារវិញ គឺចាប់តាំងពីឆ្នាំ១៩៦៧ មក លោកនៅជាមួយ ប៉ុល ពត ជាប់រហូត ដែលពេលនោះលោកទទួលបន្ទុកជាអ្នកការពារ ជាអ្នកធ្វើម្ហូប និងជាគ្រូពេទ្យប្រចាំការផ្ទាល់របស់ ប៉ុល ពត ។ ប៉ុន្តែខ្លួនមិនអាចចេញចូលកន្លែងរបស់ ប៉ុល ពត បានឡើយ ប្រសិនបើគ្មានភារកិច្ច ។ បន្ថែមលើនេះ ប៉ុល ពត ក៏មិនដែលនិយាយពីការងារនៅក្នុងបក្សប្រាប់ខ្លួនដែរ ពោលគឺមិនដែលប្រាប់ថាបុគ្គលណាខ្លះជាសមាជិករបស់គណៈកម្មាធិការមជ្ឈិមឬគណៈកម្មាធិការអចិន្ត្រៃយ៍នៃបក្សកុម្មុយនីស្តកម្ពុជា ឬប្រាប់ថាបក្សនេះមានរចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋបាល និងប្រព័ន្ធទំនាក់ទំនងការងារដូចម្ដេចឡើយ ។ ជាងនេះទៅទៀត សាក្សីក៏មិនដែលត្រូវបានអនុញ្ញាតឲ្យចូលរួមកិច្ចប្រជុំដែលធ្វើឡើងដោយ ប៉ុល ពត និងប្រធានភូមិភាគឬប្រធានតំបន់ឡើយ ហើយរបាយការណ៍នៃកិច្ចប្រជុំទាំងនោះ ក៏ខ្លួនមិនដែលបានមើលដែរ ។ ដូច្នេះលោកមិនដឹងថាកិច្ចប្រជុំទាំងនោះធ្វើឡើងក្នុងគោលបំណងអ្វី ហើយនិយាយអំពីបញ្ហាអ្វីនោះទេ ។ ប៉ុន្តែទោះបីជាយ៉ាងណាក្ដី ខ្លួនបានស្គាល់ឈ្មោះប្រធានភូមិភាគ ឬប្រធានតំបន់ដែលបានចូលរួមប្រជុំជាមួយ ប៉ុល ពត តាមរយៈការសួរ ប៉ាង់ ។ មកដល់ចំណុចនេះ លោក ខាណារ៉ាស មិនបានចោទសួរបន្តអំពីឈ្មោះរបស់អ្នកចូលរួមប្រជុំទាំងនោះឡើយ ។ លោក សាឡុត បាន បានបញ្ជាក់ទៀតថា មុនវាយបែកទីក្រុងភ្នំពេញ ខ្លួនត្រូវបាន ប៉ុល ពត ចាត់តាំងឲ្យនៅយាមឃ្លាំងអាវុធ និងគ្រាប់រំសេវ ដែលរក្សាទុកនៅផ្ទះមួយក្នុងឃុំពាម ដើម្បីត្រៀមវាយយកទីក្រុងភ្នំពេញ ។ ក្នុងអំឡុងពេលនោះលោកស្ដាប់បញ្ជាពី ប៉ុល ពត តែម្នាក់គត់ ព្រោះ ប៉ាង់ បានទៅបោះមូលដ្ឋានទ័ពនៅខាងកើតទន្លេជាមួយបុគ្គលម្នាក់ឈ្មោះ ជាម ។ សរុបមក បើខ្លួន នៅជាមួយ ប៉ាង់ គឺត្រូវទទួលការណែនាំពី ប៉ាង់ បើនៅជាមួយ ប៉ុល ពត គឺស្ដាប់ ប៉ុល ពត ។

ចំពោះទំនាក់ទំនងរវាង ប៉ាង់ និង ប៉ុល ពត វិញលោក សាឡុត បាន បានបញ្ជាក់ថា ក្នុងក្របខណ្ឌការងារ ប៉ាង់ មានភាពជិតស្និទ្ធជាមួយ ប៉ុល ពត ជាងលោក ពោលគឺរាល់កិច្ចការផ្សេងៗ គឺ ប៉ាង់ ទទួលការណែនាំផ្ទាល់ពី ប៉ុល ពត ។ ពេលមានកិច្ចប្រជុំ ឬមានការបើកវគ្គរៀនសូត្រផ្សេងៗ ប៉ុល ពត តែងតែហៅ ប៉ាង់ មកប្រាប់ដើម្បីចាត់វិធានការការពារសន្តិសុខឲ្យខ្លួន និងអ្នកចូលរួមប្រជុំផ្សេងៗទៀត ។

ស្ថិតនៅក្នុងបន្ទប់សវនាការ សាក្សី សាឡុត បាន បានបញ្ជាក់ទៀតថា ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ប៉ាង់ មានតួនាទីជាប្រធានមន្ទីរ ៨៧០ ។ ដូច្នេះ ប៉ាង់ គឺជាមនុស្សម្នាក់ដែលមានអំណាច ពោលគឺគ្រប់ក្រសួងស្ថាប័នទាំងអស់ ប៉ាង់ អាចចេញចូលដោយមិនចាំបាច់មានលិខិតអនុញ្ញាត ។ ជាងនេះទៅទៀត ប៉ាង់ គឺជាអ្នកទទួលបន្ទុកក្នុងការជ្រើសរើសបុគ្គលិកឲ្យមកបំពេញការងារនៅក្រសួងការបរទេស ដែលបុគ្គលិកទាំងនេះភាគច្រើនត្រូវបានជ្រើសរើសចេញពីវណ្ណៈកសិករ និងកម្មករ ។

ចំពោះការនាំយកមនុស្សចេញពីក្រសួងការបរទេសវិញ លោក សាឡុត បាន បានបំភ្លឺថា នៅពេល ប៉ាង់ នាំយកកម្មាភិបាល បុគ្គលិក ឬបញ្ជូនជនណាម្នាក់ចេញពីក្រសួងការបរទេស គឺ ប៉ាង់ មិនដែលមកប្រាប់ខ្លួនដោយផ្ទាល់ឡើយ គឺគ្រាន់តែប្រាប់តាមទូរស័ព្ទប៉ុណ្ណោះ ។ មនុស្សដែល ប៉ាង់ នាំទៅគឺមិនដែលត្រឡប់មកវិញឡើយ ហើយជាទូទៅត្រូវបានគិតថា ប៉ាង់ យកអ្នកទាំងនោះទៅសម្លាប់ ទោះបីជាទូទៅ ប៉ាង់ ប្រាប់ថាយកទៅសិក្សាអប់រំ ឬឲ្យទៅធ្វើការកន្លែងផ្សេងៗក៏ដោយ ។ លោក សាឡុត បាន បានពន្យល់ពីខ្សែសង្វាក់នៃការយកមនុស្សចេញពីក្រសួងការបរទេសថា តាមធម្មតា ប៉ាង់ ជាអ្នកមកយកដោយផ្ទាល់ ។ ប៉ុន្តែក្នុងករណីអ្នកនៅក្រោមបង្គាប់របស់ ប៉ាង់ ជាអ្នកមកយក គឺត្រូវមានសំបុត្រអនុញ្ញាត ដោយមានចុះហត្ថលេខារបស់ ប៉ាង់ ។ ជាទូទៅ ជាម ដែលជាអនុលេខារបស់លោក សាឡុត បាន គឺជាអ្នកដឹកមនុស្សចេញពីក្រសួងការបរទេស បន្ទាប់មកផ្ទេរឲ្យអ្នកដែលមកយកនៅតាមផ្លូវ ហើយអ្នកដែលមកនាំយកមនុស្សទៅ គឺកម្រមកដល់ក្រសួងការបរទេសណាស់ ។ ទោះបីជាយ៉ាងណាក៏ដោយលោក សាឡុត បាន នៅតែមិនអាចបញ្ជាក់

ឲ្យបានច្បាស់លាស់ថា បុគ្គលណាជាអ្នកអនុញ្ញាតឲ្យ ប៉ង់ មានសិទ្ធិនាំយកបុគ្គលិក និងបញ្ញាជនជាច្រើនចេញពីក្រសួងការបរទេសនោះឡើយ ។

ពាក់ព័ន្ធនឹងតួនាទីរបស់ ប៉ង់ លោកមេធាវី ខាណាវ៉ាស បានចោទសួរសាក្សី សាឡុត បាន អំពីការស្លាប់របស់លោកស្រី ខៀវ ធីរ៉ាត់ និងការបាត់ខ្លួនរបស់សាស្ត្រាចារ្យ ឃួន ដេវីត ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ ប៉ង់ ។ លោក សាឡុត បាន បានបញ្ជាក់ថា ខៀវ ធីរ៉ាត់ គឺជាបងស្រីរបស់ ខៀវ ធីរិទ្ធ(អៀង ធីរិទ្ធ) ត្រូវបានជនមិនស្គាល់មុខប្រចាំប់កសម្លាប់ដោយមិនដឹងមូលហេតុ ។ ពេល នោះ ខៀវ ធីរ៉ាត់ ស្ថិតនៅក្រោមគ្រប់គ្រងរបស់ ប៉ង់ ។ គួររំពឹងថា ក្រោយពី ខៀវ ធីរ៉ាត់ ស្លាប់បន្តិច ក្រោយមក ប៉ង់ ត្រូវបានបាត់ខ្លួនដោយគ្មានមូលហេតុដែរ ដែលចំណុចនេះធ្វើឲ្យលោក ខាណាវ៉ាស ចោទសួរថាតើការបាត់ខ្លួនរបស់ ប៉ង់ មកពីមានការសម្លាប់ ខៀវ ធីរ៉ាត់ ឬ? តែទោះបីជាយ៉ាងណា សាឡុត បាន នៅតែបញ្ជាក់ថាខ្លួនមិនដឹងអំពីបញ្ហាទាំងនេះ ដែលវាត្រូវបានសួរម្តងហើយម្តងទៀត ដោយភាគីផ្សេងៗកន្លងមក ។ ចំពោះការបាត់ខ្លួនលោកឃួន ដេវីតវិញសាក្សី សាឡុត បានក៏នៅតែមិនអាចបញ្ជាក់ឲ្យបានច្បាស់លាស់ដែរ ហើយសាក្សីបានផ្តល់សក្ខីកម្មជូនអង្គជំនុំជម្រះដោយភាពច្របូកច្របល់អំពីការនាំដំណឹងអំពីការបាត់ខ្លួនឃួន ដេវីត ទៅប្រាប់ ប៉ុល ពត ។ ដាក់ស្តែងដំបូង លោក សាឡុត បាន បានលើកឡើងថា ខ្លួនបានប្រាប់ ប៉ុល ពត ថាមានមនុស្សម្នាក់ឈ្មោះ ឃួន ដេវីត គឺជាមនុស្សដែលមានចំណេះដឹងខ្ពស់ ។ បន្ទាប់មក ប៉ុល ពត បានបញ្ជាលោកឲ្យទៅសួរបញ្ជាក់ឲ្យបានច្បាស់ថាតើឃួន ដេវីត ពិតជាមនុស្សមានចំណេះដឹងមែនឬអត់ ដើម្បីយកមកជួយធ្វើការ ។ បន្ទាប់ពីទទួលបានបញ្ជាដូច្នេះ លោកបានទៅជួប ប៉ង់ ហើយប្រាប់ ប៉ង់ ថា ប៉ុល ពត មានបំណងយក ឃួន ដេវីត ទៅធ្វើការជាមួយ ។ ប៉ុន្តែក្រោយមក ឃួន ដេវីត ត្រូវបានយកទៅបាត់ដោយមិនដឹងមូលហេតុ ហើយខ្លួនមិនបានយកដំណឹងនេះទៅប្រាប់ ប៉ុល ពត វិញឡើយ ។ បន្ទាប់ពីលោក សាឡុត បាន លើកឡើងដូច្នេះ លោក ខាណាវ៉ាស បានចោទសួរថា ហេតុអ្វីបានជាការបាត់ខ្លួនឃួន ដេវីត លោកមិនរាយការណ៍ឲ្យ ប៉ុល ពត ព្រោះជាមនុស្សដែល ប៉ុល ពត ចង់បាន? បន្ទាប់មកលោកមេធាវីបានបង្ហាញឯកសារមួយដែលសាក្សីធ្លាប់ផ្តល់សក្ខីកម្មជូនចៅក្រមស៊ើបអង្កេតថា "មានពេលមួយនោះប្រហែលក្នុងឆ្នាំ១៩៧៨ ខ្ញុំបានទៅតាមលោក អៀង សារី ទៅកន្លែងបឹងត្របែក ហើយបានជួបជាមួយសាស្ត្រាចារ្យម្នាក់ ជាអ្នកមានចំណេះដឹង គាត់ជាខ្មែរមកពីប្រទេសបារាំង ។ ក្រោយពីបានជួប ខ្ញុំបានរាយការណ៍ជូនឪពុកមារបស់ខ្ញុំប្រាប់គាត់ថាមនុស្សនេះជាអ្នកចេះដឹង និងស្លូតបូត ។ ប៉ុន្តែខ្ញុំត្រឡប់មករកគាត់នៅកន្លែងនោះម្តងទៀត ស្រាប់តែមនុស្សនោះបាត់ខ្លួនមិនដឹងទៅណា ។ ឈ្មោះ ហឹង អ៊ុន ដែលជាអ្នកគ្រប់គ្រងនៅទីនោះបានបញ្ជាក់ថា ជននោះត្រូវបានក្រុម ប៉ង់ យកទៅបាត់ហើយ ។ ពេលខ្ញុំបានប្រាប់ឪពុកមាខ្ញុំវិញថា មនុស្សនេះបាត់ហើយ ស្រាប់តែគាត់នៅស្ងៀមថ្ងឹងតែម្តង" ។ បន្ទាប់ពីលោក ខាណាវ៉ាស បង្ហាញឯកសារនេះ សាឡុត បាន បែរជាទទួលស្គាល់ថា ខ្លួនពិតជាបានមកប្រាប់ ប៉ុល ពត ពីការបាត់ខ្លួន ឃួន ដេវីត មែនតែមិនដឹងថាបានប្រាប់ពេលណាឡើយ ។

**២) ការសួរដេញដោលដោយក្រុមមេធាវីការពារក្តី នួន ជា ចំពោះសាក្សី សាឡុត បាន**

បន្ទាប់ពីក្រុមមេធាវីការពារក្តី អៀង សារី បានបញ្ចប់ការសួរដេញដោលលើសាក្សី សាឡុត បាន អង្គជំនុំជម្រះបានប្រគល់វេទិកាជូនក្រុមមេធាវីការពារក្តី នួន ជា ដើម្បីសួរដេញដោលអំពីភាពយល់ដឹង និងអ្វីដែលបានកើតឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ការសួរដេញដោលលើសាក្សីរូបនេះ បានចាប់ផ្តើមដោយលោកមេធាវីជាតិការពារក្តីជនជាប់ចោទ នួន ជា គឺលោកមេធាវី ស៊ុន អរុណ និងបន្ទាប់មកវេទិកាសួរដេញដោលត្រូវបានប្រគល់ជូនសហភាគារបស់លោក គឺលោកមេធាវីអន្តរជាតិ ម៉ៃឃើល ដេស្តមេន ។ មេធាវីទាំងពីររូបបានសួរផ្តោតសំខាន់លើភាពត្រឹមត្រូវរបស់ នួន ជា ក្នុងការអប់រំការពារផលប្រយោជន៍ជាតិ គោលការណ៍របស់បក្សកុម្មុយនីស្តកម្ពុជាដែលបានអប់រំថា កិច្ចការនរណាអ្នកនោះដឹង និងរឿងរាវទាក់ទងនឹងអតីតបុគ្គលិកបម្រើការនៅក្នុងក្រសួងការបរទេសនៃរបបកម្ពុជាប្រជាធិបតេយ្យ គឺលោក គាត ឈន់ និងអតីតបញ្ញាជនមកពីបរទេស គឺលោក ហោ ណាំហុង ។

**២.១) ការសួរដេញដោលដោយមេធាវី ស៊ុន អរុណ**

លោកមេធាវី ស៊ុន អរុណ បានសួរលោកសាក្សី សាឡុត

បាន ដោយចាប់ផ្ដើមជាមួយនឹងសំណួរទាក់ទងនឹងច្បាប់នៃរបបកម្ពុជាប្រជាធិបតេយ្យថាតើការអនុវត្តនៅពេលនោះមានការតឹងរឹងដែរឬទេ បើយោងតាមបទពិសោធន៍របស់សាក្សីដែលបានចូលធ្វើបដិវត្តន៍តាំងពីវ័យក្មេងជាមួយនឹងថ្នាក់ដឹកនាំធំៗនៃបក្សកុម្មុយនីស្តកម្ពុជា? មុនពេលឆ្លើយតបសំណួររបស់លោកមេធាវី អរុណ លោកសាក្សី សាឡុត បាន បានរំឭកថា លោកធ្លាប់បានជួបជាមួយ នួន ជា មួយឬពីរដងកាលពីពេលលោករស់នៅ ភូមិភាគឦសាន នៅខេត្តរតនគិរី ។ លោកសាក្សីបន្តទៀតថា លោកចូលក្នុងបក្សកុម្មុយនីស្តកម្ពុជា មិនមែនដោយសារពូរបស់ខ្លួន គឺប៉ុល ពត ឬដោយសារ នួន ជា តែម្យ៉ាងនោះទេ ។ ប៉ុន្តែអ្វីដែលសំខាន់គឺនៅពេលដែលលោកបានឮពូរបស់លោក (ប៉ុល ពត) និយាយថា នៅមុនពេលទៅរៀននៅស្រុកបារាំង ឃើញអ្នកជិតខាងមានដី១០ហិកតា ក៏ប៉ុន្តែក្រោយពេលមកពីស្រុកបារាំងវិញ ដីអ្នកទាំងនោះនៅសល់មិនដល់កន្លះហិកតាផង ។ ពាក្យនេះហើយដែលបានធ្វើឲ្យខ្លួនគិតពិចារណារហូតដល់ពេលបានជួបជាមួយ ប៉ុល ពត និង នួន ជា នៅក្នុងព្រៃ ។ ពេលជួបជាមួយ ប៉ុល ពត លោកសាក្សីបានអះអាងថា ប៉ុល ពត បានប្រគល់សៀវភៅមួយក្បាលដល់លោកតាមរយៈប៉ង់ ដែលមានចំណងជើងថា «សាមគ្គីជនជាតិក្រោមទង់បដិវត្ត» ។ ការធ្វើបដិវត្តនៅពេលនោះ គឺដើម្បីការពារទឹកដី គាំទ្រសម្ដេចតា (សម្ដេច នរោត្តម សីហនុ) រក្សាអព្យាក្រឹត្យភាពកុំឲ្យមានមូលដ្ឋានសឹកអាមេរិកនៅក្នុងប្រទេសកម្ពុជា ។ បន្ទាប់មក លោកសាក្សីបានឆ្លើយតបនឹងសំណួររបស់មេធាវីការពារក្ដីដោយខ្លីថា មិនពិតទេដែលថា ការគ្រប់គ្រងនៅពេលនោះមានការតឹងតែង ។

លោកមេធាវី អរុណ បានសួរបន្តទៀតថា តើសាក្សីស្គាល់ នួន ជា ច្បាស់ដែរឬទេ? និងថាតើធ្លាប់ជួបជាមួយ នួន ជា ប៉ុន្មានដង? លោកសាក្សីបានឆ្លើយថា លោកស្គាល់ នួន ជា ច្បាស់ និងបានជួបគ្នាជាច្រើនដង ប៉ុន្តែការជួបនោះមិនមែនជួបក្នុងគោលបំណងនិយាយពីរឿងការងារទេ ។ សាក្សីបានបន្ថែមថា នួន ជា ជាមនុស្សដែលមានចរិតសាមគ្គី និងមិនដែលធ្វើអ្វីនាំឲ្យមានការអាក់អន់ស្រពន់ចិត្តដល់រូបលោកឡើយ គឺមានតែនិយាយពីរឿងអប់រំឲ្យចេះស្រឡាញ់គ្នានៅក្នុងក្រុមដើម្បីការពារបដិវត្ត និងអប់រំពីអ្វីដែលចំណេញដល់ការតស៊ូនិងការធ្វើបដិវត្ត ។ មេធាវីបានសួរទៀតថាតើ នួន ជា ជាមនុស្សដែលមានអត្តចរិតកាចសាហាវចំពោះអ្នកដទៃដែរឬទេ? និងថាតើ នួន ជា ធ្លាប់បានបញ្ជូនមនុស្សទៅឃុំឃាំងនៅក្នុងគុកដែរឬទេ? លោកសាក្សី សាឡុត បាន បានឆ្លើយនឹងសំណួរនេះថា លោកមិនបានដឹងពីបញ្ហានេះទេ ។ លោកមេធាវីបានបន្តសួរអំពីការជំនួសតួនាទីរបស់ សុន សេន ដោយ នួន ជា នៅពេលដែល សុន សេន មានបេសកកម្មចេញទៅភូមិភាគបូព៌ា ប៉ុន្តែសាក្សីបានបដិសេធថា លោកមិនបានដឹងអំពីរឿងដែលមេធាវីកំពុងសួរនេះទេ ។ ទាក់ទងនឹងមន្ទីរស-២១ ឬគុកទួលស្លែង លោកសាក្សីបានបដិសេធថាខ្លួនមិនដែលបានដឹងពីគុកនេះឡើយ ក៏ប៉ុន្តែលោកបានទទួលស្គាល់ថា លោកបានស្គាល់ ឌុច តែស្គាល់នៅក្រោយពេលដែលទាហានវៀតណាមវាយចូលកម្ពុជារួចហើយ ។

ទាក់ទងនឹងការខ្វះខាតស្បៀងអាហារនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ លោកមេធាវី អរុណ បានសួរសាក្សីថា តើសាក្សីមានធ្លាប់បានឮប្រជាជននិយាយប្រាប់អំពីការខ្វះខាតម្ហូបអាហារហូបចុក ដែរឬទេ? ចំពោះសំណួរនេះ សាក្សីបានទទួលស្គាល់ថា លោកបានមើលឃើញអំពីការខ្វះខាតរបស់ប្រជាជននៅពេលនោះ ហើយមានប្រជាជនមួយចំនួនធ្លាប់បានប្រាប់លោកថា មិនដែលបានទទួលស្រូវដែលអង្គការសន្យាថាផ្ដល់ជូនប្រជាជនមួយអាទិត្យម្ដងនោះទេ ។ មានប្រជាជនខ្លះទៀតបានសួរលោកថាតើស្រូវដែលធ្វើបានយ៉ាងច្រើននោះគេដឹកយកទៅណាអស់ហើយ? ជាងនេះទៅទៀត សូម្បីតែឪពុកម្ដាយលោកក៏មិនដែលទទួលបានបបរ អង្ករ ឬបង្អែម ដែលអង្គការបានសន្យាថានឹងផ្ដល់ជូននោះទេ ។ លោកសាក្សីបានពន្យល់ថា លោកយល់ថាការដែលខ្វះខាតស្បៀង គឺដោយសារតែមានអ្នកដែលចង់ដុតឲ្យខ្លោច និងបំផ្លាញអង្គការ ដោយលោកចង់សំដៅលើប្រទេសវៀតណាមដែលអៀនខ្មាសនឹងបក្សកុម្មុយនីស្តកម្ពុជារំដោះបានទីក្រុងភ្នំពេញ មុនបក្សកុម្មុយនីស្តវៀតណាម ។

ពាក់ព័ន្ធនឹងគម្រោងជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ សាក្សីបានពន្យល់ថា លោកធ្លាប់ ឮបងប្អូនកងទ័ពបដិវត្តនិយាយថា បក្សកុម្មុយនីស្តកម្ពុជាឲ្យប្រជាជនចេញពីទីក្រុងភ្នំពេញគឺដោយសារតែមានចារកម្មរបស់ចក្រពត្តិអាមេរិកច្រើនម៉ឺននាក់នៅក្នុងទីក្រុងមានទាំងប្រុសទាំងស្រី និងថាបើកងទ័ពនេះចូលមកទីក្រុងដោយ

មិនយល់ពីបញ្ហានេះ នឹងធ្លាក់ចូលអន្ទាក់របស់ចារកម្ម ។ ម្យ៉ាងវិញទៀត លោក សាក្សីបានពុថា អាមេរិកមានផែនការមួយទៀតដែលគេហៅថា "ផែនការចាញ់" ។ ផែនការចាញ់នេះ គឺត្រូវបានសាក្សីពន្យល់ថាគឺជាផែនការទម្លាក់គ្រាប់បែករបស់អាមេរិកនៅក្នុងទីក្រុង ។ ដូច្នេះនយោបាយរបស់បក្ស គឺត្រូវតែជម្លៀសប្រជាជនចេញ ។ បន្ទាប់មកលោកមេធាវី អរុណ បានសួរសាក្សីអំពីស្ថានភាពប្រទេសកម្ពុជានៅក្រោយពេលដែលសម្តេច នរោត្តម សីហនុ ត្រូវបានធ្លាក់ពីតំណែងដោយសារការធ្វើរដ្ឋប្រហារដោយលោក លន់ នល់ គឺពីចន្លោះឆ្នាំ១៩៧០ដល់១៩៧៥ ។ សាក្សីបានអះអាងថា ប្រទេសកម្ពុជានៅពេលនោះ ស្ថិតនៅក្នុងស្ថានភាពលំបាកណាស់ គឺបាតដៃទទេ ។ រហូតដល់ឆ្នាំ១៩៧៥ ទើបប្រទេសកម្ពុជាត្រូវបានរំដោះ ហើយការរំដោះប្រទេសនៅពេលនោះក៏ធ្វើឡើងដោយបាតដៃទទេដូចគ្នាដែរ ព្រោះមិនមានទូរស័ព្ទដើម្បីទាក់ទងគ្នាទេ ការទាក់ទងធ្វើឡើងតាមរយៈសំបុត្រ ដោយត្រូវជិះសេះ កង់ ឬម៉ូតូ ដើម្បីបញ្ជូនសំបុត្រនោះឲ្យគ្នា ។

លោកមេធាវី ស៊ិន អរុណ បានសួរសាក្សីទៀតថា តើលោកមានបានរត់ទៅជាមួយពូរបស់លោក(ប៉ុល ពត) ដែរឬទេ នៅពេលវៀតណាមចូលមកប្រទេសកម្ពុជា? សាក្សីបានឆ្លើយថា ភារកិច្ចរបស់ខ្លួននៅក្រសួងការបរទេស គឺមើលថែទាំបញ្ញាជន និងក្មេងៗដែលត្រៀមរៀនសូត្រមានចំនួនប្រហែលមួយពាន់នាក់ ត្រូវធ្វើយ៉ាងណាជម្លៀសអ្នកទាំងនោះចេញឲ្យផុតដោយសារខ្លាចមានគ្រោះថ្នាក់ ។ លោកបញ្ជាក់ថា ការជម្លៀសនេះគឺធ្វើឡើងដោយការប្រាប់អ្នកទាំងនោះថា គ្រាន់តែចេញទៅរយៈពេលពីរអាទិត្យតែប៉ុណ្ណោះនឹងត្រឡប់មកវិញហើយ ។ ក៏ប៉ុន្តែចាប់តាំងពីការចូលមកដល់នៃកងទ័ពវៀតណាម មិនមានការវិលត្រឡប់ទៅវិញឡើយ ។ សាក្សីបានបន្ថែមថា លោកបានជួបនឹងពូរបស់លោក គឺប្រហែលមួយឆ្នាំក្រោយពេលវៀតណាមវាយចូលកម្ពុជា ក៏ប៉ុន្តែមិនបានរស់នៅជាមួយគ្នានោះទេ ព្រោះទីលំនៅអចិន្ត្រៃយ៍របស់លោកគឺនៅតំបន់១០២(ស្រុកម៉ាឡៃ) ។ ឆ្លើយតបនឹងសំណួររបស់មេធាវីទាក់ទងនឹងការជួបប្រជុំជាមួយនឹង ប៉ុល ពត នៅអំឡុងពេលដែលប៉ុល ពត ឈឺធ្ងន់ លោកសាក្សីបានរំឭកថា នៅមុនពេលស្លាប់ ប៉ុល ពត បានកោះហៅអ្នករាល់គ្នាឲ្យមកចូលរួមប្រជុំ ហើយ ប៉ុល ពត បានប្រាប់លោកថា ត្រូវមានការប្រុងប្រយ័ត្ន និងត្រូវមកជួបតែពេលណាដែលខ្លួនហៅឲ្យមកបានហើយ នៅពេលណាមិនមានការកោះហៅ មិនត្រូវមកជាដាច់ខាត ព្រោះសភាពការណ៍មិនស្រួលឡើយនៅពេលនោះ ។ បន្ទាប់មកលោកមេធាវីបានសួរសាក្សីទៀតថា តើធ្លាប់បានជួបជាមួយនឹង ប៉ុល ពត នាពេលបន្ទាប់មកទៀតឬទេ? លោកសាក្សីបានឆ្លើយថា លោកបានជួបត្រឹមតែផ្នូររបស់ ប៉ុល ពត ប៉ុណ្ណោះ ។

លោកមេធាវី អរុណ បានបន្តសួរសាក្សីដោយលើកយកឯកសារមួយដែលមានកត់ត្រាសម្តីសាក្សីទាក់ទងនឹងតួនាទីរបស់ប៉ុល ពត និង នួន ជា ដែលបានអះអាងថា នៅពេលនោះ ប៉ុល ពត មានតួនាទីខាងនយោបាយ រីឯ នួន ជា មានតួនាទីខាងចាត់តាំង ។ លោកមេធាវីបានស្នើឲ្យសាក្សីធ្វើការបញ្ជាក់អំពីចំណុចនេះ ។ លោក សាឡុត បាន បានឆ្លើយតបនឹងសំណើនេះថា លោកបានដឹងរឿងនេះតាមរយៈ ប៉ន់ ប៉ុន្តែលោកមិនអាចបញ្ជាក់ពីតួនាទីជាក់លាក់របស់ នួន ជា ឡើយ ។ បន្ទាប់ពីសំណួរនេះ លោកមេធាវី ស៊ិន អរុណ បានប្រគល់វេទិកាជូនសហភាគីរបស់ខ្លួន គឺលោកមេធាវីអន្តរជាតិ ម៉ៃឃើល ដេស្គមេន ដើម្បីបន្តសួរដេញដោលលើសាក្សី ។

**ខ.២) ការសួរដេញដោលដោយមេធាវី ម៉ៃឃើល ដេស្គមេន**


ម៉ៃឃើល ដេស្គមេន

លោកមេធាវីអន្តរជាតិការពារក្តីឲ្យ នួន ជា គឺលោក ដេស្គមេន បានបន្តសួរសាក្សីដោយផ្តោតជាបឋមលើការលើកឡើងរបស់លោកសាក្សី សាឡុត បាន ចំពោះសម្តីរបស់លោក

ទាក់ទងនឹងសំណុំរឿង០០០ ។ លោកមេធាវី ផេស្តមេន បានស្នើឲ្យលោកសាក្សីធ្វើការបញ្ជាក់ថា តើនរណាគួរតែត្រូវបានចោទប្រកាន់នៅក្នុងសំណុំរឿង០០០ ។ លោកសាក្សីបានឆ្លើយតបនៅត្រង់ចំណុចនេះថា ៖

«ថ្ងៃមុនខ្ញុំមិនចាំម៉ោងចាំពេលទេ ខ្ញុំបានថា ខ្ញុំសមាធិទៅលោកតាដំបងដែកប្រាប់ខ្ញុំថា សម្តីជាឯកណាចៅ លេខជាទោអក្សរជាត្រី ។ ០០០ ជាអ្វីម៉េចក៏មិនគិតផង នេះខ្ញុំបាននិយាយដូច្នេះ ។ ដូច្នេះខ្ញុំគិតថា ខ្ញុំសួរខ្លួនឯងថា មុននឹងមានលេខ០០១ មានអីពីមុនហ្នឹងទៀត ខ្ញុំថា មុន០០១ គឺលេខ០០០នេះឯង ។ បានន័យថា០០០នេះគឺជាមេបង្ក ។ សូន្យទី១ គេហៅថា សូន្យកង សូន្យទី២ គេហៅថា សូន្យកាក សូន្យទី៣ គេហៅថា សូន្យក ។»

លោកសាក្សី បានហៅសូន្យទាំងបីនេះថា គឺជាសូន្យកាកក និងថាសូន្យទាំងបីនោះគឺជាដើមហេតុ នៃការបង្កើតរឿងទាំងអស់ឡើង ។ លោកបានបន្តទៀតថា «ខ្មែរក្រហមដូចខ្ញុំនេះ មិនចង់រស់នៅក្នុងព្រៃទេ មិនចង់លំបាកទេ វាលំបាកណាស់ការតស៊ូ ការប្រឆាំង ការធ្វើសង្គ្រាម ។ គេទេតើ គេបង្កសង្គ្រាមឲ្យខ្ញុំធ្វើខ្មែរក្រហម ហើយខ្មែរក្រហមនេះ ខ្ញុំមិនមែនដាក់ឈ្មោះខ្លួនឯងផង មិនដឹងនរណាដាក់ផង ។ ខ្ញុំជាជនតស៊ូទេតើ ខ្ញុំជាយុទ្ធជនដើម្បីរំដោះជាតិទេតើ» ។ លោកបានបញ្ជាក់ថា អត្ថន័យនៃពាក្យ០០០ គឺអារម្មណ៍របស់លោកជាអ្នកនាំឲ្យយល់ឃើញដូច្នេះ ។ បន្ទាប់ពីការបកស្រាយរបស់សាក្សី លោកមេធាវី ផេស្តមេន បានសួរបន្តថា តើសាក្សីចង់សំដៅនរណាជាមេបង្កើតឲ្យមានបញ្ហា? តើប្រទេសវៀតណាម ឬសហរដ្ឋអាមេរិក? សាក្សីបានឆ្លើយតបថា លោកមិនបានចោទប្រកាន់ប្រទេសវៀតណាម ឬអាមេរិកទេ ប៉ុន្តែលោកបាននិយាយពីរឿងច្បាប់ព្រហ្មទណ្ឌថា បើធ្វើអ្វីខុសពីច្បាប់ព្រហ្ម ឬដំបូន្មានរបស់ព្រហ្មហើយ គឺអ្នកនោះត្រូវមានទណ្ឌកម្ម ។ លោកបានពន្យល់ទៀតថា ព្រហ្ម គឺជាពុទ្ធិ ហើយព្រហ្មគឺជាអ្នកបង្កើតមនុស្ស ហើយមនុស្សកើតចេញពី ទឹក ដី ខ្យល់ ភ្លើង ។ ដូច្នេះអ្នកដែលបំផ្លាញ ទឹក ដី ខ្យល់ ភ្លើងនេះហើយ ដែលជាមេបង្ករឿង ។ ប៉ុន្តែបន្ទាប់ពីសាក្សីបានឆ្លើយតបនឹងសំណួរនេះ លោកប្រធានអង្គជំនុំជម្រះ និល ណុន បានបង្គាប់ទៅមេធាវីការពារក្តីឲ្យរៀបចំសំណួរឡើងវិញ ដោយសារសំណួរដែលមេធាវីបានសួរ និងចម្លើយដែលសាក្សីបានឆ្លើយមិនមានជាប់ពាក់ព័ន្ធនឹងអង្គហេតុដែលកំពុងចោទប្រកាន់ទេ ។

លោកមេធាវី ផេស្តមេន បានបន្តការសួរដេញដោលរបស់ខ្លួន ដោយស្នើសុំអង្គជំនុំជម្រះដើម្បីបង្ហាញឯកសារមួយទាក់ទងនឹងសេចក្តីប្រកាសព័ត៌មានក្រោយពីដំណើរទស្សនកិច្ចរបស់សម្តេចនរោត្តម សីហនុ នៅប្រទេសវៀតណាមក្នុងឆ្នាំ១៩៧២ ។ បន្ទាប់មកលោកមេធាវីបានសួរសាក្សីថាតើសាក្សីមានបានដឹងពីដំណើរទស្សនកិច្ចនោះដែរឬទេ? សាក្សីបានឆ្លើយថា លោកមិនបានដឹងអំពីដំណើរទស្សនកិច្ចនោះឡើយ ។ លោកមេធាវីបានបន្តសួរទៀតថាតើសាក្សីស្គាល់ឈ្មោះ គាត ឈន់ ដែរឬទេ? សាក្សីបានឆ្លើយតបនឹងសំណួរនេះថាខ្លួនស្គាល់លោក គាត ឈន់ ប៉ុន្តែលោកមិនបានដឹងអំពីតួនាទីរបស់ លោក គាត ឈន់ នៅក្នុងក្រសួងការបរទេសឡើយ គឺគ្រាន់តែដឹងថាស្ថិតនៅខាងផ្នែកបញ្ញាជន ។ លោកសាក្សីបានបន្តទៀតថាខ្លួនដឹងថាលោក គាត ឈន់ ធ្លាប់ត្រូវបានចោទនៅក្នុងចម្លើយសារភាព ពេលនោះ អៀង សារី បាននិយាយការពារលោក គាត ឈន់ ថាប្រសិនបើមានការចាប់ខ្លួនលោក គាត ឈន់ ក្រសួងការបរទេសនឹងឈប់ដំណើរការ ។ លោកមេធាវីបានស្នើឲ្យសាក្សីពន្យល់ពីមូលហេតុដែលក្រសួងការបរទេសមិនដំណើរការក្នុងករណីដែលមានការដកលោក គាត ឈន់ ចេញ ។ សាក្សីបានឆ្លើយតបថា លោកមិនបានដឹងពីហេតុផលរបស់ អៀង សារី ទេ ។

លោកមេធាវី ផេស្តមេន បានសួរលោកសាក្សី សាឡុត បានដោយរំឭកអំពីសេចក្តីថ្លែងការណ៍ផ្លូវការចេញដោយក្រសួងការបរទេស ដែលបានប្រកាសផ្តាច់ទំនាក់ទំនងការទូតចេញពីប្រទេសវៀតណាម ។ លោកសាក្សីបាននិយាយថា លោកបានចាំអំពីសេចក្តីថ្លែងការណ៍នោះ ប៉ុន្តែលោកមិនចាំថាតើនរណាជាអ្នកសរសេរសេចក្តីថ្លែងការណ៍នោះទេ ។ លោកមេធាវីបានលើកយកឯកសារដែលសាក្សីធ្លាប់បានផ្តល់ចម្លើយដល់ការិយាល័យសហចៅក្រមស៊ើបអង្កេតថា លោក គាត ឈន់ ប្រហែលជាមនុស្សម្នាក់ដែលបានសរសេរសេចក្តីថ្លែងការណ៍នោះ ។ ប៉ុន្តែសាក្សីបានបញ្ជាក់ថា លោកគ្រាន់តែបានដឹងថា លោក គាត ឈន់ គឺជាអ្នកដែលសរសេរសុន្ទរកថា មិនមែនសេចក្តីថ្លែងការណ៍ជាក់លាក់នោះទេ ។ បន្ទាប់មកលោកមេធាវី ផេស្តមេន បានបង្ហាញឯកសារមួយផ្សេងទៀតទាក់ទងនឹងកំណត់ហេតុលាយលក្ខណ៍អក្សរមួយរបស់

សម្តេច នរោត្តម សីហនុ ដែលបានផ្ញើជូនអគ្គលេខាធិការអង្គការសហប្រជាជាតិនៅទីក្រុងញូវយ៉ក នាឆ្នាំ១៩៧៥ ដើម្បីស្នើសុំឲ្យសាក្សីធ្វើការបញ្ជាក់ ។ ប៉ុន្តែលោកសាក្សី សាឡុត បាន បានអះអាងថាលោកមិនដែលបានឃើញឯកសារនោះពីមុនទេ ។

លោកមេធាវី ដេស្តមេន បានបន្តសំណួររបស់ខ្លួនទាក់ទងនឹងលោក គាត ឈន់ ដោយការសួរសាក្សីថាតើសាក្សីដឹងទេថាលោក គាត ឈន់ បានធ្វើដំណើរទៅជួបអគ្គលេខាធិការអង្គការសហប្រជាជាតិជាមួយនឹងសម្តេច នរោត្តម សីហនុ នៅឆ្នាំ១៩៧៥? សំណួរនេះត្រូវបានលោកប្រធានអង្គជំនុំជម្រះណែនាំមិនឲ្យសាក្សីឆ្លើយតប ដោយសារតែវាគឺជាសំណួរមិនទាក់ទងនឹងអង្គហេតុដែលត្រូវលើកយកមកសួរដេញដោល ។ បន្ទាប់មកលោកមេធាវីបានស្នើសុំអង្គជំនុំជម្រះដាក់បង្ហាញ ឯកសារផ្សេងមួយទៀតជូនសាក្សីដើម្បីធ្វើការបញ្ជាក់ ។ សំណើនេះមិនត្រូវបានអនុញ្ញាតភ្លាមៗទេ ដោយលោកប្រធានអង្គជំនុំជម្រះ និល ណុន បង្គាប់ឲ្យលោកមេធាវីបង្ហាញឯកសារនោះជូនអង្គជំនុំជម្រះពិនិត្យជាមុនសិន ដើម្បីធ្វើឲ្យប្រាកដថាឯកសារដែលស្នើនោះមានភាពជាប់ពាក់ព័ន្ធនឹងអង្គហេតុ និងត្រឹមត្រូវតាមនីតិវិធីច្បាប់ដែរឬយ៉ាងណា ។ លោកមេធាវី ដេស្តមេន ជម្រាបអង្គជំនុំជម្រះវិញថាឯកសារនោះគឺជាសម្ភីរបស់សាក្សីដែលសហព្រះរាជអាជ្ញាធ្លាប់បានយកឯកសារនោះទៅសួរសាក្សី ។ ក្រោយពីទទួលបានការពន្យល់ពីលោកមេធាវី អង្គជំនុំជម្រះបានសម្រេចអនុញ្ញាតបង្ហាញឯកសារនោះ ។ បន្ទាប់ពីឃើញឯកសារនោះហើយលោកសាក្សីបានបដិសេធថាខ្លួនមិនធ្លាប់ឃើញឯកសារទាំងនោះពីមុនមកទេ ។ ទោះបីជា សាក្សីបានបដិសេធថាមិនធ្លាប់បានឃើញឯកសារនោះពីមុនក៏ដោយ លោកមេធាវី ដេស្តមេន នៅតែរំឭកសាក្សីថាឯកសារនោះគឺធ្លាប់ត្រូវបានបង្ហាញជូនសាក្សីម្តងរួចមកហើយកាលពីឆ្នាំ២០០៧ ដោយការិយាល័យសហចៅក្រមស៊ើបអង្កេត ។ លោកសាក្សីនៅតែបដិសេធថា ខ្លួនមិនដែលឃើញឯកសារនោះពីមុនទេ តែទទួលស្គាល់ថា ហត្ថលេខាដែលមាននៅលើឯកសារនោះគឺជារបស់លោកប្រាកដមែន ។ លោកមេធាវី ដេស្តមេន បានឈានទៅសំណួរថ្មីទាក់ទងនឹងលោក ហោ ណាំហុង ដោយបានចោទជាសំណួរថា តើលោក ហោ ណាំហុង ធ្វើជាអ្នកការទូតនៅប្រទេសគុយបា នៅមុនពេលមកធ្វើការនៅមន្ទីរប-១ ឬយ៉ាងណា? លោកសាក្សីបានឆ្លើយថា លោក ហោ ណាំហុង ពិតជាធ្លាប់បានធ្វើការជាអ្នកការទូតនៅប្រទេសគុយបា ហើយត្រឡប់មកធ្វើការនៅមន្ទីរប-១ បានមួយរយៈពេលខ្លីតែប៉ុណ្ណោះ គឺខ្លីជាងរយៈពេលដែលលោក ហោ ណាំហុង ធ្វើការនៅមន្ទីរបឹងត្របែក ។ លោកសាក្សីបានបដិសេធថា ខ្លួនមិនធ្លាប់បានឮថាលោក ហោ ណាំហុង មានតួនាទីធ្វើជាប្រធាននៅមន្ទីរបឹងត្របែកឡើយ ។ បន្ទាប់មកមេធាវីបានបន្តសួរសាក្សីទៀតថា ហេតុអ្វីបានជាលោក ហោ ណាំហុង ត្រូវបានផ្តល់ផ្ទះមួយល្វែងនៅជិតវិមានឯករាជ្យនៅអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ? លោក សាឡុត បាន ឆ្លើយតបនឹងសំណួរនេះថា ដោយសារសភាពការណ៍ប្រែប្រួល ព្រោះពេលនោះវៀតណាមបានវាយលុកចូលមកជិតដល់ភ្នំពេញ ។ ម្យ៉ាងវិញទៀត ប៉ង់ ក៏បានបាត់ខ្លួន ។ ដូច្នេះក្រសួងការបរទេសបានបញ្ជាឲ្យឈ្មោះ ជាម នាំលោក ហោ ណាំហុង ទៅរស់នៅក្នុងវីឡាមួយនៅជិតវិមានឯករាជ្យ ។ លោកមេធាវីសួរបន្តថាតើអ្នកដែលគេឃុំខ្លួនឬអ្នកដែលគេទុកនៅមន្ទីរបឹងត្របែកទាំងអស់សុទ្ធតែទទួលបានផ្ទះនៅជិតវិមានឯករាជ្យទាំងអស់គ្នាឬយ៉ាងណា? សាក្សីបានឆ្លើយថាពេលនោះមានលោក ហោ ណាំហុង និងលោក សារិន ឆាក គឺរស់នៅផ្ទះវីឡា រីឯអ្នកដទៃទៀតបក្សកុម្មុយនីស្តកម្ពុជាមានគម្រោងឲ្យចូលធ្វើការនៅក្រសួងការបរទេស ឬធ្វើជាគ្រូបង្រៀនក្មេងៗនៅសាលាបច្ចេកទេសសូវៀតសព្វថ្ងៃ ។ មេធាវីសួរទៀតថា ហេតុអ្វីបានជាលោក ហោ ណាំហុង ត្រូវបានទទួលការមើលថែយ៉ាងល្អដូច្នេះ? លោកសាក្សីបានឆ្លើយនឹងសំណួរនេះដោយខ្លីថា លោកមិនបានដឹងអំពីរឿងនេះទេ ។ លោកមេធាវី ដេស្តមេន បានសួរសាក្សីបញ្ជាក់ថា តើលោកសាក្សីធ្លាប់បានទាក់ទងជាមួយនឹងលោក គាត ឈន់ និងលោក ហោ ណាំហុង នៅក្រោយឆ្នាំ១៩៧៩ដែរឬទេ? សាក្សីបានឆ្លើយតបដោយសម្តីម៉ឺងម៉ាត់ថា លោកមិនដែលបានទាក់ទងនឹងអ្នកទាំងពីរនេះទេ ។ លោកមេធាវីសួរបន្តថាតើសាក្សីខ្លាចអ្នកទាំងពីរនាក់នោះដែរឬទេ? លោកសាក្សីបានឆ្លើយថា លោកមិនខ្លាចទេ ។ បន្ទាប់មកលោកមេធាវីបានសួរសាក្សីទាក់ទងនឹងការកោះហៅលោក គាត ឈន់ និងលោក ហោ ណាំហុង មកផ្តល់សក្ខីកម្មដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិ ប៉ុន្តែ

សំណួរនេះត្រូវបានលោកប្រធានអង្គជំនុំជម្រះមិនអនុញ្ញាតឲ្យសាក្សីឆ្លើយតបឡើយ ។ លោកប្រធានអង្គជំនុំជម្រះ និល ណុន បានផ្តល់ហេតុផលថា សាក្សីមិនមានភារកិច្ចដើម្បីចូលមើលសំណុំរឿងទេ ហើយសាក្សីអាចឆ្លើយបានត្រឹមតែអ្វីដែលខ្លួនបានដឹងពីសម័យកាលនោះតែប៉ុណ្ណោះ ។ លោកមេធាវី ជេស្តមេន នៅតែព្យាយាមពន្យល់អង្គជំនុំជម្រះអំពីការជ្រៀតជ្រែកពីខាងនយោបាយរបស់រាជរដ្ឋាភិបាលដែលគួរតែមានការស៊ើបអង្កេត និងថាសាក្សីប្រហែលជាអាចដឹងអំពីបញ្ហានេះ ។ ក៏ប៉ុន្តែការពន្យល់នេះមិនត្រូវបានទទួលយកដោយអង្គជំនុំជម្រះឡើយ ហើយលោកប្រធានអង្គជំនុំជម្រះលោកចៅក្រម និល ណុន បានប្រាប់ទៅមេធាវីការពារក្តីវិញថាសវនាការ ដែលកំពុងដំណើរការមិនមែនជាសវនាការស្តីពីការជ្រៀតជ្រែកផ្នែកនយោបាយឡើយ ប៉ុន្តែគឺជាសវនាការលើអង្គសេចក្តី ។ បន្ទាប់ពីការធ្វើអន្តរាគមន៍របស់អង្គជំនុំជម្រះ លោកមេធាវី ជេស្តមេន បានបន្តសំណួររបស់ខ្លួនទៀតថា តើសាក្សីបានដឹងទេថា ហេតុអ្វីបានជាលោក គាត ឈន់ និងលោក ហោ ណាំហុង បដិសេធមិនព្រមចូលមកផ្តល់សក្ខីកម្មនៅក្នុងតុលាការនេះដែរឬទេ? ជាថ្មីម្តងទៀតអង្គជំនុំជម្រះនៅតែមិនអនុញ្ញាតឲ្យសាក្សីឆ្លើយតបនឹងសំណួរនេះ ដោយអះអាងថានេះជាសំណួរដែលមិនជាប់ពាក់ព័ន្ធនឹងអង្គហេតុនៃសវនាការនេះ ។ លោកមេធាវីនៅតែបន្តសួរសំណួរស្រដៀងគ្នា ហើយអង្គជំនុំជម្រះនៅតែបង្គាប់មិនឲ្យសាក្សីឆ្លើយតបនឹងសំណួររបស់មេធាវី រហូតដល់មានការជំទាស់របស់តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ និងការជំទាស់របស់លោកមេធាវីជាតិនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីជាតិ ពេជ អង្គ ។ ការជំទាស់នេះបានសំអាងទៅលើហេតុផលថា សំណួររបស់មេធាវីការពារក្តីមិនជាប់ទាក់ទងនឹងអង្គហេតុ និងចំណាយពេលវេលាដោយមិនមានប្រសិទ្ធិភាព ដែលធ្វើឲ្យប៉ះពាល់ដល់ពេលវេលារបស់ក្រុមមេធាវីការពារក្តីដទៃ ។ បន្ទាប់មកលោកមេធាវីបានសួរសំណួរចុងក្រោយរបស់ខ្លួនថាតើសាក្សីអាចបញ្ជាក់បានទេថា លោក ហោ ណាំហុង និងលោក គាត ឈន់ មានឆន្ទៈក្នុងការចូលរួមផ្តល់សក្ខីកម្មនៅក្នុងសវនាការដែរឬយ៉ាងណា? សំណួរនេះនៅតែត្រូវបានរារាំងដោយអង្គជំនុំជម្រះ ហើយមិនអនុញ្ញាតឲ្យសាក្សីឆ្លើយតបឡើយ ។ បន្ទាប់មកក្រុមមេធាវីការពារក្តីជនជាប់ចោទ នួន ជា បានបញ្ចប់ការសួរដេញដោលរបស់ខ្លួន ហើយអង្គជំនុំជម្រះបានប្រគល់វេទិកាជូនក្រុមមេធាវីការពារក្តី ខៀវ សំផន ដើម្បីសាកសួរដេញដោលសាក្សី ។

**៣) ការសួរដេញដោលដោយក្រុមមេធាវីការពារក្តី ខៀវ សំផន ចំពោះសាក្សី សាឡុត បាន**

ក្រុមមេធាវីការពារក្តី ខៀវ សំផន បានសួរផ្តោតជាសំខាន់លើការយល់ដឹងរបស់សាក្សីអំពីតួនាទីកូនក្តីរបស់ខ្លួន ដែលក្រុមមេធាវី ខៀវ សំផន ចាត់ទុកថា កូនក្តីរបស់ខ្លួនមានតែតួនាទីខ្ពស់ ប៉ុន្តែមិនមានអំណាចក្នុងការសម្រេចអ្វីទាំងអស់ ។ បន្ថែមពីលើនេះ ក្រុមមេធាវីការពារ ខៀវ សំផន បានសួរដេញដោលសាក្សីអំពីគោលការណ៍រក្សាការសម្ងាត់របស់បក្ស ដែលត្រូវបានបក្សកុម្មុយនីស្តចាត់ទុកថាជាបញ្ហាអត្ថិភាព និងចាំបាច់ត្រូវមានការអប់រំជាប្រចាំ ។ គោលបំណងនៃការសួរដេញដោលរបស់ក្រុមមេធាវីការពារក្តី ខៀវ សំផន គឺដើម្បីបង្ហាញអង្គជំនុំជម្រះថាកូនក្តីរបស់ខ្លួនមិនបានដឹង និងមិនមានអំណាចនៅក្នុងការសម្រេចកិច្ចការផ្សេងៗរបស់បក្សកុម្មុយនីស្តកម្ពុជា ។ គួរកត់សម្គាល់ថា សម្រាប់ក្រុមមេធាវីការពារក្តី ខៀវ សំផន គឺមានតែមេធាវីជាតិ គឺលោក គង់ សំអុន ម្នាក់ប៉ុណ្ណោះ ដែលបានសួរដេញដោលលើសាក្សី រីឯសហមេធាវីបរទេសមិនបានចោទសំណួរទៅលើសាក្សី សាឡុត បាន ឡើយ ។

លោកមេធាវីជាតិ គង់ សំអុន បានចាប់ផ្តើមសំណួរដំបូងរបស់ខ្លួនទាក់ទងនឹងតួនាទីរបស់សាក្សីនៅអំឡុងពេលដែលលោកធ្វើជាកងការពាររបស់ ប៉ុល ពត នៅដើមឆ្នាំ១៩៧៥ និងបានស្នើឲ្យលោកសាក្សីបញ្ជាក់អំពីឈ្មោះរបស់កងការពារផ្សេងទៀត និងអ្នកដាំបាយរបស់ ប៉ុល ពត ។ លោកសាក្សីបានបញ្ជាក់ថា បើតាមលោកចាំ អ្នកដាំបាយឲ្យពូរបស់លោក (ប៉ុល ពត) មានប្រពន្ធរបស់លោក សាក្សីផ្ទាល់ និងប្រពន្ធរបស់ នួន ជា ។ រីឯកងការពាររបស់ ប៉ុល ពត មានឈ្មោះ លីន និងឈ្មោះ គាន ដែលស្ថិតក្រោមការគ្រប់គ្រងរបស់ ប៉ង់ ។ លោកបានបញ្ជាក់បន្ថែមថា កងការពាររបស់ ប៉ុល ពត នៅមានពីរ ឬបីនាក់ផ្សេងទៀត ប៉ុន្តែអ្នកទាំងអស់នោះបានស្លាប់អស់ទៅហើយ ។ លោកមេធាវី សំអុន បានសួរសំណួរបន្តទៀតថាតើនៅមុនការរំដោះទីក្រុងភ្នំពេញនៅខែមេសា ឆ្នាំ

១៩៧៥ ប៉ុល ពត បានផ្លាស់ប្តូរទីតាំងកន្លែងធ្វើការរបស់ខ្លួនប៉ុន្មានដង? លោកសាក្សីបានឆ្លើយថា ការផ្លាស់ប្តូរទីតាំងធ្វើឡើងប្រហែលជាពីរឬបីដង ហើយទីតាំងចុងក្រោយដែលត្រូវបានផ្លាស់ទី គឺអាចធ្វើឡើងនៅក្នុងឆ្នាំ១៩៧៣ឬ១៩៧៤ ។ លោកសាក្សីបានពន្យល់បន្ថែមថា ការផ្លាស់ទីតាំងទៅមូលដ្ឋានចុងក្រោយនេះ គឺដើម្បីចូលឲ្យកាន់តែជិតទីងបញ្ជាការកងទ័ពនៅទីក្រុងភ្នំពេញ និងដើម្បីភាពងាយស្រួលដល់ការជួបប្រជុំជាមួយនឹងកម្មាភិបាល ព្រោះវាមានទីតាំងស្ថិតនៅចំចំណុចកណ្តាល ។ បន្ទាប់មកលោកមេធាវីបានស្នើឲ្យលោកសាក្សីធ្វើការបញ្ជាក់ថា ហេតុអ្វីបានជាខ្មែរក្រហមជ្រើសរើសយកទីតាំងបញ្ជាការនៅក្នុងព្រៃ? លោកសាក្សីបានបញ្ជាក់យ៉ាងខ្លីថា គឺដើម្បីរក្សាការណ៍សម្ងាត់ឲ្យបានល្អ ។ ចំពោះស្ថានភាពទីតាំងនៅក្នុងព្រៃនោះ ត្រូវបានលោកសាក្សីរៀបរាប់ថា គឺគ្រាន់តែជាកូនខ្ទមតូចមួយ ប្រក់ស្លឹកពីខាងលើដែលអាចអង្គុយនិយាយគ្នាបាន ។ លោកបានបន្ថែមទៀតថា នៅពេលដែលមានភ្ញៀវទៅទីនោះ ដូចជា នួន ជា ខៀវ សំផន ឬអៀង សារី ពួកគេតែងតែរៀបចំខ្ទមតូចៗទាំងនោះដើម្បីឲ្យ ប៉ុល ពត ប្រជុំ ។


គង់ សំអុន

លោកមេធាវី គង់ សំអុន បានបន្តសំណួររបស់ខ្លួនដោយរំឭកសម្តីរបស់សាក្សីដែលបានឆ្លើយតបនឹងសហព្រះរាជអាជ្ញាថា ប៉ុល ពត ធ្លាប់បានប្រជុំជាមួយនឹងប្រធានភូមិភាគមួយរូប ឬពីររូបប៉ុណ្ណោះ មិនមានការប្រជុំធំដុំណាមួយឡើយ ។ បន្ទាប់មកលោកមេធាវីបានស្នើឲ្យលោកសាក្សីធ្វើការបញ្ជាក់ថាតើប្រធានភូមិភាគទាំងនោះចង់សំដៅលើសមាជិកគណៈភូមិភាគ លេខ ឬអនុលេខ? សាក្សីបានឆ្លើយតបនឹងសំណួរនេះថា នៅក្នុងគណៈភូមិភាគនោះមានប្រធានភូមិភាគ និងអនុប្រធានភូមិភាគម្នាក់ឬពីរនាក់ប៉ុណ្ណោះ ដែលអ្នកទាំងនោះទទួលភារកិច្ចគ្រប់ផ្នែកទាំងអស់រួមទាំងផ្នែកយោធាផង ។

លោកមេធាវីបានបន្តសួរសាក្សីអំពីបទសម្ភាសន៍ដែលសាក្សីបានធ្វើជាមួយនឹងការិយាល័យសហចៅក្រមស៊ើបអង្កេតនៅថ្ងៃទី៧ ខែមេសា ឆ្នាំ២០១០ ទាក់ទងនឹងតួនាទីរបស់ ខៀវ សំផន ដោយបញ្ជាក់ថា ខៀវ សំផន មិនមែនជាសមាជិកអចិន្ត្រៃយ៍ និងបញ្ជាក់ថា ខៀវ សំផន ជាប្រធានគណៈប្រធានរដ្ឋ ។ បន្ទាប់មកលោកមេធាវីបានសួរថា តើលោកសាក្សីនៅចងចាំអំពីចំណុចទាំងអស់នោះដែរឬទេ? សាក្សីបានឆ្លើយថា លោកចាំ ។ លោកមេធាវីបានបង្ហាញឯកសារជូនសាក្សីទាក់ទងនឹងបទសម្ភាសន៍របស់លោកសាក្សី សាឡុត បាន បន្ទាប់មកលោកមេធាវីបានស្នើសាក្សីឲ្យអានឃ្លាមួយនៃឯកសារនោះ ដែលមានអត្ថន័យថា ប្រធានគណៈប្រធានរដ្ឋមិនមានសិទ្ធិអំណាចអ្វីឡើយ ។ លោកសាក្សី សាឡុត បាន បញ្ជាក់ថា លោកនៅតែប្រកាន់ជំហរមិនឆ្លើយតបចំណុចនេះដដែល ។

លោកមេធាវីបានបន្តសួរសាក្សីអំពីការរក្សាការណ៍សម្ងាត់ថាតើវាជាទ្រឹស្តីដែលគេអប់រំនៅក្នុងការរៀនសូត្រដែរឬទេ? លោកសាក្សីបានឆ្លើយតបថា វាគឺជាការអប់រំដែលត្រូវធ្វើជាប្រចាំសម្រាប់កម្មាភិបាល ហើយមានពាក្យស្លោកមួយដែលនិយាយថា បែកការណ៍គឺស្លាប់ លាក់ការណ៍សម្ងាត់ បានគឺឈ្នះ៨០ភាគរយ ។ លោកមេធាវីបានបន្តសួរទៀតថា តើការរក្សាការណ៍សម្ងាត់មានទាក់ទងនឹងគោលការណ៍១២ប្រការដែរឬទេ? លោកសាក្សីបានឆ្លើយថា គោលការណ៍រក្សាការណ៍សម្ងាត់នេះ គឺមាននៅក្នុងគោលការណ៍ទាំង១២ប្រការរបស់បក្ស ហើយគោលការណ៍នេះក៏ស្ថិតនៅក្នុងក្របខណ្ឌនៃរបបកម្ពុជាប្រជាធិបតេយ្យដែរ ។

### III. សវនាការស្តីពីការសួរដេញដោលសាក្សី ពាន ឃឿន

នៅព្រឹកថ្ងៃទី២ ខែឧសភា ឆ្នាំ២០១២ បន្ទាប់ពីក្រុមមេធាវីការពារ ខៀវ សំផន បានបញ្ចប់ការសួរដេញដោលរបស់ខ្លួនលើសាក្សី សាឡុត បាន អង្គជំនុំជម្រះសាលាដំបូងបានកោះហៅសាក្សី

មួយរូបថ្មីទៀតដើម្បីផ្តល់សក្ខីកម្មនៅក្នុងសវនាការ ។ ភ្លាមៗនោះ មេធាវីការពារក្តីរបស់ជនជាប់ចោទ នួន ជា គឺលោក អេនឌ្រូ អ៊ីនូហ្វ៊ី បានស្នើសុំអង្គជំនុំជម្រះឲ្យធ្វើការសាកសួរដេញដោលលើសាក្សីរូបនោះជាអសាធារណៈ ដោយផ្តល់ហេតុផលថា បើយោងតាមចម្លើយរបស់សាក្សីដែលបានផ្តល់នៅក្នុងបទសម្ភាសន៍ និងសេចក្តីថ្លែងការណ៍របស់សាក្សីដែលមាននៅក្នុងសំណុំរឿងបើតាមការយល់ឃើញរបស់ក្រុមមេធាវីការពារក្តី សេចក្តីថ្លែងការណ៍ និងចម្លើយទាំងអស់នោះអាចនឹងក្លាយជាចម្លើយប្រឆាំងនឹងសាក្សីខ្លួនឯង ។

លោកមេធាវីបានបន្តទៀតថា ការណ៍ដែលលោកលើកហេតុផលនេះឡើង គឺដោយសារលោកមិនចង់ឲ្យមានបញ្ហាកើតឡើងនៅអំឡុងពេលនៃការសួរដេញដោល ។ ក៏ប៉ុន្តែសំណើនេះត្រូវបានជំទាស់ដោយតំណាងសហព្រះរាជអាជ្ញាលោក ថារីក អាប់ឌុល និងសហមេធាវីនាំមុខអន្តរជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណី លោកស្រី អេលីហ្សាប៊ែត ស៊ីមុនណូ ហ៊ុត ។

បន្ទាប់ពីបានពិភាក្សាដោយចំណាយពេលប្រហែល៥នាទី អង្គជំនុំជម្រះសម្រេចថានឹងធ្វើសវនាការជាអសាធារណៈ ដោយមិនមានការចូលរួមពីសំណាក់សាធារណជនក្នុងសវនាការចាប់ពីម៉ោង១១ព្រឹក ថ្ងៃទី៧ ខែឧសភា ឆ្នាំ២០១២ រហូតដល់ពេលសម្រាកពិសារអាហារថ្ងៃត្រង់ ដើម្បីដោះស្រាយបញ្ហាដែលបានលើកឡើងដោយភាគី ។ ស្របពេលជាមួយគ្នានោះ លោក ខាណាវ៉ាស មេធាវីការពារក្តី អៀង សារី ក៏បានស្នើសុំអង្គជំនុំជម្រះឲ្យដកចេញនូវឯកសារមួយដែលជាបទសម្ភាសន៍ធ្វើឡើងដោយការិយាល័យសហចៅក្រមស៊ើបអង្កេត ដោយសារឯកសារនោះគឺជាឯកសារដែលត្រូវបានសង្ខេបចេញពីខ្សែអាត់ថតសំឡេងនៅអំឡុងពេលនៃការធ្វើបទសម្ភាសន៍នោះ ។ ដូច្នេះចាំបាច់ត្រូវតែមានការផ្ទៀងផ្ទាត់រវាងអត្ថបទសង្ខេប និងខ្សែអាត់ថតសំឡេងជាមុនសិន មុនពេលយកឯកសារនោះប្រើប្រាស់នៅចំពោះមុខអង្គជំនុំជម្រះ ។ ជាថ្មីម្តងទៀត ទាំងតំណាងសហព្រះរាជអាជ្ញា និងមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានជំទាស់នឹងសំណើសុំរបស់លោកមេធាវី ខាណាវ៉ាស ។ ចំពោះសំណើនេះមិនមានការសម្រេចពីសំណាក់អង្គជំនុំជម្រះនៅឡើយទេ ។

## ១) ប្រវត្តិសាវតារសង្ខេបរបស់សាក្សី ពាន យៀន

បន្ទាប់ពីធ្វើសវនាការជាអសាធារណៈរួចមក អង្គជំនុំជម្រះបានចាប់ផ្តើមសវនាការជាមួយនឹងការកោះអញ្ជើញសាក្សីចូលមកផ្តល់សក្ខីកម្មនៅក្នុងសវនាការ និងបានណែនាំសាក្សីអំពីការឆ្លើយតប ចំពោះភាគីនៅក្នុងសវនាការ ។

ជាដំបូងប្រធានអង្គជំនុំជម្រះលោកចៅក្រម និល ណុន បានចាប់ផ្តើមសួរអំពីប្រវត្តិសាវតាររបស់សាក្សី ។ ឆ្លើយតបនឹងសំណួររបស់លោកប្រធានអង្គជំនុំជម្រះ លោកសាក្សីបានបញ្ជាក់ថា ឈ្មោះ ពាន យៀន អាយុ៦២ឆ្នាំ រស់នៅស្រុកសំរោង ខេត្តតាកែវ មុខរបរធ្វើស្រែ និងធ្វើតុទូ ដោយមានឪពុកឈ្មោះ ពាន និងម្តាយឈ្មោះ ខី សាក្សីមានកូន៣នាក់ ជាជនជាតិខ្មែរ អានសរសេរ និងអានភាសាខ្មែរបានខ្លះ ។ លោកសាក្សីបានអះអាងថា លោកបានស្បថរួចហើយមុនពេលលោកចូលមកផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការ ។ បន្ទាប់មក លោកប្រធានអង្គជំនុំជម្រះបានជូនដំណឹងលោកសាក្សី ពាន យៀន អំពីសិទ្ធិរបស់លោកនៅក្នុងសវនាការ ។ បន្ទាប់ពីបានស្តាប់អំពីសិទ្ធិរបស់ខ្លួនដែលមាននៅចំពោះមុខអង្គជំនុំជម្រះរួចហើយ លោកសាក្សីបានស្នើសុំមេធាវីមួយរូបដើម្បីប្រឹក្សានៅក្នុងសវនាការ ។អង្គជំនុំជម្រះបានសម្រេចផ្តល់មេធាវីប្រឹក្សាតាមការស្នើសុំរបស់សាក្សីដែលមេធាវីប្រឹក្សានោះត្រូវបានរៀបចំដោយអង្គភាពគាំពារសាក្សី ។ បន្ទាប់មក លោកប្រធានអង្គជំនុំជម្រះបានប្រគល់វេទិកាជូនសហព្រះរាជអាជ្ញា



ពាន យៀន

ដើម្បីសាកសួរសាក្សី ។

**២) ការសួរដេញដោលដោយតំណាងសហព្រះរាជអាជ្ញាចំពោះសាក្សី ពាន ឃៀន**

**ក) ការសួរដេញដោលដោយតំណាងសហព្រះរាជអាជ្ញាជាតិ**



វេង ហឿត

លោកសហព្រះរាជអាជ្ញា វេង ហឿត បានចាប់ផ្តើមសំណួររបស់ខ្លួនទាក់ទងនឹងព្រឹត្តិការណ៍មុនថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ថាតើសាក្សីបានចូលធ្វើបដិវត្តន៍នៅឆ្នាំណា? លោកសាក្សីបានឆ្លើយតបថាលោកបានចូលធ្វើបដិវត្តន៍នៅឆ្នាំ១៩៦៦ នៅស្រុកអណ្តូងមាស ខេត្តរតនគិរី គឺនៅពេលដែលលោកមានអាយុ១៦ឆ្នាំ តាមរយៈឈ្មោះ ប៉ន់ និងឈ្មោះ ធាត់ ដែលមាននាទីជាអ្នកគ្រប់គ្រងនៅភូមិភាគឦសាន ។ អ្នកទាំងពីរនេះបានប្រាប់ខ្លួនថា ការចូលធ្វើបដិវត្តនេះគឺដើម្បីរំដោះជាតិ ដោយតម្រូវឲ្យសរសេរប្រវត្តិរូបស្តីអំពីវណ្ណៈភាព ។ នៅអំឡុងពេលនោះគេបានប្រជុំស្ម័យទិតៀនជារៀងរាល់ល្ងាច ។ លោកសាក្សីបានបន្តទៀតថា នៅពេលនោះបក្សបានផ្តល់តួនាទីឲ្យលោកធ្វើជានិរសាររបស់អង្គការបដិវត្តន៍ ប៉ុន្តែលោកសាក្សីមិនបានដឹងថាអង្គការបដិវត្តន៍នោះជានរណាឡើយ ។ លោកតំណាងសហព្រះរាជអាជ្ញា វេង ហឿត បានបន្តសួរលោកសាក្សីថាតើមាននរណាប្រាប់សាក្សីថាអង្គការនោះជានរណាដែរឬទេ? សាក្សីបានឆ្លើយតបវិញថា មិនមាននរណាប្រាប់លោកថាអង្គការជានរណាឡើយ ។ ដូច្នេះលោកមិនបានដឹងថាអង្គការជានរណាទេ ។ លោកតំណាងសហព្រះរាជអាជ្ញាបានបន្តសួរថាតើការរត់សំបុត្រឲ្យអង្គការធ្វើឡើងដោយរបៀបណា? លោកសាក្សីបានបញ្ជាក់ថា គេដាក់សំបុត្រចូលទៅក្នុងបំពង់ឬស្សី បន្ទាប់មកថ្វាក់លើបញ្ជាឲ្យយកទៅឲ្យអ្នកដែលគេប្រាប់ពីអត្តសញ្ញាណជាមុន ។ លោកតំណាងសហព្រះរាជអាជ្ញាបានបន្តសួរសាក្សីទៀតថា តើលោកសាក្សីស្គាល់ឈ្មោះ កុយ ធួន ដែរឬទេ? លោកសាក្សីបានបញ្ជាក់ថា លោកពិតជាស្គាល់ឈ្មោះនេះ ប៉ុន្តែលោកបញ្ជាក់បន្ថែមថា គឺឈ្មោះ កុយ ឃួន មិនមែនឈ្មោះ កុយ ធួន ទេ ។ គួរកត់សម្គាល់ថា នៅត្រង់ចំណុចនេះលោក សាក្សី ពាន ឃៀន ត្រូវបានតំណាង សហព្រះរាជអាជ្ញាស្នើសុំឲ្យសាក្សីធ្វើការបញ្ជាក់ឲ្យបានច្បាស់ថាតើឈ្មោះដែលសាក្សីបាននិយាយនោះឈ្មោះថា កុយ ធួន ឬ កុយ ឃួន ។ លោកសាក្សីនៅតែប្រកាន់ជំហរថាអ្នកដែលលោកបានស្គាល់គឺមាន ឈ្មោះថា កុយ ឃួន ។ សូមគូសបញ្ជាក់បន្ថែមថា បើយោងតាមអត្តសញ្ញាណ និងព័ត៌មានដែលសាក្សីបានបញ្ជាក់ជូនអង្គជំនុំជម្រះ និងសហព្រះរាជអាជ្ញា ឈ្មោះ កុយ ធួន និង កុយ ឃួន គឺជាមនុស្សតែមួយ ទោះបីជាមានការហៅឈ្មោះផ្សេងគ្នាដោយសាក្សីយ៉ាងណាក្តី ។

នៅឆ្នាំ១៩៦៦ លោកសាក្សីបាននិយាយថា លោកបានផ្លាស់មករស់នៅជាមួយឈ្មោះ កុយ ឃួន ដោយមាននាទីជានិរសារ និងអង្គរក្ស ។ រហូតមកដល់ឆ្នាំ១៩៧៥ ទើបលោកដឹងថា កុយ ឃួន ធ្វើជាលេខាភូមិភាគ៣០៤ និងបានប្តូរឈ្មោះ ប៉ុល ពត នួន ជា អៀង សារី និងខៀវ សំផន នៅ ពេលនោះដែរ ។ ប៉ុន្តែលោកមិនបានដឹងច្បាស់អំពីតួនាទីរបស់អ្នកទាំងនោះថាធ្វើអ្វីឡើយនៅពេលនោះ ។ នៅក្រោយរំដោះភ្នំពេញ លោកបញ្ជាក់ថា លោកនៅចាំតែមន្ទីរក-១ មន្ទីរក-៣ និងមន្ទីរក-៧ តែប៉ុណ្ណោះ ។ លោកបំភ្លឺបន្ថែមថា មន្ទីរក-១គឺមានទីតាំងនៅជិតវិមានឯករាជ្យ រីឯមន្ទីរក-៧ មានទីតាំងនៅជាប់មាត់ទន្លេ មុំវត្តខណ្ណលោម ។ បន្ទាប់មក លោកតំណាងសហព្រះរាជអាជ្ញាបានសួរអំពីមន្ទីរ១០០ ។ ប៉ុន្តែលោកសាក្សីបានឆ្លើយថា លោកមិនស្គាល់មន្ទីរ១០០ទេ ។ លោកតំណាងសហព្រះរាជអាជ្ញាបានសួរទៀតថាតើមានស្គាល់ឈ្មោះ លីន ដែរឬទេ? សាក្សីបានបញ្ជាក់លោកស្គាល់ឈ្មោះ លីន យ៉ាងច្បាស់ ។ លោកតំណាងសហព្រះរាជអាជ្ញាបានត្រឡប់មកខាងក្រោយវិញ ដោយសួរសាក្សីថាតើមានស្គាល់ឈ្មោះ ប៉ន់ ដែរឬទេ? លោកសាក្សី

បានបញ្ជាក់ថា ឈ្មោះ ប៉ង់ គឺជាអ្នកគ្រប់គ្រងក្រុមនិរសារ ។ ឆ្លើយតបនឹងសំណួររបស់សហព្រះរាជអាជ្ញាទាក់ទងនឹងមន្ទីរក-១ លោកសាក្សី ពាន យឿន បានពន្យល់ថា មន្ទីរក-១ គឺជាកន្លែងដែល ប៉ុល ពត ស្នាក់នៅ រីឯមន្ទីរក-៣ គឺជាកន្លែងធ្វើការជុំគ្នារវាង ប៉ុល ពត ខៀវ សំផន អៀង សារី និង សុន សេន ។ រីឯមន្ទីរក-៧ លោកមិនបានដឹងថានៅទីនោះមាននាទីសម្រាប់ធ្វើអ្វីឡើយ ។ លោកបន្តទៀតថា នៅពេលដំបូង ប៉ុល ពត រស់នៅខេត្តរតនគិរី បន្ទាប់មកបានផ្លាស់មករស់នៅខេត្តកំពង់ចាម និងខេត្តកំពង់ធំ ហើយក្រោយមកក៏ចាកចេញទៅទីក្រុងភ្នំពេញ ។

បន្ទាប់មកលោកតំណាងសហព្រះរាជអាជ្ញាបានបន្តសួរសាក្សីអំពីលក្ខខណ្ឌរស់នៅរបស់ប្រជាជន ក្រោមការគ្រប់គ្រងរបស់ក្រុមខ្មែរក្រហមចាប់ពីឆ្នាំ១៩៦៦ដល់១៩៧៥ ។ លោកសាក្សីបានបញ្ជាក់ថា នៅពេលនោះលោកក្តាប់មិនបានពីសភាពការណ៍របស់ប្រជាជនឡើយ ព្រោះលោកជាប់រវល់បំពេញភារកិច្ចនៅក្នុងព្រៃ ។ ក្រោយពេលវៀតណាមចូលមកដល់ទើបលោកបានដឹងតាមរយៈការនិយាយប្រាប់ពីសំណាក់អ្នកស្គាល់គ្នា ។ លោកតំណាងសហព្រះរាជអាជ្ញាបានសាកសួរសាក្សីអំពីសេរីភាពរបស់ប្រជាជនក្នុងការគោរពសាសនានៅអំឡុងពេលការគ្រប់គ្រងរបស់ក្រុមខ្មែរក្រហមនៅខេត្តរតនគិរី ។ សាក្សីបានឆ្លើយតបនឹងសំណួរនេះថានៅមុនពេលរំដោះភ្នំពេញ គឺមានការគោរព និងមានវត្តអារាមធម្មតា ប៉ុន្តែក្រោយពេលរំដោះភ្នំពេញ លោកមិនឃើញមានការគោរពសាសនា មិនមានអាចារ្យ និងវត្តអារាមទៀតឡើយ ។

ឆ្លើយតបសំណួរទាក់ទងនឹងគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាថាតើមានការចាត់ទុករបប លន់ នល់ ថាជាសត្រូវដែរឬទេ? លោកសាក្សីបញ្ជាក់ថា បក្សកុម្មុយនីស្តកម្ពុជាពិតជាបានចាត់ទុកមន្ត្រីរដ្ឋការ និងទាហាននៃរបប លន់ នល់ ថាជាសត្រូវ និងថាប្រសិនបើទាហានខ្មែរក្រហមចាប់បានគេប្រាកដជាកម្ទេចអ្នកទាំងនោះចោលតែម្តង ។

លោកសហព្រះរាជអាជ្ញាបានសួរបន្តទៀតថាតើបក្សកុម្មុយនីស្តកម្ពុជាបានបង្រៀនលោកសាក្សីពីគោលនយោបាយរបស់បក្សដែរឬទេ? លោកសាក្សីបានឆ្លើយតបថា គឺពិតជាមានការបង្រៀនដល់លោកមែន ប៉ុន្តែមិនមានជាសៀវភៅ ឬបិចអ្វីឡើយ ។ ឆ្លើយតបនឹងសំណួររបស់សហព្រះរាជអាជ្ញាទាក់ទងនឹងទង់បដិវត្ត លោកសាក្សីបានបញ្ជាក់ថា លោកធ្លាប់បានឃើញទង់បដិវត្ត ។ បន្ទាប់មកលោកតំណាងសហព្រះរាជអាជ្ញាបានចាប់ផ្តើមសំណួរថ្មីមួយទៀតទាក់ទងនឹងការផ្លាស់ទីលំនៅរបស់លោកសាក្សី ពាន យឿន នៅមុនឆ្នាំ១៩៧៥ ។ លោកសាក្សីបានបញ្ជាក់ថា លោកបានផ្លាស់មកស្រុកដំណាក់ស្តេចដែលជាទីតាំងប្រយុទ្ធគ្នារវាងកងពលខ្មែរក្រហម និងទាហាននៃរបប លន់ នល់ ជាមួយនឹង កុយ ធួន ។

បន្ទាប់មកលោកតំណាងសហព្រះរាជអាជ្ញាបានសួរបញ្ជាក់សាក្សីថាតើមុនឆ្នាំ១៩៧៥ ក្នុងនាមជានិរសាររបស់ កុយ ធួន តើសាក្សីធ្លាប់បានដឹងពីផែនការជម្លៀសប្រជាជនចេញពីទីក្រុងរបស់បក្សកុម្មុយនីស្តកម្ពុជាដែរឬទេ? លោកសាក្សីបានឆ្លើយថា លោកមិនបានដឹងអំពីបញ្ហានេះទេ ។ លោកសហព្រះរាជអាជ្ញាបានបន្តសាកសួរសាក្សីអំពីព្រឹត្តិការណ៍ក្រោយឆ្នាំ១៩៧៥ ថាតើសាក្សីបានចូលមកកាន់ទីក្រុងភ្នំពេញដោយរបៀបណា? និងថានរណាជាអ្នកនាំមក? លោកសាក្សីបានបញ្ជាក់ថា លោកចូលមកទីក្រុងភ្នំពេញតាមរយៈ កុយ ធួន ហើយនៅពេលចូលមកដល់ទីក្រុង លោកបានមកស្នាក់នៅម្តុំវត្តភ្នំ ដោយសង្កេតឃើញថាទីក្រុងនៅពេលនោះស្ថិតនៅក្នុងសភាពស្ងាត់ជ្រងំ ។

ឆ្លើយតបនឹងសំណួររបស់លោកតំណាងសហព្រះរាជអាជ្ញាទាក់ទងនឹងមន្ទីរក-១ លោកសាក្សីបានបញ្ជាក់ថានៅមន្ទីរក-១គឺមានឈ្មោះ ប៉ង់ និង ឈ្មោះ លឹន ដែលជាអ្នកគ្រប់គ្រង ។ បន្ទាប់មកលោកតំណាងសហព្រះរាជអាជ្ញាជាតិ វេង ហ៊ត បានប្រគល់វេទិកាជូនសហភាគាអន្តរជាតិរបស់ខ្លួនគឺលោក ថារីក អាប់ឌុលហាក់ ដើម្បីសាកសួរបន្តលើសាក្សី ។

**២) ការសួរដេញដោលដោយតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ**

លោកតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ថារីក បានចាប់ផ្តើមសំណួរដំបូងរបស់ខ្លួន ដោយផ្តោតលើការចូលជាសមាជិកបក្សកុម្មុយនីស្តកម្ពុជារបស់សាក្សី ។ លោក ថារីក បានសួរសាក្សី ពាន យឿន ថា តើនៅឆ្នាំ១៩៦៦ លោកសាក្សីបានក្លាយជាសមាជិកបក្សកុម្មុយនីស្តកម្ពុជាហើយឬនៅ? លោក ពាន យឿន

បានបញ្ជាក់ថា លោកមិនទាន់ក្លាយជាសមាជិកបក្សនៅឡើយទេ ប៉ុន្តែនៅមុនឆ្នាំ១៩៧៥ បក្សបានបញ្ចូលលោកទៅក្នុងសម្ព័ន្ធយុវកក(សម្ព័ន្ធយុវជននៃបក្សកុម្មុយនីស្តកម្ពុជា) ។ លោកសាក្សីបានបញ្ជាក់ថា កុយ ធួន មានឈ្មោះសម្ងាត់ហៅថា ធុច ហើយលោកនៅជាមួយ ធុច ចាប់តាំងពីឆ្នាំ១៩៦៧-៦៨ ។ លោកបន្តទៀតថា នៅពេលដែលលោកចាកចេញពីខេត្តរតនគិរីមករស់នៅខេត្ត កំពង់ធំ លោកបានមករស់នៅស្រុកសណ្តាន់ ជាមួយ កុយ ធួន និងប្រពន្ធរបស់ កុយ ធួន ឈ្មោះ យុន ព្រោះពេលនៅពេលនោះ កុយ ធួន មានតួនាទីជាប្រធានភូមិភាគនៅទីនោះ ។ លោកសាក្សីបានបំភ្លឺទៀតថា នៅចន្លោះឆ្នាំ១៩៦៦-៦៧ រហូតដល់ឆ្នាំ១៩៧០ លោកធ្លាប់ស្គាល់ ប៉ុល ពត សុន សេន និងឈ្មោះ យ៉ា ដែលរស់នៅក្នុងតំបន់នោះជាមួយគ្នា ។ ពាក់ព័ន្ធនឹងមន្ទីរមជ្ឈិមរបស់បក្សកុម្មុយនីស្តកម្ពុជា លោកសាក្សីមិនបានដឹងទេ ដោយសារលោកត្រូវចល័តចុះឡើងជាញឹកញាប់ក្នុងតួនាទីលោកជានិរសារ ។ លោកធ្លាប់រត់សំបុត្រពី កុយ ធួន ទៅប្រពន្ធរបស់ កុយ ធួន ប៉ុន្តែមិនមែននាំសំបុត្រពី កុយ ធួន ទៅមេដឹកនាំផ្សេងទៀតទេ ។

ឆ្លើយតបនឹងសំណួររបស់សហព្រះរាជអាជ្ញាទាក់ទងនឹងការប្រយុទ្ធគ្នារវាងកងទ័ពកម្ពុជា និងកងទ័ព លន់ នល់ លោកសាក្សីបានបំភ្លឺថា នៅអំឡុងពេលនោះលោកបានដឹងអំពីការប្រយុទ្ធរវាងកងទ័ពខ្មែរក្រហម និងទាហានរបស់ លន់ នល់ ប៉ុន្តែលោកមិនចូលរួមទេ ព្រោះលោកមិនមែនជាទាហាន គឺគ្រាន់តែជានិរសារមួយរូបប៉ុណ្ណោះ ។ លោកបានបន្តថា នៅអំឡុងឆ្នាំ១៩៧៤ ធុច (កុយ ធួន) បានចាកចេញពីខេត្តកំពង់ធំមកហ៊ុកហ៊ុនទ័ពនៅមុំដំណាក់ស្តេច ដើម្បីបើកការវាយប្រយុទ្ធ ហើយលោកក៏នៅទីនោះជាមួយ នឹង ធុច ដែរ ។

លោកតំណាងសហព្រះរាជអាជ្ញាបានសួរបន្តទៀតថាតើមានអ្វីកើតឡើងប្រសិនបើទទួលបានជ័យជម្នះ? លោកបានឆ្លើយថាពេលនោះលោកមានការបារម្ភដោយមិនដឹងថាតើបដិវត្តនឹងឈ្នះ ឬក៏ចាញ់នោះទេ ។ លោក ឃឿន បានពន្យល់បន្តថា លោកបានចូលមកដល់ទីក្រុងភ្នំពេញនៅក្រោយពេលរំដោះភ្លាមៗ គឺនៅ


កុយ ធួន ជាមួយនឹងក្រុមសិល្បៈក្នុងរបបកម្ពុជាប្រជាធិបតេយ្យ

ម៉ោង៥ល្ងាចថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ជាមួយនឹង ធុច ។ លោកតំណាងសហព្រះរាជអាជ្ញាបានសួរបន្តថាតើលោកមានដឹងថាមានមេដឹកនាំផ្សេងទៀតចូលមកដល់ទីក្រុងភ្នំពេញនៅពេលណាដែរឬទេ? លោកសាក្សីឆ្លើយថា លោកមិនបានដឹងអំពីរឿងនេះទេ ។ លោកតំណាងសហព្រះរាជអាជ្ញាបានសួរសាក្សីថា តើលោកសាក្សីចូលមកភ្នំពេញដោយរបៀបណា? សាក្សីបាននិយាយថា លោកបានជិះកង់ពីខុដ្ដកកាត់តាមកំពង់ស្ពឺ ។ នៅពេលដែលលោកចូលមកដល់ លោកបានឃើញហ្វូងមនុស្សជាច្រើន បានធ្វើដំណើរចាកចេញពីទីក្រុងភ្នំពេញ ដោយមានអ្នកខ្លះធ្វើដំណើរដោយថ្មើរជើង និងអ្នកខ្លះធ្វើដំណើរដោយរថយន្ត ។ ប៉ុន្តែលោកមិនច្បាស់ទេថា គេជម្លៀសប្រជាជនដើម្បីអ្វី លោកគ្រាន់តែឮគេនិយាយគ្នាៗថា គេជម្លៀសប្រជាជនដើម្បីបោសសម្អាតខ្មាំងឲ្យស្អាត ។ ខ្មាំងគឺសំដៅលើទាហានរបស់រដ្ឋការ លន់ នល់ និងពួក សេ.អ៊ី.អា ។

លោកតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ថារីក បានបន្តសំណួររបស់ខ្លួនទាក់ទងនឹងតួនាទីរបស់សាក្សីនៅពេលចូលមកដល់ទីក្រុងភ្នំពេញ ។ លោក ថារីក បានសួរសាក្សីថាតើនៅថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥ សាក្សីបានធ្វើអ្វីបន្ទាប់ពីចូលមកដល់ភ្នំពេញ? សាក្សីបានឆ្លើយតបថា លោកមិនបានធ្វើអ្វីទេ គឺគ្រាន់តែរៀបចំបាយទឹកសម្រាប់ កុយ ធួន តែប៉ុណ្ណោះ ។ លោកបន្តថា នៅក្រោយការចាប់ខ្លួនរបស់ កុយ ធួន ទើប ប៉ាំង នាំលោកទៅធ្វើការមន្ទីរក-១ ។ លោកបញ្ជាក់ថា កុយ ធួន ធ្វើជាប្រធានតំបន់៣០៤ និងក្រោយមកធ្វើការនៅក្រសួងពាណិជ្ជកម្ម នៅមុនពេលត្រូវបានចាប់ខ្លួន ។ នៅមុនពេលចាប់ខ្លួន កុយ ធួន រស់នៅជិតវត្តភ្នំ និងមានកន្លែងមួយទៀតនៅម្តុំប្រាំងចំរេះ ។ ក្រោយពេល កុយ ធួន ត្រឡប់មកពីកំពង់សោម អង្គការបានចុះទៅចាប់ខ្លួន កុយ ធួន នៅទីកន្លែង ដែល កុយ ធួន ស្នាក់នៅ ប៉ុន្តែលោកមិនបានដឹងថានរណាជាអ្នកមកចាប់ខ្លួន កុយ ធួន ទេ គ្រាន់តែដឹងថាអង្គការជាអ្នកចាប់ខ្លួន ។ លោកតំណាងសហព្រះរាជអាជ្ញាបានបន្តសួរទៀតថាតើអង្គការជានរណា? លោកសាក្សីនិយាយថា អង្គការគឺជាអ្នកដឹកនាំធំៗនៅពេលនោះ ។ លោកតំណាងសហព្រះរាជអាជ្ញាសួរបន្តទៀតថាតើអ្នកដឹកនាំធំៗទាំងនោះមានអ្នកណាខ្លះ? លោកសាក្សីបានឆ្លើយថា នៅពេលនោះលោកស្គាល់តែអ៊ំទី១ គឺ ប៉ុល ពត តែម្នាក់ប៉ុណ្ណោះ ប៉ុន្តែក្រោយមកទៀត គឺនៅឆ្នាំ១៩៧៦ ទើបលោកស្គាល់ នួន ជា អៀង សារី សុន សេន និង ខៀវ សំផន ។ ការណ៍ដែលលោកស្គាល់អ្នកទាំងអស់នោះ គឺដោយសារតែលោកបានផ្លាស់ទៅធ្វើការនៅមន្ទីរក-១ និងក-៣ ដែលជាកន្លែង ប៉ុល ពត ធ្វើការ ។ អ្នកទាំងអស់នោះត្រូវបានគេហៅថា អ៊ំ ។ លោកបន្ថែមថា អ្នកដែលត្រូវបានគេហៅថា អ៊ំ គឺសុទ្ធតែជាមេដឹកនាំថ្នាក់ខ្ពស់ ។


ថារីក

លោក ថារីក បានបន្តសួរសាក្សីអំពីការចាប់ខ្លួន កុយ ធួន ដោយរំឭកអំពីសម្តីរបស់សាក្សីថា កន្លែងដែលគេចាប់ខ្លួន កុយ ធួន គឺមានចម្ងាយ៣០០ម៉ែត្រពីមន្ទីរក-១ ។ សាក្សីបានឆ្លើយតបដោយយល់ស្របថាគឺពិតជាត្រឹមត្រូវ ។ លោកបញ្ជាក់បន្ថែមថា ការចាប់ខ្លួននេះគឺធ្វើឡើងនៅអំឡុងចុងឆ្នាំ១៩៧៥ និងដើមឆ្នាំ១៩៧៦ ហើយទីតាំងដែលគេឃុំខ្លួន គឺជាអគារមួយដែលគេព័ទ្ធស័ង្កសីជិត ។ លោកមិនបានចាំថាទីតាំងនោះជាកន្លែងអ្វីទេ ។ ពេលដែលចូលទៅដល់ទីកន្លែងឃុំខ្លួន លោកមិនឃើញមានកងការពារអ្វីទេ ហើយលោកគ្រាន់តែប្រគល់មាន់ឲ្យទៅ កុយ ធួន ហើយនិងសួរសុខទុក្ខពីរបីម៉ាត់ក៏ត្រឡប់មកវិញ ។ អ្នកដែលចាត់ចែងឲ្យយកម្ហូបអាហារទៅឲ្យ កុយ ធួនគឺ ប៉ាំង ។ ពេលនោះ ប៉ាំង មិនបាននិយាយអ្វីជាមួយលោកច្រើននោះទេ គឺគ្រាន់តែប្រាប់ឲ្យយកម្ហូបទៅឲ្យ កុយ ធួន តែប៉ុណ្ណោះ ។

បន្ទាប់មកលោកតំណាងសហព្រះរាជអាជ្ញា ថារីក បានបង្ហាញរូបថតមួយសន្លឹកជូនលោក សាក្សី ដើម្បីធ្វើការបញ្ជាក់

ដែលនៅក្នុងរូបថតនោះគឺមានរូបមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា ។ ប៉ុន្តែលោកសាក្សីមិនអាចបញ្ជាក់លើរូបថតដែលសហព្រះរាជអាជ្ញាបង្ហាញទេ ដោយអះអាងថា លោកមិនស្គាល់មនុស្សដែលនៅក្នុងរូបថតនោះទេ និងថាប្រហែលដោយសារពេលវេលាកន្លងផុតយូរពេក ។ បន្ទាប់មកលោកតំណាងសហព្រះរាជអាជ្ញាបានបង្ហាញរូបថតរបស់ កុយ ធួន ដែលត្រូវបានចាប់ខ្លួនដាក់នៅមន្ទីរស-២១ និងមានដាក់ច្រវាក់ជើងអង្គុយនៅលើគ្រែដែកមួយ ក៏ប៉ុន្តែលោកសាក្សី ពាន យឿន នៅតែអះអាងថា លោកមិនស្គាល់មនុស្សនៅរូបថតនោះទេ ។

ឆ្លើយតបនឹងសំណួររបស់លោកតំណាងសហព្រះរាជអាជ្ញាដែលសួរថាតើមានអ្វីកើតឡើងនៅប្រាំងចំរេះក្រោយពីការចាប់ខ្លួន កុយ ធួន? លោកសាក្សី ពាន យឿន បាននិយាយថា ក្រោយការចាប់ខ្លួនរបស់ កុយ ធួន បុគ្គលិកដែលធ្វើការនៅក្នុងអង្គភាពនោះត្រូវបានរំលាយ ហើយលោកមិនបានដឹងថាអ្នកទាំងនោះធ្វើការនៅទីណាទៀតឡើយ ។ លោកបញ្ជាក់បន្ថែមថា ខ្លួនបានដឹងពីបញ្ហានោះដោយសារមានមិត្តភក្តិប្រាប់ ។ ក្រោយការចាប់ខ្លួន ធុច (កុយ ធួន) ពីរខែ ប៉ន់ បាននាំលោកមកធ្វើការនៅមន្ទីរក-១ ដែលមានទីតាំងនៅជិតវិមានឯករាជ្យ គឺនៅជិតផ្ទះរបស់ ប៉ុល ពត ។ លោកបន្ថែមថាមន្ទីរក-១ គឺជាផ្ទះ២ល្វែងដែលមានទំហំប្រហែលជា១០០ម៉ែត្របួនជ្រុង និងមានកងសន្តិសុខនៅរង់ចាំយាមយ៉ាងហោចណាស់ម្នាក់នៅក្បែរទីកន្លែងនោះ ។ លោកសាក្សីបានបំភ្លឺថា នៅទីនោះលោកមានតួនាទីធ្វើជាអ្នករៀបចំបាយសម្រាប់ ប៉ុល ពត និងប្រមាណជាកន្លះឆ្នាំ ។ នៅពេល នោះលោកធ្លាប់បានឃើញ ប៉ុល ពត និង នួន ជា ប៉ុន្តែ នួន ជា ទៅទីនោះយូរៗម្តងតែប៉ុណ្ណោះ ។ លោកសាក្សីបានបញ្ជាក់ថា ប៉ន់ ក៏រស់នៅក្នុងមន្ទីរក-១ជាមួយនឹង ប៉ុល ពត ដែរ ។ បន្ទាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ ១៩៧៥ ប៉ន់ បានក្លាយជាអ្នកទទួលខុសត្រូវរួមនៅមន្ទីរ៨៧០ ដែលជាមន្ទីរក្របខ័ណ្ឌមជ្ឈិមរបស់បក្សកុម្មុយនីស្តកម្ពុជា ។ ប៉ន់ ក៏ជាអ្នកចាត់ចែងនៅមន្ទីរក-១ ក-៣ និង ក-៧ ដែរ ។ សាក្សីអះអាងថា បើតាមគំនិតរបស់លោកផ្ទាល់ ប៉ន់ គ្រាន់តែជាលេខាម្នាក់ប៉ុណ្ណោះ ដែលមិនមានតួនាទីខ្ពស់ដូចជា ប៉ុល ពត, នួន ជា ឬ អៀង សារី នោះទេ ។ ភារកិច្ចរបស់ ប៉ន់ គឺត្រូវរាយការណ៍ជូន ប៉ុល ពត ប៉ុន្តែលោកមិនបានដឹងថាតើ ប៉ន់ រាយការណ៍ទៅនរណាផ្សេងទៀតឡើយ ។ លោកពន្យល់ទៀតថា ប៉ន់ បានបាត់ខ្លួនមុនពេលលោកចាកចេញពីមន្ទីរក-១ ប៉ុន្តែមិនបានដឹងពីមូលហេតុនៃការបាត់ខ្លួនរបស់ ប៉ន់ ទេ ។ ក្រោយពេល ប៉ន់ បាត់ខ្លួន លីន បានចូលទៅគ្រប់គ្រងជំនួស ប៉ន់ ។ លោកសាក្សីបញ្ជាក់ថា នៅអំឡុងពេលដែលលោករស់នៅមន្ទីរក-១ លោកធ្លាប់បានចូលរួមប្រជុំជាមួយ ប៉ន់ ប៉ុន្តែគ្រាន់តែជាការប្រជុំធម្មតាតែប៉ុណ្ណោះ គឺប្រជុំទាក់ទងនឹងភារកិច្ចរៀងៗខ្លួនរបស់អ្នកចូលរួមប្រជុំ ។ ក្រៅពីការប្រជុំនេះ លោកបន្ថែមថា ជារៀងរាល់យប់គឺមានការប្រជុំ ស្វ័យទិតៀនយ៉ាងទៀងទាត់ បើមិនបានរាល់ថ្ងៃក៏ត្រូវធ្វើបីដងក្នុងមួយសប្តាហ៍ដែរ ។ មានពេលខ្លះ ប៉ន់ បានបង្រៀនអំពីគោលនយោបាយរបស់បក្សទាក់ទងនឹងខ្មាំង ដោយលោកអះអាងថា ខ្មាំង គឺសំដៅលើពួក សេ.អ៊ី.អា, ពួក កា.ហ្សេ.បេ និងពួកយួន ។

ទាក់ទងនឹងមន្ទីរក-៣ លោកសាក្សីបានបញ្ជាក់ជូនសហព្រះរាជអាជ្ញាថា មន្ទីរក-៣ គឺជាកន្លែងប្រជុំគ្នារវាង ប៉ុល ពត, នួន ជា, អៀង សារី និង សុន សេន ដោយសារលោកបានឃើញអ្នកទាំងនោះបានចេញចូលនៅទីនោះ ។ លោកបញ្ជាក់បន្ថែមថា សុន សេន ទៅទីនោះម្តងម្កាលតែប៉ុណ្ណោះ ។ លោកមិនបានដឹងថា អ្នកទាំងនោះប្រជុំអំពីអ្វីឡើយ ។ ទាក់ទងនឹងគណៈអចិន្ត្រៃយ៍ លោកមិនបានដឹងទេ ព្រោះលោកមិនមែនជាអ្នកដឹកនាំ ។ រីឯ ខៀវ សំផន លោកបានឃើញនៅមន្ទីរក-៣ ដែរ ប៉ុន្តែមិនបានដឹងថា ខៀវ សំផន ទៅធ្វើអ្វីឡើយ ។

បន្ទាប់មកលោកតំណាងសហព្រះរាជអាជ្ញាបានលើកយកឯកសារចម្លើយរបស់សាក្សីដែលបានធ្វើសម្ភាសន៍ជាមួយបុគ្គលិករបស់តុលាការដើម្បីរំឭកអំពីការចងចាំរបស់លោកសាក្សីទាក់ទងនឹងអ្វីដែលលោកសាក្សីបានឆ្លើយនៅពេលនោះ ។ ប៉ុន្តែសាក្សីបានឆ្លើយតបថា លោកមិនបានចាំអំពីចម្លើយដែលលោកបានឆ្លើយប្រាប់ទៅបុគ្គលិករបស់តុលាការនៅអំឡុងពេលនោះឡើយ ។

គួរកត់សម្គាល់ថា បន្ទាប់ពីការសម្រាកនៅព្រឹកថ្ងៃទី៣ ខែឧសភា ឆ្នាំ២០១២ លោកប្រធានអង្គជំនុំជម្រះ និល ណុន បានដើរចូលក្នុងបន្ទប់សវនាការតែម្នាក់ឯង និងបានប្រកាសជូនភាគីទាំងអស់ និងសាធារណជនដែលបានចូលរួមថា អង្គជំនុំជម្រះសូម

ប្រកាសផ្អាកសវនាការនៅត្រឹមព្រឹកថ្ងៃទី៣ ឧសភា ដោយសារតែបញ្ហាសុខភាពធ្ងន់ធ្ងររបស់សាក្សី ហើយអង្គជំនុំជម្រះនឹងបន្តស្តាប់សក្ខីកម្មរបស់ សាក្សី ពាន យៀន នៅថ្ងៃព្រហស្បតិ៍ និងថ្ងៃសុក្រទី១៧ និង ១៨ ខែឧសភា ឆ្នាំ២០១២ ។

បន្ទាប់ពីបានផ្អាកកិច្ចដំណើរកាលចាប់តាំងពីថ្ងៃទី៣ ខែឧសភា ឆ្នាំ២០១២ ដោយសារមូលហេតុ បញ្ហាសុខភាពធ្ងន់ធ្ងររបស់លោកសាក្សី ពាន យៀន ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១២ អង្គជំនុំជម្រះសាលាដំបូងបានបន្តកិច្ចដំណើរការនីតិវិធីសួរដេញដោលលើសាក្សី ។ គួរកត់សម្គាល់ថា នៅថ្ងៃទី១៨ ខែឧសភា អង្គជំនុំជម្រះសាលាដំបូងមិនបានដំណើរការនីតិវិធីសួរដេញដោលលើសាក្សី ពាន យៀន ទេ ដោយសារអង្គជំនុំជម្រះបានបញ្ចប់កិច្ចដំណើរការនីតិវិធីមុនកាលកំណត់ ។

អង្គជំនុំជម្រះបានដំណើរការនីតិវិធីដោយប្រគល់វេទិកាជូនលោកតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ថារីក អាប់ឌុលហាក់ ដើម្បីបន្តការសួរដេញដោលរបស់ខ្លួនចំពោះសាក្សី ពាន យៀន ។ លោក តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ថារីក បានបន្តសួរសំណួរដោយផ្តោតលើតួនាទីរបស់សាក្សីនៅមន្ទីរប្រាំងចំរេះ ។ សាក្សីបានឆ្លើយថា នៅមន្ទីរប្រាំងចំរេះ លោកមានតួនាទីត្រឹមតែជាអ្នកជម្រះស្មៅម្នាក់ប៉ុណ្ណោះ ។ សាក្សីបានបញ្ជាក់បន្ថែមថាមន្ទីរប្រាំងចំរេះគឺគ្រាន់តែជាកន្លែងស្នាក់នៅបណ្តោះអាសន្នមួយមិនមែនជាកន្លែងស្នាក់នៅអចិន្ត្រៃយ៍ទេ ហើយនៅទីនោះមានមនុស្សធ្វើការប្រមាណ៣០នាក់ ។ សាក្សីបន្តថា ក្រោយការចាប់ខ្លួនរបស់ កុយ ធួន នៅមន្ទីរប្រាំងចំរេះមិនមានអ្វីគួរឲ្យកត់សម្គាល់ទេ ។ តំណាងសហព្រះរាជអាជ្ញាអន្តរជាតិបានសួរបន្តទៀតថាតើលោកសាក្សីមានអារម្មណ៍បែបណានៅពេលដែលមានការប្រកាសថា កុយ ធួន គឺជាភ្នាក់ងារស៊ើបអង្កេតរបស់សេ.អ៊ី.អា? សាក្សីបានឆ្លើយតបនឹងសំណួរនេះថា ក្រោយពីបានឮដំណឹងនេះលោកមានការព្រួយបារម្ភ និងខ្លាចក្រែងមានការចាប់ខ្លួនលោកដែរ ។

លោក ថារីក បានត្រឡប់មកសាកសួរសាក្សីពីស្ថានភាពនៅទីក្រុងភ្នំពេញនៅចន្លោះឆ្នាំ១៩៧៥-១៩៧៩ ។ ទាក់ទងនឹងបញ្ហានេះ សាក្សីបានបញ្ជាក់ថា លោកមិនឃើញមានអ្វីប្លែកក្រៅពីការជម្លៀសប្រជាជននៅថ្ងៃរំដោះ១៧ ខែមេសា ឆ្នាំ១៩៧៥ ទេ ។ លោក ថារីក បានសួរបន្ថែមថាតើក្រោយថ្ងៃទី៧ ខែមករា ឆ្នាំ



ថ្ងៃ១៧ មេសា ១៩៧៥

១៩៧៩ សាក្សីបានឃើញប្រជាជនត្រឡប់មកទីក្រុងវិញដែរឬទេ? សាក្សីបញ្ជាក់ថា លោកមិនបានដឹងថាប្រជាជនទាំងនោះត្រឡប់មកវិញ ឬមួយក៏ទៅរស់នៅខេត្តណាផ្សេងទេ ។ លោកបន្ថែមទៀតថា នៅអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ លោកមិនមានសិទ្ធិដើរហើរដោយសេរីទេ ប្រសិនបើចង់ទៅណាមកណាត្រូវតែមានការអនុញ្ញាតរបស់ ប៉ាង់ ។ ឆ្លើយតបនឹងសំណួរតំណាងសហព្រះរាជអាជ្ញាទាក់ទងនឹងការបាត់ខ្លួន កុយ ធួន និង ប៉ាង់ សាក្សីបានបំភ្លឺថា ក្រៅពីការបាត់ខ្លួន កុយ ធួន និង ប៉ាង់ លោកមិនបានដឹងអំពីការបាត់ខ្លួនរបស់អ្នកផ្សេងទេ ។ លោកតំណាងសហព្រះរាជអាជ្ញា ថារីក បានសាកសួរសាក្សីទៀតថា តើលោកសាក្សីមានធ្លាប់កត់សម្គាល់អំពីការបាត់ខ្លួនរបស់ ប៉ាង់ ដែរឬទេ? សាក្សីបញ្ជាក់ថា មានមនុស្សជាច្រើនបានដឹងអំពីការបាត់ខ្លួនរបស់ ប៉ាង់ ពីមន្ទីរក-១ និងក-៣ ហើយក្រោយការបាត់ខ្លួននេះ មិនមានអ្នកណាម្នាក់មកសួររក ប៉ាង់ ឡើយ ។

លោក ថារីក បានបន្តសំណួរទាក់ទងនឹងការអះអាងរបស់សាក្សីដែលថា ការប្រជុំនៅមន្ទីរក-៣ មានអ្នកចូលរួមសុទ្ធសឹងជាជនដែលមានឋានៈខ្ពស់ ។ លោកតំណាងសហព្រះរាជអាជ្ញា ថារីក បានស្នើឲ្យសាក្សីបំភ្លឺ និងធ្វើការបញ្ជាក់នៅត្រង់ចំណុចនេះ ។ សាក្សីបានបញ្ជាក់ថា នៅមន្ទីរក-៣ លោកគ្រាន់តែជាអ្នកលើកម្ហូបអាហារជូនមេដឹកនាំទាំងអស់នោះតែប៉ុណ្ណោះ និងថាកិច្ចប្រជុំនៅទីនោះធ្វើឡើងពីរ ឬបីដងក្នុងមួយខែ ។ ប៉ុន្តែលោកសាក្សីបានទទួលស្គាល់ថា លោកមិនបានដឹងថាកិច្ចប្រជុំនោះគេនិយាយពីអ្វីឡើយ ព្រោះលោកគ្រាន់តែជាអ្នកលើកម្ហូបអាហារ ។ លោកថារីក បានសួរទៀតថា តើសាក្សីមានធ្លាប់បាន ឃើញ ខៀវ សំផន ចូលរួមប្រជុំនៅកន្លែងណាផ្សេងក្រៅពីមន្ទីរក-៣ដែរឬទេ? លោកសាក្សីបានបញ្ជាក់ថា លោកមិនធ្លាប់បានឃើញ ខៀវ សំផន ចូលរួមប្រជុំនៅកន្លែងណាផ្សេងក្រៅពីមន្ទីរក-៣ ឡើយ ។ បន្ទាប់ពីតំណាងសហព្រះរាជអាជ្ញាអន្តរជាតិបានទទួលចម្លើយសាក្សីនៅត្រង់ចំណុចនេះ លោក តំណាងសហព្រះរាជអាជ្ញា ថារីក បានរំឭកសាក្សីជាមួយនឹងការបង្ហាញនូវឯកសារស្តីពីបទសម្ភាសន៍របស់សាក្សីដែលធ្វើជាមួយនឹងបុគ្គលិករបស់តុលាការ ។ នៅក្នុងឯកសារបទសម្ភាសន៍នោះ លោកសាក្សី ធ្លាប់បានអះអាងថា លោកបានឃើញ ខៀវ សំផន ធ្វើជាប្រធានកិច្ចប្រជុំនៅតាមមន្ទីរ-ក ហើយ ប៉ាង់ គឺជាអ្នករៀបចំកិច្ចប្រជុំទាំងអស់នោះ ។ បន្ទាប់ពីបានស្តាប់ការអានរបស់លោកតំណាងសហព្រះរាជអាជ្ញា លោកសាក្សី ពាន យៀន បានទទួលស្គាល់ថា លោកពិតជាបាននិយាយដូច្នេះមែន ។

តំណាងសហព្រះរាជអាជ្ញាបានសួរបន្តថា តើលោកសាក្សីមានធ្លាប់បានឃើញមេដឹកនាំជាន់ខ្ពស់ណាម្នាក់ចូលរួមបង្រៀននៅក្នុងវគ្គរៀនសូត្រណាមួយ នៅបុរីកីឡាដែរឬទេ? លោកសាក្សីបានឆ្លើយថា លោកមិនបានដឹងពីបញ្ហានេះទេ ។ បន្ទាប់មកលោកតំណាងសហព្រះរាជអាជ្ញា ថារីក បានបង្ហាញឯកសារមួយទៀត និងបានរំឭកសាក្សីដោយការអានជូនសាក្សីដូចគ្នាដដែល ។ ភ្លាមៗនោះ លោកសាក្សីបានទទួលស្គាល់ការអានរបស់សហព្រះរាជអាជ្ញាថាពិតជាសម្តីរបស់លោកដែលនិយាយថា លោកធ្លាប់បានឃើញ នួន ជា និង ខៀវ សំផន ចូលរួមបង្រៀននៅក្នុងវគ្គរៀនសូត្រនៅបុរីកីឡា ។

ឆ្លើយតបនឹងសំណួររបស់លោកតំណាងសហព្រះរាជអាជ្ញាដែលសួរថា អ្វីទៅជាការអប់រំនយោបាយជាន់ខ្ពស់ លោកសាក្សីបានពន្យល់ថា ការអប់រំនយោបាយជាន់ខ្ពស់ គឺដោយសារនៅក្នុងវគ្គរៀនសូត្រនោះ មានមេដឹកនាំធំៗចូលរួមបើកដោយផ្ទាល់ មានដូចជា អ៊ឹហែម (ខៀវ សំផន) និង ប៉ាង់ ។

ក្រោយការបាត់ខ្លួនរបស់ ប៉ាង់ បក្សបានបញ្ជូនលោកសាក្សីទៅស្វាយមាស លោកតំណាងសហ ព្រះរាជអាជ្ញាអន្តរជាតិ ថារីក បានសួរហេតុអ្វីបានជាបក្សបញ្ជូនលោកសាក្សីទៅទីនោះ? សាក្សីបានបកស្រាយជូនតំណាងសហព្រះរាជអាជ្ញាថា នៅមុនពេលវៀតណាមចូលដល់ភ្នំពេញរយៈពេលបីខែ បក្សបានបញ្ជូនលោកទៅធ្វើការងារស្វាយមាស ដោយសារតែលោកធ្លាប់ធ្វើការជាមួយនឹង កុយ ធួន ដោយមានឈ្មោះ ឃុំ ជាអ្នកបញ្ជូនលោកទៅទីនោះ ។ នៅទីនោះលោកមិនមានតួនាទីអ្វីទេ គឺគ្រាន់តែធ្វើជាអ្នកបង់សំណាញ់ ដាំបន្លែ មុនពេលដែលគេបញ្ជូនលោកត្រឡប់មកភ្នំពេញវិញ ។ លោកបានបំភ្លឺបន្ថែមថា ចំពោះពាក្យទទួលបន្ទុកដែលត្រូវបានប្រើចំពោះលោក គឺមិនមែនមានន័យថាលោកគ្រប់គ្រងនៅស្វាយមាសនោះទេ ប៉ុន្តែមានន័យថា គឺលោកត្រូវបានបញ្ជូនទៅទីនោះដើម្បីធ្វើការលត់ដំតែប៉ុណ្ណោះ ។

បន្ទាប់ពីតំណាងសហព្រះរាជអាជ្ញាអន្តរជាតិបានបញ្ចប់ការសួរដេញដោលលើសាក្សី ពាន ឃៀន អង្គជំនុំជម្រះបានប្រគល់វេទិកាជូនសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីដើម្បីសួរដេញដោលសាក្សី ។

**៣) ការសួរដេញដោលដោយសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីចំពោះ សាក្សី ពាន ឃៀន**

**ក) ការសួរដេញដោលដោយសហមេធាវីនាំមុខអន្តរជាតិ**


អេលីហ្សាប៉ែត ស៊ីម៉ុនណូហ្គត

មេធាវីនាំមុខអន្តរជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណី លោកស្រី អេលីហ្សាប៉ែត ស៊ីម៉ុនណូហ្គត បានចាប់ផ្តើមដំបូងដោយស្នើសុំឲ្យសាក្សីធ្វើការពន្យល់ចំពោះសម្តីដែលលោកសាក្សីបាននិយាយទៅកាន់សហចៅក្រមស៊ើបអង្កេតថា លោកចង់ឲ្យអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជារកយុត្តិធម៌ឲ្យជាតិនិងប្រជាជនកម្ពុជា ។ លោកបានទទួលស្គាល់ចំពោះពាក្យសម្តីរបស់លោកនៅត្រង់ចំណុចនេះថា លោកចង់ឲ្យអង្គជំនុំជម្រះរកយុត្តិធម៌ឲ្យជនរងគ្រោះឲ្យបានពិតប្រាកដ និងចង់ប្រទេសកម្ពុជាទទួលបានភាពយុត្តិធម៌ និងសុខសាន្តឡើងវិញ ។ បន្ទាប់មកលោកស្រីមេធាវីបានផ្តើមសួរសំណួរទាក់ទងនឹងការចូលរួមរបស់សាក្សីនៅក្នុងចលនាតស៊ូនៅក្នុងខេត្តរតនគីរី តាំងពីអាយុ១៦ឆ្នាំ និងសួរថាតើសាក្សីបានដឹងថាក្មេងៗជាច្រើនត្រូវបានជ្រើសរើសឲ្យចូលបម្រើបដិវត្តដែរឬទេ? លោកសាក្សីបានឆ្លើយតបនឹងសំណួរនេះថា មានប្រជាជនទូទាំងប្រទេសមិនថាក្មេង ឬចាស់ បានចូលរួមនៅក្នុងចលនាតស៊ូនេះ ។ លោកស្រីមេធាវីបានបន្តសំណួរទៀតថា ហេតុអ្វីនៅពេលនោះមានការជ្រើសរើសកុមារឲ្យចូលរួមនៅក្នុងចលនាតស៊ូ? លោកបានបញ្ជាក់ថា លោកក៏មិនបានដឹងពីមូលហេតុនេះដែរ ។ សាក្សីបានបន្ថែមថា កុយ ធួន ធ្លាប់បានអប់រំលោកឲ្យចូលរួមបដិវត្តដើម្បីរំដោះជាតិពីពួកចក្រពត្តិអាមេរិក ។

ឆ្លើយតបនឹងសំណួររបស់មេធាវីដែលសួរថា តើលោកសាក្សីស្គាល់ឈ្មោះ សូ ហុង ដែរឬទេ? សាក្សីបានបញ្ជាក់ថា លោកស្គាល់ឈ្មោះ សូ ហុង ព្រោះ សូ ហុង គឺជាពៅរបស់ ប៉ុល ពត ហើយនៅក្រោយពេលរំដោះបានទីក្រុងភ្នំពេញ សូ ហុង ជាបុគ្គលិកធ្វើការនៅក្នុងក្រសួងការបរទេស ។ ប៉ុន្តែលោកមិនដែលបានទាក់ទងជាមួយ សូ ហុង នៅពេលក្រោយមកទៀតទេ ។

ពាក់ព័ន្ធនឹងវត្តស្វាយមាស លោកសាក្សីបានបញ្ជាក់ថា នៅអំឡុងពេលដែលលោកត្រូវបានបញ្ជូនឲ្យមករស់នៅវត្តស្វាយមាស លោកមិនដែលបានឮថាមានការបញ្ជូនមនុស្សពីទីនោះទៅមន្ទីរ ស-២១ទេ ហើយលោកក៏មិនបានដឹងថា អ្នកដែលរស់នៅទីនោះត្រូវបានបញ្ជូនទៅទីណាឡើយ ដោយសារលោករស់នៅទីនោះរយៈពេលខ្លីប៉ុណ្ណោះ ។

លោកស្រីមេធាវីនាំមុខអន្តរជាតិបានបន្តសួរលោកសាក្សីទៀតថា លោកសាក្សីធ្លាប់ត្រូវបានចោទប្រកាន់ថាជាជនក្បត់ តើនរណាជាអ្នកចោទប្រកាន់លោកថាជាជនក្បត់? លោកសាក្សីបញ្ជាក់ថា ជាទូទៅប្រសិនបើជាមានការចាប់ខ្លួនប្រធានអង្គភាពណាមួយ អ្នកធ្វើការនៅក្នុងអង្គភាពនោះនឹងក្លាយជាពួកសមាសភាព ។ លោកបានពន្យល់ពាក្យ សមាសភាព ថា ប្រសិនបើមានការរកឃើញថា ប្រធានអង្គភាពណាមួយក្បត់ អ្នកស្ថិតនៅក្រោមបង្គាប់នឹងត្រូវបានចោទប្រកាន់ថាជាខ្សែក្បត់ ។

**ខ) ការសួរដេញដោលដោយសហមេធាវីនាំមុខជាតិ**

មេធាវីនាំមុខជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណីលោក ពេជ អង្គ បានផ្តើមសំណួរសាក្សីទាក់ទងនឹងតួនាទីជានិរសារនៅក្នុងស្រុកអណ្តូងមាស ។ លោកសាក្សីបានបញ្ជាក់តួនាទីជានិរសារនេះថាមិនមានការរៀនសូត្រទេ ហើយទាក់ទងនឹងការរត់សំបុត្រក៏មិនមានការនាំណែណាមួយដែរ ។ ឆ្លើយតបនឹងសំណួររបស់លោកមេធាវី ពេជ អង្គ ដែលសួរថា តើសាក្សីមានធ្លាប់ឃើញមានការ

ជម្លៀសនៅអំឡុងពេលរស់នៅខេត្តកំពង់ធំដែរឬទេ? លោកសាក្សីបានឆ្លើយថា លោកមិនដែលឃើញមានការជម្លៀសទេ ។ លោកបញ្ជាក់ទៀតថា នៅមុនឆ្នាំ១៩៧៥ លោកនៅជាប់ជាមួយនឹង កុយ ធួន និងថាមុនពេលធ្វើអ្វីមួយ កុយ ធួន តែងតែទទួលបញ្ជា និងប្រជុំជាមួយនឹង ប៉ុល ពត ជាមុន ។ សាក្សីបន្តថា លោកធ្លាប់បានឃើញ កុយ ធួន ប្រជុំជាមួយនឹង ប៉ុល ពត នៅស្រុកចម្ការលើ ។ ឆ្លើយតបនឹងសំណួររបស់មេធាវីទាក់ទងនឹងមធ្យោបាយដែលសាក្សីធ្វើដំណើរចូលមកទីក្រុងភ្នំពេញ លោកសាក្សីបាននិយាយថា លោកចូលមកដល់ទីក្រុងភ្នំពេញនៅពេលល្ងាចថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ធ្វើដំណើរដោយម៉ូតូជាមួយនឹងមនុស្សម្នាក់ផ្សេងទៀត ដោយចាកចេញពីដំណាក់ស្នាច់នៅឧដ្ដុង្គ ។ បន្ទាប់មក លោកមេធាវី ពេជ អង្គ បានសួរផ្ដោតសំខាន់លើការធ្វើដំណើរ


ពេជ អង្គ

របស់លោកសាក្សីពីឧដ្ដុង្គចូលមកទីក្រុងភ្នំពេញ ដែលភាគច្រើននៃសំណួរទាំងអស់នោះធ្លាប់ត្រូវបានសួររួចហើយដោយសហព្រះរាជអាជ្ញា ។

### ៤) ការសួរដេញដោលដោយក្រុមមេធាវីការពារក្ដីជនជាប់ចោទចំពោះសាក្សី ពាន ឃៀន

ពាក់ព័ន្ធនឹងការសួរដេញដោលចំពោះសាក្សី ពាន ឃៀន ក្រុមមេធាវីការពារក្ដីទាំងបីក្រុមបានចំណាយពេលត្រឹមតែកន្លះថ្ងៃប៉ុណ្ណោះដើម្បីធ្វើការសួរដេញដោល ។ សំណួរភាគច្រើនរបស់ក្រុមមេធាវីការពារក្ដីទាំងបីក្រុម គឺផ្ដោតលើការយល់ដឹងរបស់សាក្សីទាក់ទងនឹងមន្ទីរក-១ និងមន្ទីរក-៣ ដែលសាក្សីធ្លាប់បានអះអាងថាលោកធ្លាប់បានធ្វើការជាអ្នករៀបចំម្ហូបអាហារនៅទីនោះ ។

អង្គជំនុំជម្រះបានផ្ដល់វេទិកាជូនក្រុមមេធាវីការពារក្ដី នួន ជា ដើម្បីសួរដេញដោលលើសាក្សី ពាន ឃៀន បន្ទាប់មកការសួរដេញដោលនេះត្រូវបន្តទៅក្រុមមេធាវីការពារក្ដី អៀង សារី និង ខៀវ សំផន ។

### ក) ការសួរដេញដោលសាក្សីដោយក្រុមមេធាវីការពារក្ដី នួន ជា

លោកមេធាវី ស៊ុន អរុណ បានចាប់ផ្ដើមសំណួររបស់ខ្លួនទាក់ទងនឹងទស្សនាវដ្ដីទង់បដិវត្ត ដោយលោកមេធាវីបានសួរសាក្សីអំពីទម្រង់ និងរូបរាងនៃទស្សនាវដ្ដីនោះថា តើវាត្រូវបានសរសេរដោយដៃ ឬវាយដោយអង្គុលីលេខជាអក្សរខ្មៅ ឬមានពណ៌? លោកសាក្សីបានឆ្លើយនឹងសំណួរនេះថាលោកធ្លាប់ឃើញទស្សនាវដ្ដីនោះមានរូបកណ្ដៀវ និងញញួរនៅចំកណ្ដាល ព័ទ្ធដោយកម្រងគួរស្រូវនៅពីក្រោម ។ លោកមេធាវីបានបន្តសួរថា តើសាក្សីស្គាល់ នួន ជា ដែរឬទេ? លោកសាក្សីបានឆ្លើយថាលោក ស្គាល់ នួន ជា នៅពេលដែលលោកធ្វើការនៅមន្ទីរក-៣នៅអំឡុងឆ្នាំ១៩៧៦ ។ លោកបន្ថែមថា លោកធ្លាប់បានបម្រើ នួន ជា តាមរយៈលើកបាយទឹកជូន នួន ជា ។ បន្ទាប់មក លោកមេធាវីបានបន្តសួរទៀតថាតើ នួន ជា ជាមនុស្សដែលមានអត្តចរិតបែបណា? លោកសាក្សីបានឆ្លើយតបនឹងសំណួរនេះថា នួន ជា គឺជាមនុស្សរាក់ទាក់មួយរូប ។ ឆ្លើយតបនឹងសំណួររបស់មេធាវីថាតើ នួន ជា មានតួនាទីជាអ្វីនៅអំឡុងនៃរបបកម្ពុជាប្រជាធិបតេយ្យ? សាក្សីបានបញ្ជាក់ថា នួន ជា មាននាទីជាប្រធានសភាតំណាងប្រជាជន ប៉ុន្តែលោកមិនបានដឹងថា នួន ជា មានតួនាទីអ្វីផ្សេងទៀតឡើយ ។

ចំពោះសំណួររបស់លោកមេធាវី ទាក់ទងនឹងការចូលមកដល់របស់ទាហានវៀតណាមក្នុងទីក្រុងភ្នំពេញ លោកសាក្សីបានឆ្លើយតបថា លោកមិនបានឃើញទាហានវៀតណាមផ្ទាល់ភ្នែកទេ ប៉ុន្តែលោកបានឃើញមានរថក្រោះជាច្រើន ។ លោកមេធាវីបានសួរបន្តថា តើរថក្រោះដែលលោកសាក្សីបានឃើញនោះជារបស់អ្នកណា? លោកសាក្សីបានបំភ្លឺថា លោកមិនច្បាស់ថារថក្រោះ

ទាំងនោះជារបស់អ្នកណាទេ ព្រោះសភាពការណ៍នៅពេលនោះមានភាពច្របូកច្របល់ ។

ពាក់ព័ន្ធនឹងសំណួររបស់មេធាវីដែលសួរទាក់ទងនឹងអត្តចរិតរបស់ ប៉ុន លោកសាក្សីបានបញ្ជាក់ថា លោកស្គាល់ ប៉ុន ច្បាស់ និងថា ប៉ុន គឺជាមនុស្សល្អ ។ រីឯសំណួរទាក់ទងនឹងស្ថានភាពទីក្រុងភ្នំពេញក្រោយពេលរំដោះ លោកនិយាយថា នៅពេលទាហានខ្មែរក្រហមរំដោះភ្នំពេញបាន លោកកត់សម្គាល់ថាទីក្រុងភ្នំពេញនៅពេលនោះមានសភាពរញ៉េរញ៉ៃ ប៉ុន្តែមិនមានការវាយតប់គ្នាទេ ។

ឆ្លើយតបនឹងសំណួររបស់លោកមេធាវី អរុណ ទាក់ទងនឹងការទម្លាក់គ្រាប់បែករបស់សហរដ្ឋអាមេរិកមកលើប្រទេសកម្ពុជា លោកសាក្សីបានបញ្ជាក់ថា នៅអំឡុងពេលដែលលោករស់នៅខេត្តកំពង់ធំ លោកធ្លាប់បានជួបប្រទះការទម្លាក់គ្រាប់បែករបស់សហរដ្ឋអាមេរិក ប៉ុន្តែជាសំណាងល្អមិនមានសមាជិកគ្រួសាររបស់លោកណាម្នាក់ទទួលរងរបួសនៅពេលនោះឡើយ ។

គួរកត់សម្គាល់ថា នៅស្របពេលដែលក្រុមមេធាវីការពារក្តី នួន ជា កំពុងសួរដេញដោល សាក្សី ពាន យឿន មកដល់សំណួរនេះ អង្គជំនុំជម្រះត្រូវបានជូនដំណឹងថា ជនជាប់ចោទ អៀង សារី មានបញ្ហាសុខភាពដែលតម្រូវឲ្យមេធាវីការពារត្រូវទៅពិភាក្សាជាមួយនឹងកូនក្តីរបស់ខ្លួនជាបន្ទាន់ ។ បន្ទាប់ពីបានពិភាក្សាជាមួយនឹងកូនក្តីរបស់ខ្លួន មេធាវីការពារក្តីទាំងពីររូបរបស់ជនជាប់ចោទ អៀង សារី បានជូនដំណឹងមកអង្គជំនុំជម្រះថា អៀង សារី មានបញ្ហាសុខភាពធ្ងន់ធ្ងរមធ្យមដែលតម្រូវឲ្យមានការព្យាបាលនិងត្រួតពិនិត្យនៅមន្ទីរពេទ្យជាបន្ទាន់ ។ លោកមេធាវី អាង ឧត្តម ក៏បានស្នើសុំអង្គជំនុំជម្រះបន្តសវនាការដោយមិនមានវត្តមានកូនក្តីរបស់ខ្លួន ។ ឆ្លើយតបនឹងសំណើសុំរបស់មេធាវីការពារក្តី អៀង សារី អង្គជំនុំជម្រះបានសម្រេចអនុញ្ញាតឲ្យបន្តដំណើរការនីតិវិធីសវនាការដោយមិនមានវត្តមាន របស់ជនជាប់ចោទ អៀង សារី ។

បន្ទាប់ពីដោះស្រាយបញ្ហានេះរួចរាល់ អង្គជំនុំជម្រះបានអនុញ្ញាតឲ្យមេធាវីការពារក្តី នួន ជា បន្តសំណួររបស់ខ្លួន ។ លោកមេធាវី អរុណ បានបន្តសួរសំណួររបស់ខ្លួនទាក់ទងនឹងការទម្លាក់គ្រាប់បែករបស់អាមេរិកថា តើការទម្លាក់គ្រាប់បែកនោះប៉ះពាល់ជីវិតមនុស្ស ឬស្រែចម្ការរបស់ប្រជាជនដែរឬទេ? លោកសាក្សីបានបញ្ជាក់ថា ការទម្លាក់គ្រាប់បែកនោះបានប៉ះពាល់ដល់ស្រែចម្ការរបស់ប្រជាជន ព្រៃឈើ និងស្ពាន ប៉ុន្តែលោកមិនបានឃើញមានស្លាប់មនុស្សទេ ។ លោកមេធាវីបានសួរពីសភាពការណ៍មុនរំដោះភ្នំពេញ ថាតើមានហេតុការណ៍អ្វីខ្លះបានកើតឡើង? លោកសាក្សីបានបញ្ជាក់ថា នៅមុនពេលរំដោះបានភ្នំពេញ លោកបានឃើញកងទ័ពវៀតណាមនៅខេត្តកំពង់ធំចូលមកជួយរំដោះប្រទេសកម្ពុជាពីអាមេរិក ។ តើលោកសាក្សីមានបានដឹងថា កងទ័ពវៀតណាមមានចំនួនប៉ុន្មាននាក់ដែរឬទេ? សាក្សីបានឆ្លើយថា មានទាហានវៀតណាមមានចំនួនច្រើនគឺប្រហែលមួយកងពល ។

ឆ្លើយតបនឹងសំណួររបស់លោកមេធាវីទាក់ទងនឹងការចាប់ខ្លួនរបស់ កុយ ធួន លោកសាក្សីបានឆ្លើយថា លោកបានដឹងពីការចាប់ខ្លួនរបស់ កុយ ធួន តាមរយៈវិទ្យុដែលចោទថា កុយ ធួន ជាប់ខ្សែសេ.អ៊ី.អា ។ ប៉ុន្តែលោកបញ្ជាក់ថា លោកមិនបានដឹងថាហេតុអ្វីបានជាលោកត្រូវបានបញ្ជូនចេញពីមន្ទីរក-១ ទៅវត្តស្វាយមាសក្រោយការចាប់ខ្លួនរបស់ កុយ ធួន ទេ ។ បន្ទាប់ពីបញ្ចប់សំណួរនេះ លោកមេធាវី អរុណ បានប្រគល់វេទិកាជូនសហភាគាររបស់ខ្លួនដើម្បីសាកសួរបន្ត ។

មេធាវីអន្តរជាតិការពារក្តី នួន ជា គឺលោក អេនឌ្រូ អ៊ីនូហ្វ៊ី បានចាប់សំណួរដំបូងរបស់ខ្លួន ទាក់ទងនឹងទីតាំងនៃមន្ទីរក-១ ដោយលោកមេធាវីបានចោទសួរថា តើលោកសាក្សីមានបានដឹងពីការសម្តែងរបស់ក្រុមសៀករបស់ប្រទេសចិននៅក្នុងសាលចតុមុខដែរឬទេ? លោកសាក្សីបាននិយាយថា ធ្លាប់បានចូលរួម ប៉ុន្តែលោកមិនបានចាំកន្លែងច្បាស់នោះទេ ។ បន្ទាប់មកលោកមេធាវីបានបន្តសំណួរថាតើលោកសាក្សីមានបានដឹងពីការជំនុំជម្រះលើរបបប្រល័យពូជសាសន៍ ប៉ុល ពត ដោយរបបសាធារណរដ្ឋកម្ពុជារបស់ ហ៊ុន សែន និង ហេង សំរិន នៅសាលសន្និសីទចតុមុខដែរឬទេ? និងថាតើលោកសាក្សីបានដឹងទេថាសវនាការដែលកំពុងដំណើរការនាពេលនេះគឺចម្លងតាមសវនាការកាលពីឆ្នាំ១៩៧៩? ប៉ុន្តែសំណួរនេះមិនត្រូវបានអង្គជំនុំជម្រះអនុញ្ញាតឲ្យសាក្សីឆ្លើយតបឡើយ ដោយផ្តល់ហេតុផលថា សំណួរដែលមេធាវីការពារក្តីបានសួរមិនពាក់ព័ន្ធនឹងសវនាការ ។ លោកមេធាវីបានបញ្ជាក់ថា ការណ៍ដែលលោកសួរសំណួរនេះគឺដោយ

សារតែលោកចង់បង្ហាញថា សវនាការកាត់ក្តីនៅឆ្នាំ១៩៧៩ គឺគ្រាន់តែជាសវនាការឆាកល្ខោនតែប៉ុណ្ណោះ ។ លោកមេធាវីបានលើកយកឯកសារមួយដែលជាបទសម្ភាសន៍រវាងសាក្សីនិងបុគ្គលិករបស់តុលាការបង្ហាញជូនសាក្សីដើម្បីបញ្ជាក់ថា តើសម្តីដែលលោកសាក្សីបាននិយាយនៅក្នុងឯកសារនោះត្រឹមដែរឬទេ? លោកសាក្សីបានបញ្ជាក់ថា សម្តីទាំងអស់នោះគឺត្រឹមត្រូវ ។

លោកមេធាវីការពារក្តី អ៊ីនូហ្ស៊ី បានបន្តសំណួររបស់ខ្លួនទាក់ទងនឹងការនាំប្រជាជនចេញពីវត្តស្វាយមាស ថាតើការនាំមនុស្សចេញនេះត្រូវបានគេយកចេញទៅសម្លាប់ឬយ៉ាងណា? លោកសាក្សីបានឆ្លើយថា លោកបានដឹងថា ពិតជាមានការយកមនុស្សចេញពីទីនោះ ប៉ុន្តែលោកមិនបានដឹងថាមានការសម្លាប់ឬយ៉ាងណាចំពោះអ្នកទាំងអស់នោះទេ ។

**ខ) ការសួរដេញដោលសាក្សីដោយក្រុមមេធាវីការពារក្តី អៀង សារី**

ពាក់ព័ន្ធនឹងការសួរដេញដោលលើសាក្សី ពាន យឿន ក្រុមមេធាវីការពារក្តី អៀង សារី បានចំណាយពេលប្រមាណ២០នាទីតែប៉ុណ្ណោះដើម្បីចោទសំណួរលើសាក្សី ដែលភាគីច្រើននៃសំណួរទាំងអស់នោះគឺផ្អែកលើឯកសារបទសម្ភាសន៍ដែលធ្វើឡើងដោយបុគ្គលិករបស់តុលាការជាមួយនឹងសាក្សី ។

លោក អាង ឧត្តម មេធាវីជាតិការពារក្តីឲ្យជនជាប់ចោទ អៀង សារី បានចាប់ផ្តើមសំណួរ ដំបូងរបស់ខ្លួនដោយចោទសួរសាក្សីថាតើលោកសាក្សីដែលបានចូលរួមប្រជុំជាមួយនឹងមេដឹកនាំនៃរបបកម្ពុជាប្រជាធិបតេយ្យឬទេ? លោកសាក្សីបានឆ្លើយថាលោកមិនបានចូលរួមប្រជុំជាមួយនឹងមេដឹកនាំជាន់ខ្ពស់ទាំងអស់នោះទេ ។ លោកមេធាវីបានសួរបន្តទៀតថា តើសាក្សីនៅតែរក្សាសម្តីដែលថាខ្លួនមិនដែលបានលើកម្ហូបអាហារជូនមេដឹកនាំជាន់ខ្ពស់ទាំងអស់នោះនៅអំឡុងពេលប្រជុំដែរឬទេ? លោកសាក្សីបានឆ្លើយថា លោកនៅតែរក្សាសម្តីរបស់ខ្លួនដែលនិយាយដូច្នេះដដែល ព្រោះលោកពិតជាមិនដែលបានឃើញ ។ លោកបានសួរបន្តទៀតថា តើសាក្សីដឹងថាមានមេដឹកនាំណាខ្លះនៅក្នុងកិច្ចប្រជុំនោះដែរឬទេ? លោកសាក្សីបានឆ្លើយថា លោកមិនបានដឹងថាមានមេដឹកនាំណាខ្លះនៅក្នុងកិច្ចប្រជុំនោះទេ ហើយលោកក៏មិនបានដឹងថានៅក្នុងកិច្ចប្រជុំនោះនិយាយពីអ្វីដែរ ព្រោះលោកនៅតែកន្លែងចង្ក្រានបាយ ។ សាក្សី បានបញ្ជាក់ទៀតថាការណ៍ដែលលោកនិយាយថាមេដឹកនាំជាន់ខ្ពស់ទាំងអស់នោះនៅក្នុងកិច្ចប្រជុំគ្រាន់តែជាការសន្និដ្ឋានរបស់លោកតែប៉ុណ្ណោះ ។ ឆ្លើយតបនឹងសំណួររបស់មេធាវីទាក់ទងនឹងការប្រជុំជាមួយនឹងអង្គការ លោកសាក្សីបានឆ្លើយថា លោកមិនធ្លាប់បានចូលរួមប្រជុំជាមួយនឹងអង្គការទេ ហើយលោកក៏មិនដែលបានទទួលកំណត់ហេតុប្រជុំទាំងអស់នោះដែរ ។

បន្ទាប់ពីលោកមេធាវី អាង ឧត្តម បានបញ្ចប់ការសួរដេញដោលរបស់ខ្លួន អង្គជំនុំជម្រះបានប្រគល់វេទិកាជូនក្រុមមេធាវីការពារក្តី ខៀវ សំផន ដើម្បីសួរដេញដោលលើសាក្សី ។

**គ) ការសួរដេញដោលសាក្សីដោយក្រុមមេធាវីការពារក្តី ខៀវ សំផន**



អង់តា ហ្គីហ្សេ

នៅពេលចាប់ផ្តើមមេធាវីអន្តរជាតិការពារក្តី ខៀវ សំផន គឺមេធា វី អង់តា ហ្គីហ្សេ បានសួរសាក្សីទាក់ទងនឹងរយៈកាលដែលលោកសាក្សីបានធ្វើការនៅមន្ទីរក-១ ។ មេធាវី ហ្គីហ្សេ បានសួរថា តើសាក្សីមានការកត់សម្គាល់អ្វីទេនៅអំឡុងពេលដែលលោកនៅធ្វើការរយៈពេល៦ខែនៅមន្ទីរក-១? សាក្សីបានបញ្ជាក់ថា ពេលខ្លះលោកស្នាក់នៅខាងក្នុងពេលខ្លះលោកស្នាក់នៅខាងក្រៅនៃមន្ទីរនោះ ដូច្នេះលោកមិនអាចនិយាយឲ្យត្រឹមត្រូវបានទេ ។ លោកបន្ថែមថា កន្លែងដែលលោកស្នាក់នៅ គឺកន្លែង

ផ្សេងគ្នាពីអគារដែល ប៉ុល ពត ស្នាក់នៅ ។ លោកបានបញ្ជាក់ថា នៅច្រកទ្វារចេញចូលនៃមន្ទីរក-១ គឺមានទាហានយាមនៅទីនោះជារៀងរាល់ថ្ងៃ ។ បន្ទាប់ពីចាកចេញពីមន្ទីរក-១ លោកមិនដែលត្រឡប់ទៅទីនោះវិញទេ ។ ទាក់ទងនឹងមន្ទីរក-៣ លោកសាក្សីបញ្ជាក់ថា មន្ទីរក-៣ មានមនុស្សធ្វើការច្រើន ដូច្នេះលោកសន្និដ្ឋានថាមន្ទីរក-៣មានទំហំធំជាងមន្ទីរក-១ ។ លោកធ្លាប់ទៅមន្ទីរក-៣ រយៈពេល៦ខែ ដោយត្រូវយកម្ហូបអាហារ ដូចជាត្រី និងអង្ករទៅទីនោះ ។ លោកបានបន្ថែម ថាខ្លួនមិនបានរស់នៅមន្ទីរក-៣ជាអចិន្ត្រៃយ៍ទេ ។ លោកបានបញ្ជាក់ទៀតថា នៅមន្ទីរក-៣ ក៏ដូចជាមន្ទីរក-១ដែរ គឺមានអ្នកយាមឈរនៅមាត់ទ្វារ ។ លោកសាក្សីបញ្ជាក់ថា លោកមិនដឹងថាតើមេដឹកនាំទាំងអស់នោះជួបប្រជុំគ្នានៅទីណានៃមន្ទីរក-៣នោះទេ ។

ទាក់ទងនឹងបទសម្ភាសន៍រវាងលោកសាក្សី និងអ្នកស៊ើបអង្កេតរបស់តុលាការ មេធាវី ហ្កីហ្វេ បានសួរថា តើអ្នកស៊ើបអង្កេតទាំងអស់នោះមានបានប្រាប់លោកសាក្សីថាមកពីខាងណាដែរឬទេ? សាក្សីឆ្លើយថា អ្នកទាំងនោះបានប្រាប់លោកថា ពួកគេគឺជាក្រុមស្រាវជ្រាវរបស់សាលាក្តីខ្មែរក្រហម ។ លោកមិនដែលជួបជាមួយអ្នកសម្ភាសន៍ទាំងនោះនៅពេលក្រោយទៀតទេ ហើយលោកក៏មិនដែលបានអានឯកសារបទសម្ភាសន៍របស់លោកក្រោយពីការធ្វើបទសម្ភាសន៍នោះដែរ ។

បន្ទាប់មកមេធាវី ហ្កីហ្វេ បានបន្តសួរសំណួរទៀតថា តើចំណុចណាមួយដែលធ្វើឲ្យសាក្សី យល់ថា ខៀវ សំផន ធ្វើជាប្រធានអង្គប្រជុំនៅមន្ទីរក-៣ ប្រសិនបើលោកសាក្សីមិនដែលបានចូលរួមនៅក្នុងកិច្ចប្រជុំ និងមិនដឹងថាកិច្ចប្រជុំនោះធ្វើនៅទីណាផងនោះ? លោកសាក្សីបានឆ្លើយថា ចម្លើយរបស់លោកគឺគ្រាន់តែជាការសន្និដ្ឋានរបស់លោកតែប៉ុណ្ណោះ ។ បន្ទាប់ពីសហភាគីរបស់ខ្លួន លោកមេធាវីជាតិការពារក្តីជនជាប់ចោទ ខៀវ សំផន គឺលោក គង់ សំអុន បានចោទសំណួរភាគច្រើនទាក់ទងនឹងឋានៈរបស់សាក្សីចាប់តាំងពីការចូលរួមធ្វើបដិវត្ត ។ ឆ្លើយតបនឹងសំណួររបស់លោកមេធាវី សំអុន លោកសាក្សី ពាន យៀន បានបញ្ជាក់ថាចាប់តាំងពីលោកចូលរួមជាមួយបដិវត្ត គឺលោកមិនដែលមានតំណែង ឬឋានៈអ្វីទាំងអស់ និងថាលោកបានចំណាយពេលស្ទើរតែទាំងស្រុងនៅជាមួយគ្រួសាររបស់ កុយ ធួន ។

បន្ទាប់ពីបញ្ចប់ការផ្តល់សក្ខីកម្មរបស់សាក្សី ពាន យៀន លោកប្រធានអង្គជំនុំជម្រះ និល ណុន បានប្រកាសផ្អាកកិច្ចដំណើរការនីតិវិធី និងជូនដំណឹងអំពីសវនាការសួរដេញដោលលើសាក្សីមួយរូបផ្សេងទៀតដែលមានរហស្សនាម TCW៤៨៧ ដែលគ្រោងនឹងបន្តធ្វើនៅថ្ងៃច័ន្ទទី២១ ខែឧសភា ឆ្នាំ២០១២ ។

**បញ្ហាផ្សេងៗ**

**◆ ការពិភាក្សាអំពីសិទ្ធិនៅស្ងៀមមិនឆ្លើយតបសំណួរដោយជនជាប់ចោទ នួន ជា**



នួន ជា

នៅថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១២ នៅពេលចាប់ផ្តើមសវនាការជនជាប់ចោទ នួន ជា បានធ្វើសេចក្តីថ្លែងការណ៍បដិសេធសក្ខីកម្មរបស់សាក្សី កាំងហ្កេចអ៊ាវ ហៅ ឌុច និងបានបង្ហាញពីជំហររបស់ខ្លួនក្នុងការរក្សាសិទ្ធិនៅស្ងៀមមិនឆ្លើយតបនឹងសំណួរទាំងឡាយរបស់ភាគី និងអង្គជំនុំជម្រះ ។ ឆ្លើយតបនឹងការបង្ហាញពីជំហររបស់ជនជាប់ចោទ នួន ជា ក្នុងការមិនឆ្លើយតបសំណួរទាំងឡាយនេះ លោកតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ខេល លីសាក់ បានក្រោកឈរដើម្បីធ្វើកំណត់សម្គាល់ថា នួន ជា បដិសេធសក្ខីកម្មរបស់ ឌុច ហើយបែរជាមិនឆ្លើយតបនឹងសំណួរទៀត ។

លោកយល់ថា ការបដិសេធរបស់ជនជាប់ចោទ នួន ជា ទៅលើសាក្សី ឌុច គឺជាទង្វើដែលមិនមានទម្ងន់អ្វីគួរឲ្យទុកចិត្តបាននោះទេ ហើយជំហរមិនឆ្លើយតបសំណួរនោះ គឺជាការមិនសមស្រប និងស្នើសុំឲ្យតុលាការបកស្រាយតាមរបៀបអវិជ្ជមានប្រឆាំងនឹងជនជាប់ចោទ នួន ជា ក្នុងករណីដែលគាត់មិនឆ្លើយតបសំណួរបែបនេះ ។ លោកស្រីមេធាវីអន្តរជាតិនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី អេលីហ្សាប៊ែត ស៊ីម៉ុនណូហ្វត បានលើកឡើងដែរថា មិនឃើញមានការអនុញ្ញាតដោយច្បាប់ចំពោះការណ៍ដែលជនជាប់ចោទឆ្លើយតបរួច បែរជាផ្លាស់ប្តូរទៅជាមិនឆ្លើយវិញនោះទេ ។ ភ្លាមនោះលោកមេធាវី ស៊ុន អរុណ ការពារក្តីឲ្យជនជាប់ចោទ នួន ជា បានឆ្លើយតបវិញថា ការណ៍ដែលកូនក្តីរបស់លោកធ្វើសេចក្តីថ្លែងការណ៍នៅពេលនេះដោយសារនៅមុនពេលបើកការសួរ ឌុច នោះ នួន ជា បានស្នើសុំពេលវេលាដើម្បីថ្លែងការណ៍ ប៉ុន្តែអង្គជំនុំជម្រះមិនអនុញ្ញាតឲ្យធ្វើនៅពេលនោះទេ គឺអនុញ្ញាតឲ្យធ្វើនៅពេលក្រោយគឺពេលនេះ ។ ចំពោះជំហរមិនឆ្លើយតបសំណួររបស់ភាគី លោកមេធាវីបានអះអាងថា កូនក្តីលោកបានប្រគល់សិទ្ធិការពារមកឲ្យមេធាវីរបស់ខ្លួនជាអ្នកឆ្លើយតបហើយកូនក្តីរបស់លោកមិនមែនមិនឆ្លើយតបរហូតនោះទេគឺ នួន ជា នឹងធ្វើការឆ្លើយតបនៅពេលក្រោយ ។

### ◆ បញ្ហានៃការបើកសវនាការអសាធារណៈនិងការមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង

នៅថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១២ ដោយយោងលើឯកសាររបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត លោកតំណាងសហព្រះរាជអាជ្ញាជាតិ សេង ប៊ុនឃាង បានចោទសំណួរទាក់ទងនឹងអតីតភាពការងារដែលសាក្សីធ្លាប់បំរើជាកងការពារជនជាប់ចោទ នួន ជា ។ ភ្លាមៗលោកមេធាវីអន្តរជាតិការពារក្តីឲ្យជនជាប់ចោទ នួន ជា បានលើកឡើងពីសិទ្ធិរបស់សាក្សីនៅក្នុងវិធាន២៨(៩) នៃវិធានផ្ទៃក្នុង ដែលអនុញ្ញាតឲ្យសាក្សីមានសិទ្ធិទទួលបានការការពារដោយមេធាវី ក្នុងករណីមានបញ្ហាកើតឡើងក្នុងការឆ្លើយដាក់បន្ទុកខ្លួនឯង ។ ដូចនេះលោកមេធាវីបានស្នើសុំឲ្យអង្គជំនុំជម្រះអនុញ្ញាតផ្តល់មេធាវីម្នាក់ដើម្បីការពារដល់សាក្សី ។ លោកសហព្រះរាជអាជ្ញារងអន្តរជាតិ វីល្លៀម ស្មឹត បានជំទាស់ទៅលើការលើកឡើងរបស់លោកមេធាវីថាជាការរំខាន ហើយថាលោកមេធាវីគួរតែស្នើអង្គជំនុំជម្រះឲ្យបើកសវនាការជាអសាធារណៈ ប៉ុន្តែទោះជាយ៉ាងណាក្តីសំណើនេះត្រូវបានជំទាស់រួចទៅហើយ ។ ដូច្នេះខាងសហព្រះរាជអាជ្ញាយល់ឃើញថាគួរតែសម្រាក ដើម្បីពិភាក្សាបញ្ហានេះដោយគ្មានវត្តមានរបស់សាក្សី ដើម្បីកុំឲ្យសាក្សីរងអារម្មណ៍ដូចជាត្រូវបានបំភិតបំភ័យលើរូបគាត់ ។ ក្រុមមេធាវីតំណាង ដើមបណ្តឹងរដ្ឋប្បវេណី បានលើកឡើងដែរថា ការធ្វើអន្តរាគមន៍របស់មេធាវីការពារក្តីនៅពេលនេះ ជាការមិនសមស្រប និងមិនមានភាពស្មោះត្រង់នោះទេ ។ ចំណែកលោកមេធាវីអន្តរជាតិ កាណាវ៉ាស ការពារក្តីជនជាប់ចោទ អៀង សារី វិញបានលើកឡើងថា នៅពេល ឌុច ធ្វើសក្ខីកម្ម ព្រះរាជអាជ្ញាមិនមានការគាំទ្រឲ្យមានការបើកសវនាការអសាធារណៈទេ តែពេលនេះបែរជាគាំទ្រសវនាការបែបនេះទៅវិញ ។ លោកបានបន្ថែមថាការលើកឡើងរបស់ខាងក្រុមមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីមិនត្រឹមត្រូវទេ ព្រោះថាភាគីផ្សេងទៀតនៃដំណើររឿងអាចនឹងទទួលរងការចោទប្រកាន់ដោយតុលាការផ្សេងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ទោះបីជាមិនត្រូវបានចោទនៅចំពោះមុខតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមនេះក៏ដោយ ។

### ◆ សវនាការអសាធារណៈស្តីពីការអនុវត្តសិទ្ធិនៅស្ងៀមមិនឆ្លើយតបដោយជនជាប់ចោទ

បន្ទាប់ពីការសម្រាកនៅពេលព្រឹកនាថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១២ លោកប្រធានអង្គជំនុំជម្រះបានជូនដំណឹងដល់ភាគីទាំងអស់ថា ការស្តាប់សក្ខីកម្មរបស់សាក្សី សូត្រ ទឿង ដែលធ្វើនៅក្នុងព្រឹកនេះ គឺអង្គជំនុំជម្រះសម្រេចបន្តស្តាប់សក្ខីកម្មសាក្សីរូបនេះនៅពេលរសៀលវិញ ដោយសារបញ្ហាបច្ចេកទេសនៅក្នុងកិច្ចដំណើរការ ។ លោកប្រធានអង្គជំនុំជម្រះបានចេញសេចក្តីសម្រេចផ្ទាល់មាត់ លើបញ្ហាពាក់ព័ន្ធនឹងសិទ្ធិនៅស្ងៀមមិនឆ្លើយតបរបស់ជនជាប់ចោទ អៀង សារី និងខៀវ សំផន ឯកសារ E164 និង E174 ហើយអង្គជំនុំជម្រះកត់សម្គាល់ឃើញថា ក្រោយពីបានធ្វើសេចក្តីថ្លែងការណ៍ ទាក់ទងនឹងវគ្គទីមួយនៃការជំនុំជម្រះរួចមកជនជាប់ចោទ នួន ជា បានបញ្ជាក់ថាគាត់អាចរក្សាសិទ្ធិ នៅស្ងៀមមិនឆ្លើយតប ។ អង្គជំនុំជម្រះបានសម្រេចថា ជនជាប់ចោទមិនត្រូវ

បានបង្កឲ្យផ្តល់សក្ខីកម្មប្រឆាំងនឹងខ្លួនឯងទេ ។ នៅក្នុងករណីណាក៏ដោយ អង្គជំនុំជម្រះនឹងមិនផ្អែកទាំងស្រុងលើការទាញជាសេចក្តីសន្និដ្ឋានផ្ទុយចេញពីការរក្សាសិទ្ធិនៅស្ងៀមមិនឆ្លើយតបនៅក្នុងការវិនិច្ឆ័យអំពីកំហុសឡើយ ។ បន្ទាប់មកអង្គជំនុំជម្រះបានសម្រេចបើកសវនាការជាអសាធារណៈ ដើម្បីពិភាក្សាឲ្យបានជ្រះស្រឡះចំពោះភាពចម្រូងចម្រាសខ្លាំងកាលពីព្រឹកមិញ ទាក់ទងនឹងការដោះស្រាយបញ្ហារួមក្នុងការបន្តធ្វើសក្ខីកម្មរបស់សាក្សី ។


និល ណុន

បន្ទាប់ពីការបញ្ចប់សវនាការអសាធារណៈ នៅពេលរសៀល អង្គជំនុំជម្រះសាលាដំបូងបានបន្តសវនាការស្តាប់សក្ខីកម្មរបស់សាក្សី សូត្រ ទៀង ដោយអនុញ្ញាតឲ្យសាក្សីមានមេធាវីការពារខ្លួនម្នាក់ ឈ្មោះលោក លឹម ប៊ុនហេង ។ ការផ្តល់មេធាវីដើម្បីការពារសាក្សីតាមផ្លូវច្បាប់នេះ អង្គជំនុំជម្រះបានបំភ្លឺថា គឺក្នុងគោលបំណងការពារសាក្សីពីការឆ្លើយតបនឹងសំណួរទាំងឡាយណាដែលអាចដាក់បន្ទុក ឬពិរុទ្ធភាពប្រឆាំងនឹងខ្លួនឯង ។

មុនពេលនៃការចាប់ផ្តើមកិច្ចដំណើរការនីតិវិធីសវនាការនៅព្រឹកថ្ងៃទី២ ខែឧសភា ឆ្នាំ២០១២ មេធាវីការពារក្តីអន្តរជាតិរបស់ជនជាប់ចោទ នួន ជា គឺលោក អេនឌ្រូ អ៊ីនូហ្ស៊ី បានលើកឡើងពីការជ្រៀតជ្រែកនៅក្នុងតុលាការ និងភាពលម្អៀងរបស់លោកស្រីចៅក្រម ស៊ីលវៀ ខាតវ៉្រាយត៍ ។ ប៉ុន្តែការលើកឡើងរបស់ក្រុមមេធាវីការពារក្តី នួន ជា ត្រូវបានបដិសេធដោយអង្គជំនុំជម្រះជាមួយនឹងហេតុផលថា ការលើកឡើងរបស់មេធាវី នួន ជា មិនមានមូលដ្ឋានផ្លូវច្បាប់ ។

គួរបញ្ជាក់ថាក្នុងសំណុំរឿង០០២ សាក្សី សាឡុត បាន គឺជាសាក្សីទីពីរបន្ទាប់ពីសាក្សី សូត្រ ទៀង ដែលមានមេធាវីនៅអង្គុយអមប្រឹក្សាយោបល់មុននឹងផ្តល់សក្ខីកម្មជូនអង្គជំនុំជម្រះ ដើម្បីជៀសវាងការឆ្លើយសំណួររបស់ភាគីផ្សេងៗដែលអាចដាក់បន្ទុកនាំឲ្យមានពិរុទ្ធភាពលើខ្លួនឯង ។ ដូច្នេះក្នុងការផ្តល់សក្ខីកម្មជូនអង្គជំនុំជម្រះ សាក្សី សាឡុត បាន មានការប្រុងប្រយ័ត្នបំផុតហើយជាច្រើនលើកច្រើនសា សក្ខីកម្មដែលបានផ្តល់ជូននេះ គឺមានការខុសគ្នានឹងសក្ខីកម្មដែលលោកបានផ្តល់ជូនចៅក្រមស៊ើបអង្កេតក្នុងតំណាក់កាលស៊ើបសួរ ។ តែទោះបីជាយ៉ាងនេះក្តីលោក សាឡុត បាន តែងតែទទួលស្គាល់នូវសក្ខីកម្មដែលខ្លួនបានផ្តល់ជូនចៅក្រមស៊ើបអង្កេតដោយគ្រាន់តែធ្វើការកត់សម្គាល់បន្ថែមខ្លីៗប៉ុណ្ណោះ ។

**◆ ការបន្ថែមពេលវេលាក្នុងការសួរសាក្សី ពាន ឃៀន**

នៅក្នុងសវនាការថ្ងៃទី៣ ខែឧសភា ឆ្នាំ២០១២ ស្តីពីការសួរដេញដោលលើសាក្សី ពាន ឃៀន តំណាងសហព្រះរាជអាជ្ញាអន្តរជាតិលោក ថារីក បានស្នើសុំអង្គជំនុំជម្រះនូវពេលវេលាបន្ថែមដើម្បីសួរដេញដោលលើសាក្សី ពាន ឃៀន ដោយសារមានអង្គហេតុថ្មីៗបានលេចឡើងអំឡុងពេលការធ្វើសក្ខីកម្មរបស់សាក្សី ។ ការស្នើសុំនេះត្រូវបានលោកតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ថារីក ផ្តល់ហេតុផលថា នៅអំឡុងពេលផ្តល់ចម្លើយនៅចំពោះមុខអ្នកស៊ើបអង្កេតលោកសាក្សីមិនបាននិយាយអំពីបញ្ហាដែលលោកបានលើកឡើងនៅក្នុងសវនាការទេ ។ ភ្លាមៗនោះ សហមេធាវីនាំមុខអន្តរជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានបង្ហាញពីជំហរគាំទ្រចំពោះការស្នើសុំរបស់លោកតំណាងសហព្រះរាជអាជ្ញា ។ ប៉ុន្តែសំណើនេះត្រូវបានក្រុមមេធាវីការពារក្តីរបស់ជនជាប់ចោទទាំងបីក្រុមបានធ្វើការជំទាស់ ។ បន្ទាប់ពីបានពិភាក្សា និងពិចារណារួចមកអង្គជំនុំជម្រះបានយល់ស្របតាមសំណើរបស់លោកតំណាងសហព្រះរាជអាជ្ញាដែលស្នើសុំពេលវេលាបន្ថែមដើម្បីសួរដេញដោលលើសាក្សី ពាន ឃៀន ។ **ពិនិត្យនិងផ្ទៀងផ្ទាត់ដោយ ខាន់ថាន់ ពៅដារ៉ា**

## ពន្យល់ពាក្យសំខាន់ៗ

ប-១ : មន្ទីរនៃក្រសួងការបរទេស ។

ប-៣០,៣១,៣២ : ជំរំអប់រំកែប្រែសម្រាប់បញ្ញវន្ត អ្នកការទូត និង និស្សិតដែលធ្វើមាតុភូមិនិវត្តន៍ មានទីតាំងស្ថិតនៅបឹងត្របែកក្នុងទីក្រុងភ្នំពេញ ដែលត្រូវបានប្តូរឈ្មោះដែលភ្ជាប់លេខកូដអក្សរ "ប" បន្ទាប់ពីបានផ្ទេរការគ្រប់គ្រងពីមន្ទីរ៨៧០ មកឲ្យក្រសួងការបរទេស ហើយដែលពីមុនត្រូវបានគេស្គាល់ថា ក-១៥, ក-១៦ និង ក-១៧ ។

ក-១ : លំនៅដ្ឋានមួយរបស់សមាជិកនានានៃគណៈកម្មាធិការអចិន្ត្រៃយ៍ និងជាកន្លែងធ្វើការរបស់ ប៉ុល ពត ។


## មជ្ឈមណ្ឌលឯកសារកម្ពុជា

ប្រអប់សំបុត្រលេខ១១១០, ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទ : (៨៥៥) ២៣ ២១១ ៨៧៥

ទូរសារ : (៨៥៥) ២៣ ២១០ ៣៥៨

អ៊ីម៉ែល : *dccam@online.com.kh*

គេហទំព័រ : *www.dccam.org* ឬ *www.cambodiatribunal.org*



គម្រោងនេះទទួលជំនួយហិរញ្ញវត្ថុពីមូលនិធិ

*John D. and Catherine T. MacArthur Foundation and British Embassy-Cambodia* ។


| ល.រ | ឈ្មោះដើម | ឈ្មោះបដិវត្ត | លេខសម្ងាត់ | ប្រភពឯកសារ |
|---|---|---|---|---|
| ១ | សាឡុត ស | ប៉ុល ពត, បងប៉ុល, បងទី១, | ៨៧០, ៨៧ | D427, E1/56.1 |
| ២ | នួន ជា | នួន ជា, បងនួន, បងទី២ | (អត់ដឹង) | D427 |
| ៣ | គីម ត្រាង | អៀង សារី, វ៉ាន់ | (អត់ដឹង) | D427, E1/21.1 |
| ៤ | ខៀវ សំផន | ហែម, ខាង, ណន | (អត់ដឹង) | D427 |
| ៥ | សុន សេន | ខៀវ, ឃឹម | ៨៩, ៦២ | E1/54.1 |



**ឆាយ ឈុនលី**

**ឈុនលី** ទទួលបានបរិញ្ញាប័ត្រច្បាប់ ពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ។



**ឌី សុជាតា**

**សុជាតា** ជានិស្សិតថ្នាក់បរិញ្ញាប័ត្រផ្នែកច្បាប់ សិក្សាជាភាសាអង់គ្លេស នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ។



**លឹម ជ័យរ័ត្ន**

**ជ័យរ័ត្ន** ទទួលបានបរិញ្ញាប័ត្រច្បាប់ ពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ។ ជ័យរ័ត្ន ជាអតីតជ័យលាភីថ្នាក់ជាតិនៅក្នុងការប្រកួតសវនាការប្រឌិតឆ្នាំ២០១០ ។



**ចាន់ ប្រាថ្នា**

**ប្រាថ្នា** ទទួលបានបរិញ្ញាប័ត្រច្បាប់ ពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ។ ប្រាថ្នា សព្វថ្ងៃកំពុងត្រៀមប្រឡងសិក្សាវិជ្ជាជីវៈមេធាវីនៅកម្ពុជា ។



សុន សេន រដ្ឋមន្ត្រីក្រសួងការពារជាតិនៃរបបកម្ពុជាប្រជាធិបតេយ្យ

មជ្ឈមណ្ឌលឯកសារកម្ពុជា រក្សាសិទ្ធិ ខែមិថុនា ឆ្នាំ២០១២